# ការស្រាវជ្រាវ និងអភិវឌ្ឍន៍ស្តីពី ការប្រែប្រួលអាកាសធាតុ និងវិស័យពាក់ព័ន្ធនៅ ក្នុងការអប់រំកម្រិតឧត្តមសិក្សានៅប្រទេសកម្ពុជា ឡាវ និងវៀតណាម៖ ស្ថានភាពបច្ចុប្បន្ន និងនិន្នាការ

REACT

Co-funded by the
Erasmus+ Programme
of the European Union

Reference Number:
573964-EPP-1-2016-1-ES-EPPKA2-CBHE-JP

## ព័ត៌មានអំពីអ្នកបោះពុម្ព

| | |
|---|---|
| គម្រោង | strengthening climate change REsearch And innovation CapaciTies in Cambodia, Laos and Vietnam |
| អក្សរកាត់ | **REACT** |
| លេខសំគាល់មូលនិធិ | #573964-EPP-1-2016-1-ES-EPPKA2-CBHE-JP |
| អ្នកនិពន្ធរបាយការណ៍ | Lodovica Di Deodato, Gizem Erdogmus & Dr. Roderich v.Detten<br>Albert-Ludwigs-Universität Freiburg (University of Freiburg)<br>Institute of Environmental Social Sciences and Geography<br>Chair of Forestry Economics and Forest Planning |

**បណ្ដាញគម្រោងរីអ៊ែក៖**

សហគមន៍អឺរ៉ុប៖

- សាកលវិទ្យាល័យអាលីកាន់តេ (University of Alicante) (ប្រទេសអេស្ប៉ាញ), អ្នកសម្របសម្រួល
- សាកលវិទ្យាល័យហ្វ្រាយប៊ឺហ្គ (University of Freiburg) (ប្រទេសអាឡឺម៉ង់)
- Institut Euro-Méditerranéen en Science du Risque (ប្រទេសបារាំង)
- Università degli Studi di Genova (ប្រទេសអ៊ីតាលី)

កម្ពុជា៖

- សាកលវិទ្យាល័យភូមិន្ទកសិកម្ម (Royal University of Agriculture)
- សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ (University of Heng Samrin Thbongkhmum)

ឡាវ៖

- សាកលវិទ្យាល័យជាតិឡាវ (National University of Laos)
- សាកលវិទ្យាល័យសុផានូវង្ស (Souphanouvong University)
- វិទ្យាស្ថានជាតិសម្រាប់ការស្រាវជ្រាវសេដ្ឋកិច្ច (National Institute for Economic Research)

វៀតណាម៖

- សាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហ៊ូ (Hue University of Agriculture and Forestry)
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ ទីក្រុងហូជីមីញ/ សាកលវិទ្យាល័យជាតិវៀតណាម (University of Social Sciences and Humanities Ho Chi Minh/ Vietnam National University)

**ព័តមានទំនាក់ទំនង៖** ការិយាល័យគ្រប់គ្រងគម្រោងអន្តរជាតិ (OGPI) – សាកលវិទ្យាល័យអាលីកាន់តេ

**វេបសាយ៖** www.ogpi.ua.es

**រីអ៊ែក (REACT)៖** www.climate-react.eu

**ការទទួលស្គាល់៖** ចំពោះបុគ្គលិកដែលខិតខំប្រឹងប្រែងនៅក្នុងស្ថាប័នដៃគូ ដែលបានវិនិយោគលើភាពជោគជ័យនៃគម្រោងនេះហើយបានទទួលខុសត្រូវក្នុងការរៀបចំការពិភាក្សាក្រុម (Focus Group) ដែលបានផ្ដល់ទិន្នន័យសម្រាប់ការវិភាគនេះ ក៏ដូចជាគណៈកម្មាធិការអឺរ៉ុបសម្រាប់ការគាំទ្រនិងសហហិរញ្ញប្បទានគម្រោងនេះតាមរយៈកម្មវិធី Erasmus+។

# ការស្រាវជ្រាវ និងអភិវឌ្ឍន៍ស្តីពី ការប្រែប្រួលអាកាសធាតុ និងវិស័យពាក់ព័ន្ធនៅក្នុងការអប់រំកម្រិតឧត្តមសិក្សានៅប្រទេសកម្ពុជា ឡាវ និងវៀតណាម៖ ស្ថានភាពបច្ចុប្បន្ន និងនិន្នាការ

**ការអះអាងផ្នែកច្បាប់**

ឯកសារនេះត្រូវបានបង្កើតឡើងនិងកែសម្រួលដោយស្ថាប័នដៃគូនៃគម្រោង រីអ៊ែក/REACTនៃ Erasmus+ គឺគម្រោង " **ការពង្រឹងសមត្ថភាពក្នុងការស្រាវជ្រាវ និងនវានុវត្តន៍ស្តីពីការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម** " ក្រោមការសម្របសម្រួលរបស់សាកលវិទ្យាល័យអាលីកាន់តេ។ លទ្ធផល ទស្សនៈ និងគំនិតដែលបានបង្ហាញក្នុងឯកសារនេះគឺជារបស់អ្នកនិពន្ធ ហើយគណៈកម្មការសហគមន៍អឺរ៉ុបមិនទទួលខុសត្រូវលើរាល់ការប្រើប្រាស់ណាមួយចេញពីព័ត៌មានដែលមានក្នុងឯកសារនេះឡើយ។

ខ្លឹមសារទាំងអស់ដែលបង្កើតឡើងដោយគម្រោង REACT ត្រូវបានការពារដោយច្បាប់កម្មសិទ្ធិបញ្ញា ក្នុងន័យការពារសិទ្ធអ្នកនិពន្ធ។

កែសម្រួលដោយសាកលវិទ្យាល័យអាលីកាន់តេ ប្រទេសអេស្ប៉ាញ។

© សាកលវិទ្យាល័យអាលីកាន់តេ ឆ្នាំ២០១៨។ រក្សាសិទ្ធគ្រប់យ៉ាង។ ការផលិតឡើងវិញត្រូវបានអនុញ្ញាតិបើមានការផ្តល់ការយោងត្រឹមត្រូវ។

សូមដាក់ការយោងលើឯកសារនេះដូច្នេះ៖ *Di Deodato L., Erdogmus G.  & Dr. v. Detten R. (2018). R&D in Climate Change and Related Areas within Higher Education in Cambodia, Laos and Vietnam: Current Status and Trends. REACT project. Erasmus+ programme.*

Co-funded by the
Erasmus+ Programme
of the European Union

# បញ្ជីមាតិកា


បញ្ជីតារាង និងក្រាហ្វិច.....7
បញ្ជីតារាងក្នុងឧបសម្ព័ន្ធ.....7
បញ្ជីអក្សរកាត់.....8
អារម្ភកថា.....9
សេចក្តីសង្ខេប.....11
សេចក្តីផ្តើម.....14
គោលបំណងរបស់របាយការណ៍.....14
មាតិកា និងរចនាសម្ព័ន្ធនៃរបាយការណ៍.....14
ការវិភាគលទ្ធផលពីបញ្ជីសំណួរ.....17
លទ្ធផលពីបញ្ជីសំណួរ " ការប្រែប្រួលអាកាសធាតុនៅតាមគ្រឹះស្ថានអប់រំ".....17
a. គ្រឹះស្ថានអប់រំដែលមានផ្តល់ការសិក្សាកម្រិតសញ្ញាប័ត្រ ឬវគ្គសិក្សាអំពីការប្រែប្រួលអាកាសធាតុ.....18
b. ស្ថាប័ននានាដែលផ្តល់សម្ភារបង្រៀនឬព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ.....20
c. ស្ថាប័នដែលមានផ្តល់នូវកម្មវិធីថ្នាក់បណ្ឌិតស្តីពីប្រធានបទការប្រែប្រួលអាកាសធាតុ.....21
d. កម្មវិធីគុណវុឌ្ឍដើម្បីពង្រឹងជំនាញស្រាវជ្រាវឬថ្នាក់ត្រៀមសម្រាប់ថ្នាក់បរិញ្ញបត្រជាន់ខ្ពស់រឺថ្នាក់បណ្ឌិត.22
e. ស្ថាប័នចូលរួមក្នុងតួអង្គស្រាវជ្រាវដែលមានលក្ខណៈអន្តរវិស័យលើប្រធានបទពាក់ព័ន្ធ CC.....23
លទ្ធផលពីបញ្ជីសំណួរ "ការស្រាវជ្រាវក្នុងការប្រែប្រួលអាកាសធាតុ".....23
a. អ្នកចូលរួមដែលបានអនុវត្តន៍ការស្រាវជ្រាវក្នុងការប្រែប្រួលអាកាសធាតុ.....24
b. អ្នកចូលរួមដែលសហការជាមួយដៃគូអន្តរជាតិ និងស្ថាប័នឯកជន.....26
c. តម្រូវការជំនាញសិក្សាស្រាវជ្រាវ.....27
ការវិភាគលើការពិភាក្សាជាក្រុម.....29
ប្រទេសកម្ពុជា៖ អាជ្ញាធរជាតិ និងវិស័យឯជន.....29
ទស្សនៈការយល់ឃើញ និងការផ្សព្វផ្សាយ.....29
សមត្ថភាពថ្នាក់ជាតិស្តីពីការស្រាវជ្រាវនិងការអភិវឌ្ឍ និងតួនាទីរបស់វិស័យឯកជន.....35
ការផ្តល់ហិរញ្ញវត្ថុ និងធនធានសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍការប្រែប្រួលអាកាសធាតុ.....36
ប្រទេសកម្ពុជា៖ មុខវិជ្ជាសិក្សា.....39
ប្រទេសកម្ពុជា៖ និស្សិត.....45
ប្រទេសឡាវ ៖ អាជ្ញាធរជាតិ និងវិស័យឯកជន.....47
ទស្សនៈ និងការយល់ដឹង.....48

សមត្ថភាពថ្នាក់ជាតិស្តីពី R&D និងតួនាទីវិស័យឯកជន....51
ហិរញ្ញប្បទាន និងធនធាន....53
ប្រទេសឡាវ៖ ការអប់រំ....54
ប្រទេសឡាវ៖ និស្សិត....57
ប្រទេសវៀតណាម៖ អាជ្ញាធរមូលជាតិ និងវិស័យឯកជន....58
ទស្សនៈ និងការយល់ដឹង....59
សមត្ថភាពថ្នាក់ជាតិលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងតួនាទីវិស័យឯកជន....62
ការផ្តល់ហិរញ្ញប្បទាន និងប្រភពសម្រាប់ស្រាវជ្រាវ និងការអនុវត្តការប្រែប្រួលអាកាសធាតុ....64
ប្រទេសវៀតណាម៖ ការអប់រំ....66
ប្រទេសវៀតណាម៖ និស្សិត....71
សេចក្តីសន្និដ្ឋាន និងអនុសាសន៍....75
ឧបសម្ព័ន្ធ....78

## បញ្ជីតារាង និងក្រាហ្វិច

ក្រាហ្វិច 1៖ ចំនួនស្ថាប័នដែលបានចូលរួមក្នុងការស្ទង់មតិ.....17
ក្រាហ្វិច 2៖ ចំនួនវិទ្យាស្ថានដែលមានផ្តល់ការសិក្សាកម្រិតសញ្ញាប័ត្រ ឬវគ្គសិក្សាអំពីការប្រែប្រួលអាកាសធាតុ..18
ក្រាហ្វិច 3៖ ស្ថាប័ននានាដែលផ្តល់សម្ភារបង្រៀនឬព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ.....20
ក្រាហ្វិច 4៖ ស្ថាប័នមានដែលផ្តល់នូវកម្មវិធីថ្នាក់បណ្ឌិតស្តីពីប្រធានបទការប្រែប្រួលអាកាសធាតុ.....21
ក្រាហ្វិច 5៖ ចំនួនស្ថាប័នដែលមានផ្តល់កម្មវិធីគុណវុទ្ធ.....22
ក្រាហ្វិច 6៖ ចំនួនស្ថាប័នចូលរួមក្នុងតួអង្គស្រាវជ្រាវដែលមានលក្ខណៈអន្តរវិស័យ និងចំនួននៃការស្រាវជ្រាវដែលបានអនុវត្តន៍.....23
ក្រាហ្វិច 7៖ ចំនួណស្ថាប័នចូលរួម និងអ្នកស្រាវជ្រាវ.....24
ក្រាហ្វិច 8៖ ចំនួនអ្នកស្រាវជ្រាវដែលអនុវត្តន៍ និងមិនអនុវត្តន៍ការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ.....24
ក្រាហ្វិច 9៖ អ្នកស្រាវជ្រាវសហការជាមួយដៃគូអន្តរជាតិ និងស្ថាប័នឯកជន.....26
ក្រាហ្វិច10៖ ការប្រៀបធៀបរវាងអ្នកស្រាវជាវក្នុងជំនាញការប្រែប្រួលអាកាសធាតុ និងក្រៅជំនាញដែលបាន.....27

តារាង 1 ៖ មុខវិជ្ជាសិក្សាដែលផ្តល់ដោយស្ថាប័នស្តីពីការប្រែប្រួលអាកាសធាតុ.....19

## បញ្ជីតារាងក្នុងឧបសម្ព័ន្ធ

តារាង 1៖ ស្ថាប័នពាក់ព័ន្ធចូលរួមក្នុងអង្គភាពស្រាវជ្រាវអន្តរគម្រោង ដៃគូអភិវឌ្ឍន៍ ដៃគូជំនួយ និងជំនួយទទួលបាន.....78
តារាង 2៖ ការស្រាវជ្រាវតាមផ្នែក និងប្រធានបទនៃអ្នកស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុ.....82
តារាង 3៖ ស្ថាប័នឯកជននិងអន្តរជាតិដែលចូលរួមក្នុងការធ្វើការស្រាវជ្រាវ.....89
តារាង 4៖ តំបន់ដែលត្រូវការការស្រាវជ្រាវបន្ថែម.....94
តារាង 5៖ ស្ថាប័នដែលបានចូលរួមក្នុងកិច្ចពិភាក្សាក្រុម "អាជ្ញាធរ" និង "វិស័យឯកជន".....98
តារាង 6៖ អ្នកចូលរួមក្នុងក្រុមពិភាក្សា "គ្រឹះស្ថានសិក្សា".....100
តារាង 7: អ្នកចូលរួមក្រុមពិភាក្សាលើ "សិស្ស".....102

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| **ALU** | Albert-Ludwig Universität of Freiburg | សាកលវិទ្យាល័យហ្វ្រាយប៊ឺហ្គ |
| **CC** | Climate Change | ការប្រែប្រួលអាកាសធាតុ |
| **EU** | European Union | សហភាពអឺរ៉ុប |
| **HCM USSH** | Ho Chi Minh University of Social Sciences & Humanities | សាកលវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ ទីក្រុងហូជីមិញ |
| **HEIs** | Higher Educational Institutions | គ្រឹះស្ថានអប់រំឧត្តមសិក្សា |
| **NIER** | National Institute of Economic Research | វិទ្យាស្ថានជាតិសម្រាប់ការស្រាវជ្រាវសេដ្ឋកិច្ច |
| **NUOL** | National University of Laos | សាកលវិទ្យាល័យជាតិឡាវ |
| **PCs** | Partner Countries | ប្រទេសដៃគូ |
| **R&D** | Research & Development | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| **RUA** | Royal University of Agriculture | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| **UA** | University of Alicante | សាកលវិទ្យាល័យ អាលី កាន់តេ |
| **UHST** | University of Heng Samrin Thbongkhmum | សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ |
| **HUAF** | Hue University of Agriculture and Forestry | សាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហ៊ូ |

# អារម្ភកថា

ប្រទេសកម្ពុជា ឡាវ និងវៀតណាម គឺជាប្រទេសដែលងាយរងគ្រោះបំផុតនៅលើពិភពលោកចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលភាគច្រើននៃប្រជាជនរស់នៅក្នុងតំបន់ជនបទ ពឹងផ្អែកយ៉ាងខ្លាំងទៅលើជម្រកធម្មជាតិនៅមូលដ្ឋាន និងមានសមត្ថភាពតិចតួចក្នុងការទប់ទល់ជាមួយហានិភ័យទាក់ទងនឹងការប្រែប្រួលអាកាសធាតុ (គណៈកម្មការទន្លេមេគង្គ, ២០១១) ។ ព្រឹត្តិការណ៍អាកាសធាតុ ជម្រក និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ការកើនឡើងកម្រិតទឹកសមុទ្រ ការស្តុកទុកអស់។ល។ សុទ្ធតែបង្ករគ្រោះថ្នាក់ដល់ការអភិវឌ្ឍក្នុងតំបន់ហើយត្រូវការនូវដំណោះស្រាយជាការបន្សាំបែបនវានុវត្តន៍ចំគោលដៅ និងការកាត់បន្ថយ ដើម្បីប្រឈមមុខទៅនឹងការគំរាមកំហែងទាំងនេះ។

គ្រឹះស្ថានអប់រំឧត្តមសិក្សា (HEIs) អាចនាំផ្លូវទៅដល់ដំណោះស្រាយទាំងនេះតាមរយៈការអភិវឌ្ឍការស្រាវជ្រាវនិងបច្ចេកវិទ្យាប្រកបដោយគំនិតច្នៃប្រឌិតថ្មី លើការប្រែប្រួលអាកាសធាតុ ហើយបណ្តុះបណ្តាលអ្នកជំនាន់ក្រោយដែលនឹងបន្តអភិវឌ្ឍយ៉ាងមុតមាំ។ ចំពោះបញ្ហានេះ កិច្ចសហប្រតិបត្តិការរវាងអ្នកជំនាញមកពីស្ថាប័នខុសៗគ្នា និងបណ្តាប្រទេសផ្សេងៗ គឺជាគន្លឹះដ៏សំខាន់។

REACT គឺជាគម្រោងស្តីពីការកសាងសមត្ថភាពរបស់កម្មវិធី Erasmus+ នៅកម្រិតឧត្តមសិក្សាដែលកំពុងត្រូវបានបង្កើតឡើងនៅកម្ពុជា ឡាវ និងវៀតណាមចន្លោះពី ខែតុលា ឆ្នាំ២០១៦ ដល់ ខែតុលា ឆ្នាំ២០១៩ ។ គោលបំណងរួមរបស់ REACT គឺដើម្បីគាំទ្រដល់គ្រឹះស្ថានអប់រំនៅកម្ពុជា ឡាវ និងវៀតណាមក្នុងការពង្រឹងសមត្ថភាពនិងកិច្ចសហប្រតិបត្តិការតាមតំបន់របស់ខ្លួន តាមរយៈការលើកកម្ពស់ការស្រាវជ្រាវនិងការបង្កើតថ្មីប្រកបដោយប្រសិទ្ធភាពស្តីពីការប្រែប្រួលអាកាសធាតុ។ ជាក់ស្តែង REACT មានបំណងជាក់លាក់ដូចខាងក្រោម៖

(1) បង្កើនសមត្ថភាពមនុស្សនៃស្ថាប័នដៃគូក្នុងការផ្តួចផ្តើមអភិវឌ្ឍ ការគ្រប់គ្រង វាយតម្លៃ និងទាញយកផលប្រយោជន៍ R,D&I ក្នុងការប្រែប្រួលអាកាសធាតុ ក៏ដូចជាធ្វើទំនើបកម្មកម្មវិធីសិក្សាពាក់ព័ន្ធនឹងការរួមបញ្ចូលនៃ R,D&I ក្នុងការ

ប្រែប្រួលអាកាសធាតុឆ្ពោះទៅរកកម្មវិធីសិក្សាដែលផ្អែកលើសមត្ថភាពជាមូលដ្ឋាន; និង

(2) ពង្រឹងសមត្ថភាពស្ថាប័នតាមរយៈការបង្កើតបណ្តាញ REACT សម្រាប់ការស្រាវជ្រាវ និងការសិក្សាប្រកបដោយការប្រកួតប្រជែងបែបពហុវិជ្ជាជីវៈលើការប្រែប្រួលអាកាសធាតុនៅកម្រិតតំបន់ ។

ឯកសារនេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងវិភាគស៊ីជម្រៅមានលក្ខណៈប្រកដប្រជាលើការស្រាវជ្រាវនិងការអភិវឌ្ឍ (R & D) ដែលផ្តោតលើការប្រែប្រួលអាកាសធាតុ ដែលបានធ្វើឡើងនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ចំនួនបីតាមរយៈមធ្យោបាយនៃការស្ទង់មតិ និងពិភាក្សាក្រុមបែបពាក់កណ្តាលរៀបរយជាមួយអ្នកសិក្សា និស្សិត និងអ្នកពាក់ព័ន្ធខាងក្រៅផ្សេងទៀត។

# សេចក្ដីសង្ខេប

របាយការណ៍នេះបង្ហាញពីឯកសារបញ្ចប់នៃកញ្ចប់ការងារទី២ (WP2) "ការសិក្សាជាក់ស្តែង និងស្រាវជ្រាវស៊ីជម្រៅលើ R&D ក្នុងការប្រែប្រួលអាកាសធាតុនិងការសិក្សាផ្អែកលើសមត្ថភាពនៅប្រទេសដៃគូ (PCs)" នៅក្នុងក្របខ័ណ្ឌនៃគម្រោង REACT ដោយផ្តោតលើស្ថានភាព និងតម្រូវការបច្ចុប្បន្នរបស់ប្រទេសកម្ពុជា ឡាវ (ពីការគ្រប់គ្រងទៅវិធីសាស្រ្តការអនុវត្ត ការវាយតម្លៃ និងការផ្ទេរលទ្ធផលស្រាវជ្រាវ) លើការប្រែប្រួលអាកាសធាតុក៏ដូចជាការផ្តល់ និងតម្រូវការបច្ចុប្បន្ននៃប្រធានបទទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សា (HEIs) នៅក្នុងបណ្តាប្រទេសដៃគូដែលបានរៀបរាប់ខាងលើ។ គោលបំណងនៃការសិក្សានេះគឺដើម្បីកំណត់ពីសក្តានុពលនៃការរីកចម្រើនដែលជាកន្លែងអង្គភាពស្រាវជ្រាវ និងសិក្សារបស់ REACT លើការប្រែប្រួលអាកាសធាតុអាចធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ឬត្រូវការការអភិវឌ្ឍសមត្ថភាពបន្ថែមទៀត។ ទិន្នន័យនេះត្រូវបានប្រមូលតាមរយៈការស្ទង់មតិដែលមានកម្រងសំណួរចំនួនពីរដែលត្រូវបានផ្ញើទៅកាន់ HEIs នៅក្នុងប្រទេសដៃគូ និងការសម្ភាសជាក្រុម ដែលបានធ្វើឡើងជាមួយដៃគូពាក់ព័ន្ធផ្សេងៗដោយដៃគូREACTនៅតំបន់អាស៊ីអាគ្នេយ៍ក្នុងកិច្ចប្រឹងប្រែងរួម។ ជារួម មានស្ថាប័នចំនួន ២៩ និងអ្នកស្រាវជ្រាវចំនួន ៩៨រូប ត្រូវបានអង្កេតជាមួយអ្នកតំណាងសរុប ៥៣ រូប មកពីអជ្ញាធរជាតិ និងស្ថាប័នឯកជន និងអ្នកស្រាវជ្រាវចំនួន ៧១ រូប និងនិស្សិត ចំនួន ៧៧រូប មកពីសាកលវិទ្យាល័យចំនួន ៧ នៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាមដែលបានចូលរួមក្នុងការសម្ភាសនិងវគ្គផ្តោតសំខាន់ៗ។

តាមរយៈការវាយតម្លៃបានបង្ហាញថា ការផ្តល់កម្មវិធីសិក្សាអំពីការប្រែប្រួលអាកាសធាតុ (CC) គឺមានកំណត់ណាស់ ខណៈពេលដែលការបែងចែកសម្ភារបង្រៀនដែលពាក់ព័ន្ធគឺមានច្រើនជាងពាក់កណ្តាលក្នុងចំណោមស្ថាប័នចំនួន ២៩ ដែលបានចូលរួមក្នុងការអង្កេតផ្តល់ជូននូវការបង្រៀនជាក់លាក់និងវគ្គសិក្សាដែលទាក់ទងទៅនឹងវិស័យនេះ។ មានត្រឹមតែ ៨ ស្ថាប័នក្នុងចំណោមស្ថាប័នទាំងអស់ដែលឆ្លើយតបកម្រងសំណួរ មានផ្តល់នូវថ្នាក់បណ្ឌិតអំពីការប្រែប្រួលអាកាសធាតុ ហើយក្នុងចំណោមនោះមាន៧ស្ថាប័នបានបំពេញកម្មវិធីសិក្សាដែលមានវគ្គសិក្សាសម្រាប់ការបង្កើនជំនាញស្រាវជ្រាវរបស់សិស្សដែលបញ្ចប់ការសិក្សា។ ការស្រាវជ្រាវអំពីផលប៉ះពាល់នៃ CC លើវិស័យផ្សេងៗគ្នានៃសេដ្ឋកិច្ចជាតិកម្ពុជា

ឡាវ និងវៀតណាម គឺមានលក្ខណៈទូលំទូលាយ ហើយវិធីសាស្រ្តចម្រុះវិស័យបានប្រើដោយអ្នកស្រាវជ្រាវមួយភាគបីដើម្បីស្រាវជ្រាវលើប្រធានបទទាំងនេះ។ ការស្រាវជ្រាវភាគច្រើននេះ បានផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយអន្តរជាតិ និងមូលនិធិនានាខណៈដែលវិស័យឯកជននៅតែជាចំណែកតូចមួយក្នុងការរួមចំណែកដល់ R & D ទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ។

ការសម្ភាសជាមួយតំណាងពីអាជ្ញាធរជាតិ និងវិស័យឯកជន បានបង្ហាញថាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុត្រូវបានចាត់ទុកថាជាបញ្ហាពិតប្រាកដ ហើយផលវិបាកបានប៉ះពាល់ដល់វិស័យកសិកម្ម ទេសចរណ៍ និងវិស័យព្រៃឈើដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជីវភាពរបស់កសិករខ្នាតតូច ដែលធ្វើកសិកម្មសម្រាប់ ត្រឹមតែចិញ្ចឹមជីវិត។ ទឹកជំនន់ធ្ងន់ធ្ងរ ភាពរាំងស្ងួតរយៈពេលវែង និងការហូរចូលទឹកប្រៃនៅតំបន់ឆ្នេរ គឺជាការគំរាមកំហែងចម្បងចំពោះធនធានទឹកស្អាត និងការដាំដុះដំណាំដ៏សំខាន់សម្រាប់ផលិតកម្មកសិកម្មដែលតំណាងឱ្យយ៉ាងហោចណាស់ ៦០% នៃសេដ្ឋកិច្ចជាតិនៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម។ ការសហការរវាងរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវនានាក្នុងការបង្កើតយុទ្ធសាស្រ្តបន្សាំនិងការកាត់បន្ថយប្រកបដោយប្រសិទ្ធភាព គឺមានភាពទន់ ខ្សោយហើយថវិកាជាតិសម្រាប់ការស្រាវជ្រាវលើការប្រែប្រួលអាកាសធាតុនៅមានកំណត់។ ការបង្កើតក្រុមស្រាវជ្រាវ ចម្រុះនិងការចែករំលែកទិន្នន័យ គឺភាគច្រើនអាស្រ័យលើទំនាក់ទំនងផ្ទាល់ខ្លួនដោយសារតែមានការខ្វះខាតបណ្តាញ ដ៏រឹងមាំរវាងគ្រឹះស្ថានឧត្តមសិក្សា។

ទិដ្ឋភាពសំខាន់ដែលលេចចេញពីការសម្ភាសក្រុមពិភាក្សា "អ្នកសិក្សា" និង "និស្សិត" គឺជាការពិតដែល ថាទោះជានៅក្នុងករណីមានវគ្គសិក្សាផ្តល់អំពីការប្រែប្រួលអាកាសធាតុសម្ភារៈបង្រៀនត្រូវបានចាត់ទុកថានៅមិន ទាន់ច្បាស់លាស់ (សេរីៗ) ហើយវិធីសាស្រ្តបង្រៀន និងខ្លឹមសារមេរៀននៅមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំឲ្យ និស្សិតបញ្ចប់ការសិក្សាអាចដើរតួនាទីសកម្មក្នុងវិស័យស្រាវជ្រាវ ឬក្នុងទីផ្សារការងារ។ ទាក់ទងនឹងលទ្ធភាពទទួល បានវគ្គសិក្សា និងកម្រិតសញ្ញាបត្រដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ បានបង្ហាញថាមិនមានឱកាស ទទួលបានអាហារូបករណ៍ណាមួយដែលពាក់ព័ន្ធប្រធានបទនេះទេ។

ការសិក្សានេះគឺជាចំណុចសំខាន់មួយសម្រាប់ការយល់ដឹងឱ្យកាន់តែប្រសើរអំពីស្ថានភាព និងតម្រូវការដើម្បីបង្កើនសមត្ថភាព R&D លើប្រធានបទការប្រែប្រួលអាកាសធាតុនៅកម្ពុជា ឡាវ និងវៀតណាម។ ដោយយោងទៅលើលទ្ធផលនៃការអង្កេតនេះ មានទិដ្ឋភាពសំខាន់ៗបីដែលអង្គភាព REACT នឹងត្រូវផ្តោតដោយការយកចិត្តទុកដាក់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន៖

- សម្របសម្រួល និងលើកទឹកចិត្តឱ្យមានកិច្ចសហការរវាងគ្រឹះស្ថានឧត្តមសិក្សា និងការិយាល័យរដ្ឋាភិបាល និងភ្នាក់ងារនានាដែលផ្តោតទៅលើការស្រាវជ្រាវ និងការបង្កើតយុទ្ធសាស្ត្រសបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។
- ការសម្របសម្រួល និងធ្វើស្តង់ដារកម្មលើនីតិវិធីនៃការចែករំលែកទិន្នន័យ ដើម្បីលើកកម្ពស់បណ្តាញរវាង គ្រឹះស្ថានឧត្តមសិក្សា និងការបង្កើតប្រព័ន្ធទិន្នន័យនៅក្នុងស្ថាប័នស្រាវជ្រាវនីមួយៗ។
- លើកកម្ពស់និស្សិតហាត់ការ និងការសិក្សាករណីជាក់ស្តែងដើម្បីគាំទ្រដល់ភាពជាដៃគូរវាងវិស័យឯកជន និងសាកលវិទ្យាល័យដើម្បីលើកកម្ពស់ជំនាញវិជ្ជាជីវៈរបស់និស្សិត និងបង្កើនចំណាប់អារម្មណ៍ដល់វិស័យ ឯកជនក្នុងការស្រាវជ្រាវ។

# សេចក្តីផ្តើម

## គោលបំណងរបស់របាយការណ៍

របាយការណ៍នេះបង្ហាញពីការវិភាគស៊ីជម្រៅអំពីស្ថានភាព និងតម្រូវការបច្ចុប្បន្ននៅប្រទេសកម្ពុជា ឡាវ និង វៀតណាមទាក់ទងនឹងការស្រាវជ្រាវ និងការអភិវឌ្ឍលើប្រែប្រួលអាកាសធាតុ ក៏ដូចជាការផ្តល់ជូននូវតម្រូវការថ្មីៗលើប្រធានបទទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងស្ថាប័នអប់រំថ្នាក់ឧត្តមសិក្សា។ នៅក្នុងគម្រោង REACT ក្រោមកម្មវិធី Erasmus+ ការប្រែប្រួលអាកាសធាតុត្រូវបានគេចាត់ទុកថាជាវិស័យពហុជំនាញដែលមានឥទ្ធិពលលើវិស័យជាច្រើនដូចជា៖ វិស័យកសិកម្ម រុក្ខាប្រមាញ់ ទេសចរណ៍ និងសេដ្ឋកិច្ច។ លើសពីនេះ វាបានកំណត់នូវវិស័យនៃការរីកចំរើនដ៏មានសក្តានុពលដែលអង្គភាព REACT
អាចធ្វើកិច្ចអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ឬត្រូវការការអភិវឌ្ឍសមត្ថភាពបន្ថែមទៀត។ របាយការណ៍នេះ គឺជាឯកសារបញ្ចប់នៃកញ្ចប់ការងារ WP2 របស់គម្រោង REACT "ការសិក្សាជាក់ស្តែង និងស្រាវជ្រាវស៊ីជម្រៅលើ R&D ក្នុងការប្រែប្រួលអាកាសធាតុ និងការសិក្សាផ្អែកលើសមត្ថភាពនៅប្រទេសដៃគូ (PCs)" ដែលនឹងដើរតួជាទិន្នន័យដើម (Baseline) សម្រាប់ជំហានបន្ទាប់នៃគម្រោងដោយកំណត់នូវប្រធានបទពាក់ព័ន្ធសម្រាប់កម្មវិធីវគ្គបណ្តុះបណ្តាល និងសម្រាប់បង្កើតបណ្តាញ REACT អន្តរជាតិដែលមានលទ្ធភាពសម្របសម្រួលដល់ការផ្លាស់ប្តូរព័ត៌មាននៅក្នុងប្រទេសនិងជាមួយដៃគូដទៃទៀតនៅអាស៊ីអាគ្នេយ៍ និងណែនាំដល់គ្រឹះស្ថានអប់រំក្នុងការស្វែងរកហិរញ្ញប្បទានសម្រាប់ការងារស្រាវជ្រាវ។

## មាតិកា និងរចនាសម្ព័ន្ធនៃរបាយការណ៍

ទិន្នន័យដែលប្រមូលបានត្រូវបានបង្ហាញដូចខាងក្រោម៖ នៅក្នុងផ្នែកទី១ ទិន្នន័យដែលផ្តល់ព័ត៌មាននៅ ថ្នាក់ជាតិពិពណ៌នាអំពីស្ថានភាពរួមនៃការស្រាវជ្រាវពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ នៃគ្រឹះស្ថានឧត្តមសិក្សានៅ ក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាមត្រូវបានបង្ហាញ។ ផ្នែកទី២ គឺជាការវិភាគលើទិន្នន័យគុណភាពដែលប្រមូល បានតាមរយៈការសម្ភាសជាក្រុមដែលចែកចេញជាពីរគឺ"អ្នកស្រាវជ្រាវនិងសិស្ស-និស្សិត"និងក្រុមស្ថាប័ន

ខាងក្រៅពីរទៀតគឺ "វិស័យឯកជន និងអាជ្ញាធរជាតិ" ដែលត្រូវបានបែងចែកតាមប្រទេសតាមលំដាប់លំដោយអក្សររួមមានប្រទេសកម្ពុជា ឡាវ និងវៀតណាម។ អនុសាសន៍និងយុទ្ធសាស្ត្រសម្រាប់កសាងនិងពង្រឹងសមត្ថភាព R & D តាមរយៈអង្គភាព REACT ត្រូវបានផ្តល់ឱ្យនៅក្នុងផ្នែកខាងក្រោយដោយរួមបញ្ចូលជាមួយនឹងការកត់សម្គាល់ចុងក្រោយអំពីស្ថានភាព R & D លើការប្រែប្រួលអាកាសធាតុនិងឧបសគ្គចម្បងៗចំពោះការរីកចម្រើនរបស់ខ្លួន និងការកើតផលប៉ះពាល់លើគោលនយោបាយជាតិ។

ការប្រមូលទិន្នន័យត្រូវបានអនុវត្តន៍ដោយដៃគូនៅអាស៊ីអាគ្នេយ៍នៃគម្រោង ក្រោមការត្រួតពិនិត្យរបស់ក្រុម ការងារពីសាកលវិទ្យាល័យ Albert-Ludwig Universität of Freiburg (ប្រទេសអាល្លឺម៉ង់)។ *"របាយការណ៍ស្តីពីដំណើរទស្សនកិច្ចសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានៅសហភាពអឺរ៉ុប"* (D2.1.1) មុននេះ ត្រូវបានប្រើជាទិន្នន័យដើមសម្រាប់ការធ្វើសេចក្តីព្រាងបញ្ជីសំណួរសម្រាប់ការសម្ភាសជាក្រុមពាក់កណ្តាលរៀបរយ និងកម្រងសំណួរចំនួនពីរដែលមានចម្លើយបើកខ្លីៗ។ កម្រងសំណួរដំបូងមានបំណងប្រមូលទិន្នន័យអំពីស្ថានភាពអំពីប្រធានបទ CC ដែលមាន នៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សាខណៈដែលកម្រងសំណួរទី ២ បានប្រមូលទិន្នន័យ ពីការធ្វើបច្ចុប្បន្នភាព ឬបញ្ចប់ការស្រាវជ្រាវក្នុងវិស័យការប្រែប្រួលអាកាសធាតុពីស្ថាប័នស្រាវជ្រាវសាធារណៈនិងឯកជននៅក្នុងប្រទេសទាំងបី។




រូបភាពទី ១៖ អ្នកចូលរួមក្នុងក្រុមក្រុមពិភាក្សា "អាជ្ញាធរ និងវិស័យឯកជន" នៅសកលវិទ្យាល័យកសិកម្មនិងព្រៃឈើហ៊ូ (ប្រទេសវៀតណាម)

ខណៈដែលកម្រងសំណួរដែលមានគោលបំណង ដើម្បីវាយតម្លៃអ្វីដែលជាការផ្តោតសំខាន់នៃការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុដោយប្រើវិធីសាស្ត្របរិមាណ ការសម្ភាសជាក្រុមគឺដើម្បីស្វែងយល់ស៊ីជម្រៅលើ ទិដ្ឋភាពជាក់ស្តែង និងសង្គមនៃការស្រាវជ្រាវរួមជាមួយនឹងផលប៉ះពាល់នៃការស្រាវជ្រាវទាំងនោះទៅលើគោលនយោបាយជាតិ និងវិស័យឯកជនទៅលើការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។ ដូច្នេះសម្រាប់ក្រុមខាងក្រៅ ពួកគេមានបីផ្នែក គឺមួយទាក់ទងនឹងការយល់ឃើញ និងការយល់ដឹងអំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅលើ វិស័យផ្សេងៗដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចជាតិ។ មួយវិញទៀត សមត្ថភាពបច្ចុប្បន្នរបស់ស្ថាប័នស្រាវជ្រាវធនធាន មនុស្សនិងការរៀបចំរបស់ពួកគេដើម្បីបំពេញតម្រូវការនៃផ្នែកឯកជន និងផ្នែកមួយចុងក្រោយត្រូវបានធ្វើឡើងដើម្បី កំណត់អត្តសញ្ញាណយន្តការអនុវត្តន៍គោលនយោបាយដែលខិតខំប្រឹងប្រែង និងប្រភពសំខាន់នៃការផ្តល់ហិរញ្ញវត្ថុ សម្រាប់ R&D ជាទូទៅនិងជាពិសេសនៅក្នុងវិស័យការប្រែប្រួលអាកាសធាតុ។ សំណួរផ្សេងៗគ្នាត្រូវបានរៀបចំ ឡើងសម្រាប់ក្រុមពិភាក្សា "សិស្សនិស្សិត" និង "អ្នកស្រាវជ្រាវ" ដើម្បីវាយតម្លៃវិធីសាស្ត្របង្រៀនភាពអាចទទួលបានមុខវិជ្ជាសិក្សា កម្មវិធីសិក្សា និងភាពអាចអនុវត្តន៍បាននូវអ្វីដែលបានរៀនពីមុខវិជ្ជាឬកម្មវិធីសិក្សាទាំងនោះ សម្រាប់ការងារអនាគត។ បញ្ជីឈ្មោះស្ថាប័នដែលបានចូលរួមនៅក្នុងក្រុមពិភាក្សាផ្សេងៗគ្នា និងផ្នែកចំណេះដឹង សម្រាប់សិស្ស និងអ្នកស្រាវជ្រាវអាចរកបាននៅក្នុងតារាងទី ៥-៧ នៅក្នុងឧបសម្ព័ន្ធ។

សេចក្តីណែនាំលម្អិតត្រូវបានផ្តល់ជូនដល់ដៃគូតាមរយៈរបាយការណ៍៖ *"គោលការណ៍ណែនាំពីការប្រមូល ទិន្នន័យ"* (D2.2.1) រួមទាំងវិធីសាស្ត្រការស្ទង់មតិ ការសម្ភាស និងវិធីសាស្ត្រវិភាគ។ ឯកសារនេះអាចរកបាន ដើម្បីពិគ្រោះលើការស្នើសុំដើម្បីឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីការអង្កេតបច្ចុប្បន្ននិងដំណើរការប្រមូលទិន្នន័យ។

# ការវិភាគលទ្ធផលពីបញ្ជីសំណួរ

## លទ្ធផលពីបញ្ជីសំណួរ "ការប្រែប្រួលអាកាសធាតុនៅតាមគ្រឹះស្ថានអប់រំ"

ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអាស៊ីរបស់យើង យើងបានឈានដល់ចំនួនសរុប ២៩ ស្ថាប័នមកពីប្រទេសវៀតណាម កម្ពុជា និងឡាវដែលបានចូលរួមក្នុងការអង្កេតនេះ។ ការប្រមូលទិន្នន័យពីស្ថាប័នមិនមែនជាដៃគូគម្រោង គឺជាបញ្ហាប្រឈមច្រើន។




ក្រាហ្វិច 1៖ ចំនួនស្ថាប័នដែលបានចូលរួមក្នុងការស្ទង់មតិ

ពួកគេបានឆ្លើយ ៦សំណួរផ្សេងៗគ្នា។ នៅផ្នែកខាងក្រោមចម្លើយសម្រាប់សំណួរទាំងនេះត្រូវបានពិភាក្សាលម្អិត។

### a. គ្រឹះស្ថានអប់រំដែលមានផ្តល់ការសិក្សាកម្រិតសញ្ញាប័ត្រ ឬវគ្គសិក្សាអំពីការប្រែប្រួលអាកាសធាតុ




ក្រាហ្វិច 2៖ ចំនួនវិទ្យាស្ថានដែលមានផ្តល់ការសិក្សាកម្រិតសញ្ញាប័ត្រ ឬវគ្គសិក្សាអំពីការប្រែប្រួលអាកាសធាតុ

សំណួរជាច្រើនបានសួរដើម្បីយល់ដឹងពីភាពពាក់ព័ន្ធនៃ "ការប្រែប្រួលអាកាសធាតុ" នៅក្នុងកម្មវិធីសិក្សា។ យោងទៅតាមទិន្នន័យដែលប្រមូលបានពីស្ថាប័ននានា ទំនងជាមានវគ្គសិក្សាដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងកម្រិតខុសគ្នា។ លទ្ធផលទទួលបានពីស្ថាប័នចំនួន ២៩ ដែលបានចូលរួមក្នុងការអង្កេតនេះ មាន ២០ ស្ថាប័នបានផ្តល់វគ្គសិក្សាអំពីការប្រែប្រួលអាកាសធាតុ។ មានតែស្ថាប័នចំនួន ២ ប៉ុណ្ណោះនៅក្នុងប្រទេសកម្ពុជា និងឡាវដែលមានផ្តល់នូវកម្មវិធីសិក្សាអំពីការប្រែប្រួលអាកាសធាតុនៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់។ នៅសាកលវិទ្យាល័យជាតិឡាវ មានកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អំពីការប្រែប្រួលអាកាសធាតុលើសពីមួយ គឺថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងព្រៃឈើសម្រាប់ការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកការប្រែប្រួលអាកាសធាតុសម្រាប់ការអភិវឌ្ឍជនបទ។ លើសពីនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅកម្ពុជា បានចាប់ផ្តើមថ្នាក់បរិញ្ញាបត្រ ជាន់ខ្ពស់ នៅឆ្នាំ ២០១៧ ដែលមានឈ្មោះថា "បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រការប្រែប្រួលអាកាសធាតុ" ។

នៅពេលយើងគិតតែអំពីកម្រិតសញ្ញាបត្រនៃការប្រែប្រួលអាកាសធាតុនោះ គ្មានវិទ្យាស្ថានណាដែលផ្តល់ សញ្ញាប័ត្របរិញ្ញាបត្រនៃការប្រែប្រួលអាកាសធាតុក្រៅពីមហាវិទ្យាល័យកសិកម្ម និងធនធានព្រៃឈើនៅសាកល វិទ្យាល័យសូផាន់នូវង្ស (SU) ទេ។ ទោះយ៉ាងណា ឈ្មោះនៃកម្មវិធីនេះមិនត្រូវបានផ្តល់ជូននៅក្នុងការអង្កេតនេះទេ។ យ៉ាងណាក៏ដោយមានសញ្ញាប័ត្របរិញ្ញាបត្រដែលត្រូវបានកត់សម្គាល់ដោយស្ថាប័នមកពីវៀតណាមនិងឡាវ ដូចជា "សេដ្ឋកិច្ចបរិស្ថាន" "វិទ្យាសាស្ត្របរិស្ថាន" "បរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ" ជាសញ្ញាប័ត្រដែលទាក់ទង នឹងការប្រែប្រួលអាកាសធាតុ។ វគ្គសិក្សាដែលមាននៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បរិញ្ញាបត្រផ្សេងៗត្រូវបាន ចុះបញ្ជីដូចខាងក្រោម។ វគ្គសិក្សាមួយចំនួនត្រូវបានផ្តល់ជូនដោយស្ថាប័នលើសពីមួយ។

តារាង 1៖ មុខវិជ្ជាសិក្សាដែលផ្តល់ដោយស្ថាប័នស្តីពីការប្រែប្រួលអាកាសធាតុ

| កម្ពុជា | ឡាវ | វៀតណាម |
|---|---|---|
| សេចក្តីផ្តើមពីការប្រែប្រួលអាកាសធាតុ | ការប្រែប្រួលអាកាសធាតុនិងជីវចម្រុះ | ការប្រែប្រួលអាកាសធាតុ |
| ការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ | ការវាស់វែងនិងត្រួតពិនិត្យកាបូននិងអភិបាលកិច្ចព្រៃឈើ | ការវាយតម្លៃផលប៉ះពាល់និងការបន្សាំនៃការប្រែប្រួលអាកាសធាតុក្រោមភូមិសាស្ត្របរិស្ថានវិទ្យា |
| ការវាយតម្លៃផលប៉ះពាល់បរិស្ថាននៅក្នុងកម្មវិធីផលផលនិងព្រៃឈើ | វគ្គសិក្សាទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងមុខវិជ្ជាសេដ្ឋកិច្ចបរិស្ថាន | ការប្រែប្រួលអាកាសធាតុ និងការបន្សាំ |
| | | ការគ្រប់គ្រងធនធានធម្មជាតិអាស្រ័យលើសហគមន៍ |
| | | ច្បាប់បរិស្ថាននិងគោលនយោបាយ |
| | | ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន |
| | | ការវាយតម្លៃផលប៉ះពាល់ |

| | | |
|---|---|---|
| | | បរិស្ថាន និងសង្គមក្នុងវិស័យព្រៃឈើ |
| | | ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព |
| | | សង្គមវិទ្យាទីក្រុង សង្គមវិទ្យាជនបទ ទេសចរណ៍ កសិកម្មទេសចរណ៍ |
| | | ការគ្រប់គ្រងគ្រោះមហន្តរាយ ការកាត់បន្ថយ និងការបន្សាំការប្រែប្រួលអាកាសធាតុ |
| | | ការគ្រប់គ្រងដី |
| | | ការអភិវឌ្ឍប្រកបដោយនិរន្តរភាព |
| | | ការគ្រប់គ្រងធនធានធម្មជាតិ |

## ៦. ស្ថាប័ននានាដែលផ្ដល់សម្ភារបង្រៀនឬព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ




ក្រាហ្វិច ៣៖ ស្ថាប័ននានាដែលផ្ដល់សម្ភារបង្រៀនឬព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

ជារួម យ៉ាងហោចណាស់ក៏មានពាក់កណ្តាលនៃចំនួនស្ថាប័នដែលបានចូលរួមក្នុងការសិក្សានេះផ្តល់ជា សម្ភារៈបង្រៀន ឬព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុដល់សិស្សរបស់ពួកគេ។ សម្ភារៈដែលផ្តល់ដោយ ស្ថាប័ននានានៅក្នុងប្រទេសវៀតណាមភាគច្រើន គឺសម្ភារបង្រៀន និងសៀវភៅសម្រាប់វគ្គសិក្សាស្តីពីការប្រែប្រួលអាកាសធាតុ ។ នៅ NUOL ពួកគេផ្តល់សៀវភៅណែនាំអំពី រ៉េដបូក (REDD+) សម្រាប់បុគ្គលិកបច្ចេកទេស និងប្រជាជននៅក្នុងប្រទេសឡាវ ចម្លងផែនទី ឬឯកសារការប្រែប្រួលអាកាសធាតុបន្ថែមទៅលើសៀវភៅយោងសម្រាប់វគ្គសិក្សា។ នៅក្នុងប្រទេសកម្ពុជាមានឯកសារបទបង្ហាញស្លាយ Power Point និងវីដេអូដែលទាក់ទងទៅនឹងមុខវិជ្ជាទាំងនោះត្រូវបានផ្តល់ឱ្យសិស្ស។ លើសពីនេះ នៅស្ថាប័នមួយចំនួនសិស្សត្រូវបានឱ្យចូលអនុវត្តន៍នៅក្នុងមន្ទីរពិសោធន៍មួយចំនួននិងបន្ទប់កុំព្យូទ័រក្នុងកំឡុងពេលសិក្សា។ ជាពិសេសសាកលវិទ្យាល័យបាត់ដំបងក្នុងប្រទេសកម្ពុជាក្នុងការសិក្សាជាក់ស្តែងមួយស្តីអំពីផលប៉ះពាល់កំដៅលើត្រី ប្រព័ន្ធប្រព័ន្ធប្រដាប់បម្លែងធ្យូងថ្ម ប្រដាប់ស្ទង់បង្ហូរទឹក ជាដើមត្រូវបានប្រើប្រាស់។

### c. ស្ថាប័នដែលមានផ្តល់នូវកម្មវិធីថ្នាក់បណ្ឌិតស្តីពីប្រធានបទការប្រែប្រួលអាកាសធាតុ




ក្រាហ្វិច 4៖ ស្ថាប័នមានដែលផ្តល់នូវកម្មវិធីថ្នាក់បណ្ឌិតស្តីពីប្រធានបទការប្រែប្រួលអាកាសធាតុ

ស្ថាប័នដែលផ្តល់ការសិក្សាថ្នាក់បណ្ឌិតអំពីការប្រែប្រួលអាកាសធាតុគឺនៅមានកម្រិតទាប។ មានតែស្ថាប័ន ចំនួន ៨ ប៉ុណ្ណោះដែលផ្តល់ការសិក្សាកម្រិតនេះលើប្រធានបទពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ប្រធានបទ ដែលបានលើកឡើងរួមមាន៖ បរិស្ថានដី និងទឹក ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងនៅតំបន់ជួរភ្នំ សម្ភាពស្រូបយកឧស្ម័ន

កាបូនឌីអុកស៊ីតចេញពីព្រៃកៅស៊ូដែលបានដាំនៅចំការ Tan Hung ស្រុក Ben Cat ខេត្ត Binh Duong ការប្រើប្រាស់ទឹកសម្រាប់ដាំកាហ្វេនៅដាកណុង ការផ្លាស់ប្តូរបរិស្ថាន និងការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋនៅខេត្ត An Giang ការមិនអាចកកើតឡើងវិញ និងកកើតឡើងវិញក្នុងការគ្រប់គ្រងព្រៃឈើ។

### d. កម្មវិធីគុណវុឌ្ឍដើម្បីពង្រឹងជំនាញស្រាវជ្រាវឬថ្នាក់ត្រៀមសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់រឺថ្នាក់បណ្ឌិត




ក្រាហ្វិច 5៖ ចំនួនស្ថាប័នដែលមានផ្តល់កម្មវិធីគុណវុឌ្ឍ

ក្នុងចំណោមស្ថាប័នទាំង ២៩ មានតែស្ថាប័នចំនួន ៧ ប៉ុណ្ណោះដែលមានផ្តល់កម្មវិធីជំនាញពាក់ព័ន្ធនឹងការស្រាវជ្រាវ។ កម្មវិធីទាំងនេះមានដូចជា៖ មុខវិជ្ជាជំនាញសម្រាប់ការសរសេរគម្រោងអន្តរជាតិ ការគ្រប់គ្រងគម្រោង ក្នុងកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ វគ្គបណ្តុះបណ្តាលក្នុងការកសាងសមត្ថភាពលើការអភិវឌ្ឍធនធានមនុស្សក្នុងប្រទេស វគ្គបណ្តុះណ្តាលក្នុងការវិភាគទិន្នន័យ ការអភិវឌ្ឍគម្រោងសំណើរស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវលើវិទ្យាសាស្ត្រសង្គម ការសរសេរបែបវិទ្យាសាស្ត្រ។ លើសពីនេះនៅតាមស្ថាប័នមួយចំនួន ជំនាញស្រាវជ្រាវត្រូវបានដាក់ បញ្ចូលក្នុងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ការប្រែប្រួលអាកាសធាតុ។ នៅកម្ពុជា មានគ្រឹះស្ថានអប់រំមួយដែលផ្តល់វគ្គសិក្សាភាសាអង់គ្លេសបែបវិទ្យាសាស្ត្រសម្រាប់កសិកម្ម ខណៈដែលមានគ្រឹះស្ថានអប់រំមួយផ្សេងទៀតមានផ្តល់នូវវគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តភាព និងប្រព័ន្ធគាំទ្រការសម្រេចចិត្ត បន្ថែមពីលើការគ្រប់គ្រងគម្រោង និងជំនាញស្រាវជ្រាវ។

## e. ស្ថាប័នចូលរួមក្នុងតួអង្គស្រាវជ្រាវដែលមានលក្ខណៈអន្តរវិស័យលើប្រធានបទពាក់ព័ន្ធ CC




ក្រាហ្វិច 6៖ ចំនួនស្ថាប័នចូលរួមក្នុងតួអង្គស្រាវជ្រាវដែលមានលក្ខណៈអន្តរវិស័យ និងចំនួននៃការស្រាវជ្រាវដែលបានអនុវត្តន៍

ស្ថាប័នដែលបានចូលរួមក្នុងការអង្កេតមានចំនួន ១៦ស្ថាប័ន បានចូលរួមក្នុងគម្រោងស្រាវជ្រាវមួយឬច្រើនជាងនេះដែលមានលក្ខណៈអន្តរវិស័យ។ នៅក្នុងស្ថាប័នទាំង១៦ នោះមានគម្រោងស្រាវជ្រាវចំនួន ៣៣ផ្សេង គ្នាត្រូវបានអនុវត្តន៍ ឬកំពុងអនុវត្តន៍។ ប្រធានបទគម្រោង ដៃគូ និងមូលនិធិគម្រោងអាចរកបានក្នុងឧបសម្ព័ន្ធ (តារាង ១)។

## លទ្ធផលពីបញ្ជីសំណួរ "ការស្រាវជ្រាវក្នុងការប្រែប្រួលអាកាសធាតុ"

ដៃគូគម្រោង REACT នៅកម្ពុជា ឡាវ និងវៀតណាមបានប្រមូលចម្លើយចំពោះសំណួរ "ការស្រាវជ្រាវ ក្នុងការប្រែប្រួលអាកាសធាតុ" ពីអ្នកស្រាវជ្រាងចំនួន ៩៨រូប ដែលកំពុងអនុវត្តន៍ការស្រាវជ្រាវនៅក្នុងស្ថាប័នចំនួន ២៤ ផ្សេងគ្នា។




ក្រាហ្វិច 7៖ ចំនួនស្ថាប័នចូលរួម និងអ្នកស្រាវជ្រាវ

## a. អ្នកចូលរួមដែលបានអនុវត្តន៍ការស្រាវជ្រាវក្នុងការប្រែប្រួលអាកាសធាតុ

ពីអ្នកចូលរួមទាំងអស់ មានអ្នកស្រាវជ្រាវច្រើនជាងពាក់កណ្តាលបាននិងកំពុងអនុវត្តន៍ការស្រាវជ្រាវក្នុងវិស័យនានាពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។




ក្រាហ្វិច 8៖ ចំនួនអ្នកស្រាវជ្រាវដែលអនុវត្តន៍ និងមិនអនុវត្តន៍ការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ

ផ្នែកស្រាវជ្រាវចម្បងនៃអ្នកស្រាវជ្រាវជិត ៣៥% ដែលបានអនុវត្តន៍ការស្រាវជ្រាវពាក់ព័ន្ធការប្រែប្រួល អាកាសធាតុគឺការប្រែប្រួលអាកាសធាតុ។ ចំនួននេះមានកម្រិតប្រហែលគ្នាក្នុងប្រទេសទាំងបី។ ទោះបីជាយ៉ាងណា ចំណុចផ្ដោតសំខាន់នៃការស្រាវជ្រាវមានភាពខុសគ្នា។ ឧទាហរណ៍ អ្នកស្រាវជ្រាវម្នាក់ពីសាកលវិទ្យាល័យ កាន់ ធឺ នៅវៀតណាមផ្ដោតលើឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើតំបន់ដីសណ្ដទន្លេមេគង្គ ខណៈដែលអ្នកស្រាវជ្រាវម្នាក់ទៀតមកសាកលវិទ្យាល័យដូចគ្នាផ្ដោតលើឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើទេសចរណ៍។ អ្នកស្រាវជ្រាវពីដៃគូ REACT នៅឡាវ (NIER និង NUOL) ផ្ដោតលើបញ្ហាពាក់ព័ន្ធសេដ្ឋកិច្ចដូចជាការលូតលាស់ បៃតង ឬការអភិវឌ្ឍសេដ្ឋកិច្ចនិងបរិស្ថាន។ ប្រធានបទសំខាន់មួយនៃអ្នកស្រាវជ្រាវឯករាជម្នាក់ពីកម្ពុជាក៏ផ្ដោតលើទន្លេមេគង្គផងដែរ នៅខណៈដែលអ្នកស្រាវជ្រាវម្នាក់ផ្សេងទៀតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកំពុងធ្វើការលើការអភិវឌ្ឍជម្រើសបន្សាំសម្រាប់សហគមន៍កសិកម្មដែលមិនត្រឹមតែនៅក្នុងប្រទេសកម្ពុជានោះទេ តែក៏មាននៅប្រទេសឡាវ ឥណ្ឌា និងបង់ក្លាដេសផងដែល។

អ្នកចូលរួមជាច្រើនដែលកំពុងធ្វើការលើប្រធានបទពាក់ព័ន្ធការប្រែប្រួលអាកាសធាតុមានការបោះពុម្ពឯកសារ លើសពីមួយ។

សម្រាប់ប្រទេសទាំងបីផ្នែកជាច្រើននៃការប្រែប្រួលអាកាសធាតុត្រូវបានគ្របដណ្ដប់។ នេះរាប់ចាប់ពី"ប្រព័ន្ធព័ត៌មានភូមិសាស្រ្ត (GIS), ការសិក្សារូបថតលំហអាកាស (Remote sensing) និងការគណនាម៉ូដែលរហូតដល់ការធ្វើផែនទីហានិភ័យទឹកជំនន់ដោយសារកំណើននីវ៉ូទឹកសមុទ្រ" ដល់ "ការចូលរួមរបស់ប្រជាជនក្នុងការការពារធនធានធម្មជាតិ" ដែលប្រធានបទវិទ្យាសាស្រ្តសង្គម និងធម្មជាតិជាច្រើនដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុគឺកំពុងស្ថិតក្នុងការស្រាវជ្រាវនៅក្នុងប្រទេសទាំងបី។ ស្ថាប័នស្រាវជ្រាវវិស័យសំខាន់ដែលមានអ្នកស្រាវជ្រាវទាក់ទងនឹងប្រធានបទស្រាវជ្រាវដែលបានអនុវត្តន៍អាចរកបាននៅក្នុងតារាង ២ ក្នុងឧបសម្ព័ន្ធ។

## ង. អ្នកចូលរួមដែលសហការជាមួយដៃគូអន្តរជាតិ និងស្ថាប័នឯកជន

យោងតាមចម្លើយរបស់អ្នកស្រាវជ្រាវដែលបានចូលរួម ជាទូទៅកិច្ចសហការជាមួយស្ថាប័នឯកជនហាក់មានលក្ខណៈសាមញ្ញច្រើន។




ក្រាហ្វិច ៩៖ អ្នកស្រាវជ្រាវសហការជាមួយដៃគូអន្តរជាតិ និងស្ថាប័នឯកជន

ការសិក្សាស្រាវជ្រាវក្នុងប្រទេសទាំងបីនេះ អ្នកស្រាវជ្រាវកំពុងធ្វើការសិក្សាពីការប្រែប្រួលអាកាសធាតុពាក់ព័ន្ធ។ ការស្រាវជ្រាវផ្សេងៗហាក់មានកិច្ចសហការច្រើនជាងជាមួយស្ថាប័នអន្តរជាតិ បើប្រៀបធៀបជាមួយអ្នកសិក្សាស្រាវជ្រាវដូចគ្នាដែលមិនបានចូលរួមនៅក្នុងជំនាញពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ (ក្រាហ្វិច ១០)។ សម្រាប់ប្រទេសទាំងអស់មានអ្នកវិទ្យាសាស្ត្រប្រហែល ៨០% ដែលបានសិក្សាស្រាវជ្រាវពីការប្រែប្រួលអាកាសធាតុ

ហើយបាននឹងកំពុងអនុវត្តន៍ការងាររួមគ្នាជាមួយស្ថាប័នអន្តរជាតិ។ ផ្ទុយទៅវិញ នេះគ្រាន់តែជាករណីសិក្សាដែលមានអ្នកវិទ្យាសាស្ត្រតិចជាង ៣៧% ដែលមិនបានធ្វើការងារពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដោយមិនសហការជាមួយស្ថាប័នអន្តរជាតិ។ បន្ថែមពីនេះទៀត នៅក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម អ្នកស្រាវជ្រាវដែលធ្វើការសិក្សាពី

ការប្រែប្រួលអាកាសធាតុបានសហការរួមគ្នាជាមួយស្ថាប័នឯកជន លើកលែងតែករណីនៅប្រទេសឡាវ។




ក្រាហ្វិច 10៖ ការប្រៀបធៀបរវាងអ្នកស្រាវជាវក្នុងជំនាញការប្រែប្រួលអាកាសធាតុ និងក្រៅជំនាញដែលបានសហការជាមួយស្ថាប័នឯកជន និងស្ថាប័នអន្តរជាតិ

ស្ថាប័នឯកជន និងស្ថាប័នអន្តរជាតិដែលអ្នកស្រាវជ្រាវបានសហការជាមួយសូមពិនិត្យតារាង ៣ ក្នុងឧបសម្ព័ន្ធខាងក្រោម។

## 3. តម្រូវការជំនាញសិក្សាស្រាវជ្រាវ

ជាចុងបញ្ចប់ យើងបានចោទជាសំណួរទៅកាន់អ្នកចូលរួមទាំងអស់អំពីគំនិតយោបល់របស់ពួកគេទាក់ទងជំនាញណាខ្លះដែលមានតម្រូវការស្រាវជ្រាវច្រើន។ អ្នកស្រាវជ្រាវមកពីប្រទេសទាំង ៣ ខាងលើបានឆ្លើយសំណួរលម្អិត និងផ្តោតសំខាន់ទៅលើប្រធានបទជាច្រើនដែលពួកគេគិតថាមានសារៈសំខាន់។ ពួកគេភាគច្រើនបានលើកឡើងពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅលើវិស័យផ្សេងៗដូចជា៖ វិស័យកសិកម្ម កម្រិតជីវភាពរស់

នៅ ជលផល ការប្រើប្រាស់ដី ព្រៃឈើ ។ល។ ការបន្សាំទៅនឹងការប្រែប្រួលអាសកាសធាតុ ក៏ដូចជាយុទ្ធសាស្ត្រការកាត់បន្ថយគឺជាបញ្ហារួមដែលពួកគេបានលើកឡើង។ ប្រធានបទទាក់ទងក្នុងសង្គមដូចជាៈ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុក្នុងសង្គម យេនឌ័រ និងការប្រែប្រួលអាសធាតុ ទស្សនៈការយល់ឃើញជាសាធារណ ការផ្សព្វផ្សាយឥរិយាបថចំពោះការប្រែប្រួលអាកាសធាតុ ក៏ត្រូវបានលើកយកមកបង្ហាញដែរ។ ស្ថានភាពការប្រើប្រាស់ថាមពលនៅក្នុងប្រទេសទាំងបី និងការស្រាវជ្រាវពីការប្រើប្រាស់ថាមពលកកើតឡើងពាក់ព័ន្ធនឹងប្រធាបទដែលបានលើកឡើងដោយអ្នកចូលរួម ក៏ដូចជាសេដ្ឋកិច្ចនៃការប្រែប្រួលអាកាសធាតុ។ ភាពរាំងស្ងួតនិងគ្រោះទឹកជំនន់ មូលហេតុ ឥទ្ធិពល និងយុទ្ធសាស្ត្រកាត់បន្ថយ ត្រូវបានលើកឡើងដោយអ្នកចូលរួមទាំងអស់មកពីប្រទេសទាំងបី។ ការធ្វើផែនការប្រើប្រាស់ដី ហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់នៅទីក្រុង និងតំបន់ជនបទ ឬនៅតំបន់ជាក់លាក់ណាមួយគឺសុទ្ធសឹងជាចំណាប់អារម្មណ៍នៃប្រធានបទ។ ប្រធានបទដែលបានបង្ហាញខាងលើ គឺជាចំណុចសង្ខេបរួមខ្លីអំពី ប្រធានបទដែលអ្នកសិក្សាស្រាវជ្រាវគិតថាមានតម្រូវការស្រាវជ្រាវច្រើន។ ប្រធាបទទាំងអស់នេះមានបង្ហាញនៅក្នុងតារាងទី ៤ នៃឧបសម្ព័ន្ធ។

# ការវិភាគលើការពិភាក្សាជាក្រុម

## ប្រទេសកម្ពុជា៖ អាជ្ញាធរជាតិ និងវិស័យឯជន

ការពិភាក្សាជាមួយតំណាងមកពីនាយកដ្ឋានការប្រែប្រួលអាកាសធាតុចំនួន ១២ នាក់ នៃក្រសួងបរិស្ថានព្រមទាំងតំណាងដែលអញ្ជើញមកពីផ្នែកការនៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជាចំនួន ១៤ នាក់បានចូលរួមការពិភាក្សាក្រុម។ ការពិភាក្សាត្រូវបានបែងចែកជាបីក្រុម ដូចនេះការបង្ហាញពីទិន្នន័យនឹងត្រូវបានដាក់តាមលំដាប់លំដោយដូចខាងក្រោម៖

### ទស្សនៈការយល់ឃើញ និងការផ្សព្វផ្សាយ

យោងទៅលើការពិភាក្សារបស់តំណាងក្រុមនីមួយៗ "អាជ្ញាធរមូលដ្ឋាន" និង "វិស័យឯកជន" នៅក្នុងប្រទេសកម្ពុជា ការប្រែប្រួលអាកាសធាតុត្រូវបានគេដឹងថា ជាបាតុភូតពិតប្រាកដមួយដែលគេចាត់ទុកថាបានផ្តល់ផលលំបាកជាច្រើនដូចជា៖ ការកើនឡើងនៃសីតុណ្ហភាព ការប្រែប្រួលរបបទឹកភ្លៀង ការកើនឡើងកម្ពស់ទឹកសមុទ្រ និងការកើនឡើងទឹកប្រៃនៅតំបន់មាត់សមុទ្រ និងព្រឹត្តិការណ៍ធាតុអាកាសធាតុធ្ងន់ធ្ងរនានាដូចជា៖ គ្រោះទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបានប៉ះពាល់ដល់វិស័យសំខាន់ៗដែលជួយដល់សេដ្ឋកិច្ចជាតិ ជាពិសេសសង្គមដែលងាយនឹងទទួលរងគ្រោះ ដែលបណ្តាលឱ្យមានការពន្យាពេលដល់ស្ថេរភាពសេដ្ឋកិច្ច នៅក្នុងប្រទេស និងការប្រកួតប្រជែងនៅកម្រិតអន្តរជាតិ។ វិស័យដែលទទួលរងគ្រោះខ្លាំងបំផុតនោះគឺវិស័យកសិកម្មដោយធនធានទឹកមានការថយចុះ។ ក្នុងវិស័យកសិកម្ម ផលប៉ះពាល់ដែលបានទទួលរងកន្លងមកមានដូចខាងក្រោម៖

- ការផ្លាស់ប្តូររដូវការដាំដុះ
- ការទទួលគ្រោះទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះញឹកញាប់
- ផ្លាស់ប្តូរវិសមរូបអាកាសធាតុដូចជា៖ សីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងរបបទឹកភ្លៀង ជាមួយគ្នានឹងការជ្រាបចូលនៃទឹកក្រោមដី ក៏ដូចជាសំណើមក្នុងបរិយកាស
- ទិន្នផលដំណាំធ្លាក់ចុះដែលនាំឱ្យមានការនាំចេញថយចុះជាលំដាប់
- ទទួលរងដោយការបំផ្លាញផលដំណាំដោយសារតែគ្រោះទឹកជំនន់ធ្ងន់ធ្ងរកំឡុងពេលរដូវវស្សា
- ការផ្ទុះឡើងជម្ងឺ និងសត្វល្អិត ដែលបំផ្លាញប្រភេទដំណាំដែលងាយរងគ្រោះ

- ការកើនឡើងកម្ពស់ទឹកសមុទ្រធ្វើឱ្យប៉ះពាល់ផលិតកម្មកសិកម្មតាមបណ្តោយឆ្នេរសមុទ្រ
- កំណើនការប្រើប្រាស់ទឹកពីអាងស្តុកដោយសារគ្រោះរាំងស្ងួតរយៈពេលយូដែលពេលខ្លះបានឈានទៅដល់ការខូចផលដំណាំទាំងស្រុង។
- ការរំពឹងទុកបានបង្ហាញថាទិន្នផលស្រូវនៅរដូវវស្សាបានបន្តធ្លាក់ចុះរហូតដល់ឆ្នាំ ២០៨០ និងធ្លាក់រហូតដល់ ៧០% ធៀបនឹងទិន្នផលស្រូវបច្ចុប្បន្ន។ ទិន្នផលស្រូវនៅរដូវប្រាំង (ស្រូវស្រោចស្រព) ទិន្នផលដំណាំដែលបានដាំដុះនៅខែវិច្ឆិកា និងខែធ្នូអាចធ្លាក់ចុះរហូតដល់ ៤០%។
- ការបាត់បង់ផលិតផលខ្លាំងនោះដោយសារគ្រោះទឹកជំនន់ (ប្រហែល ៦២%) និងគ្រោះរាំងស្ងួត (ប្រហែល ៣៦%)

វិស័យទេសចរងាយនឹងទទួលរងគ្រោះដោយសារទទួលរងឥទ្ធិពលខាងក្រៅរួមមាន៖ តម្លៃប្រេងឡើងថ្លៃ រោគរាតត្បាត និងគ្រោះធម្មជាតិដែលកើតឡើងផ្ទួនៗ ការសឹករេចរឹលបរិស្ថានធម្មជាតិ ការបំផ្លាញកេរ៍ដំណែលមរតកវប្បធម៌ ការប្រែប្រួលរបបទឹកប្រើប្រាស់ ការបាត់បង់ពពួកជីវចម្រុះ ការបាត់បងសោភ័ណភាពតំបន់ទេសភាព ការប្រកួតប្រជែងផលិតផលកសិកម្ម និងការសឹករេចរឹកតំបន់ឆ្នេរសមុទ្រ។ ការបាត់បង់ជីវចម្រុះដែលជាផ្នែកមួយដែលបានទាក់ទាញភ្ញៀវទេសចរណ៍ ក៏ទទួលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ។ ការបំផ្លាញពពួកសត្វ និងរុក្ខជាតិតូចៗ ដែលជាលទ្ធផលនាំឱ្យថយចុះចំនួនទេសចរណ៍ដែលបានមកទស្សនាក្នុងប្រទេស។ ការប្រែប្រួលអាកាសធាតុត្រូវបានគេមានជំនឿថាបង្កឱ្យសឹករេចរឹលតំបន់បេតិកភណ្ឌជាប្រវត្តិសាស្ត្រផងដែរដោយសារតែភាពរាំងស្ងួត និងគ្រោះទឹកជំនន់ ព្រមទាំងកើនឡើងចំនួនថ្ងៃក្តៅ។

ព្រៃឈើ ជាវិស័យមួយដ៏សំខាន់នៅក្នុងប្រទេសកម្ពុជាដែលមានប្រជាជនជាច្រើនរស់នៅក្នុងតំបន់ជនដែលពឹងអាស្រ័យជាចម្បងទៅលើអនុផលព្រៃឈើសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងបង្កើនប្រាក់ចំណូលបន្ថែម។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើព្រៃឈើ ពាក់ព័ន្ធជាមួយភ្លើងឆេះព្រៃ និងការបាត់បង់ជីវចម្រុះ ដំណុះមិនល្អ និងថយចុះផលិទ្ធភាពព្រៃឈើដោយសារតែការពន្យាពេលភាពរាំងស្ងួត។ ផលប៉ះពាល់ដែលអាចនឹងកើតនាពេលអនាគតរួមមាន៖

- ការគំរាមកំហែងពពួករុក្ខជាតិពូជដើមតាមរយៈការធ្វើឱ្យបរិស្ថានមានផលិតភាពសម្រាប់ពពួករាតត្បាតណាដែលមិនចាំបាច់ និងធ្វើឱ្យមានសមភាពរបស់ប្រព័ន្ធអេកូឡូស៊ីព្រៃឈើ។
- ស្ថិតនៅក្រោមចំហាកបញ្ចេញឧស្ម័ន Scenarios B1 និង A2 ព្រៃឈើនៅតំបន់ទំនាបភាគច្រើននឹងទទួលរងរយៈពេលស្ងួតយូររហូតដល់ឆ្នាំ ២០៥០ ជាពិសេសតំបន់ព្រៃស្ថិតនៅភាគឦសាន និងនិរតីនៃប្រទេស។
- ព្រៃឈើនៅតាមតំបន់ទំនាបប្រមាណជាង ៤ លាន ហិកតា ដែលបច្ចុប្បន្នដែលមានបរិមាណទឹកលើស ចន្លោះ ៤ ទៅ ៦ខែ ក៏នឹងអាចទទួលរងបរិមាណទឹកលើសផងដែរចន្លោះពី ៦ ទៅ ៨ខែ ឬលើសនេះ។

ការប្រែប្រួលអាកាសធាតុក៏ទទួលរងផលប៉ះពាល់ដល់វិស័យផ្សេងៗទៀតផងដែរដូចខាងក្រោម៖

**វិស័យជលផល៖** តាមរយៈការពន្យាពេល រដូវប្រាំងកាន់តែក្តៅ និងពន្យាពេលមកដល់នៃរដូវវស្សាបានប៉ះពាល់ដល់រដូវត្រីពង ជម្រកត្រី ចរាចរណ៍ការធ្វើដំណើររបស់ត្រី និងកម្រិតរស់រហូតដល់ភាពពេញវ័យ ហើយក៏មានការកើនឡើងវត្តមានពពួករាតត្បាតនៅតាមបណ្តោយទន្លេ ឬតំបន់វាលទំនាប។ ភាពរាំងស្ងួតមានរយៈពេលយូរ និងកម្រិតរំភាយខ្ពស់ដោយសារតែកំណើនសីតុណ្ហភាពដែលនាំឱ្យបឹងរីងស្ងួត បង្កឱ្យបាត់បង់ ឬសឹករេចរិលបរិមាណទិន្នផលត្រី។ ឧទាហរណ៍ត្រីរាប់ពាន់តោនក្នុងបឹងទន្លេសាបបានងាប់កំឡុងពេលអាកាសធាតុក្តៅមិនបានរំពឹងទុកនៅរដូវប្រាំងឆ្នាំ ២០១៥។

**វិស័យអប់រំ៖** ការកើនឡើងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរបានប៉ះពាល់ដលសេវាកម្មអប់រំ ការអភិវឌ្ឍធនធាន មនុស្ស និងហេដ្ឋារចនសម្ព័ន្ធ។ គ្រោះទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះនាំឱ្យមានកំណើនថ្ងៃក្តៅខ្លាំងធ្វើឱ្យសិស្សជាពិសេសកុមារ និងគ្រូមិនអាចធ្វើដំណើរទៅសាលារៀនបាន។ ជាក់ស្តែង មានសាលារៀនប្រមាណ ៥០០ បានពន្យារពេលសិក្សាដោយសារមានទឹកជំនន់ខ្ពស់ពេកនៅឆ្នាំ ២០១៣។ ចំណែកឯ នៅឆ្នាំ២០១៥ មានសាលាបឋមទាំងអស់នៅក្នុងប្រទេសកម្ពុជា បានបិទទ្វារយ៉ាងហោចណាស់១ខែកំឡុងពេលរដូវក្តៅខ្លាំងក្នុងឆមាសនោះដើម្បីចៀសវាងហានិភ័យដែលនាំឱ្យកុមារមានជំងឺនៅពេលទៅសាលារៀនកំឡុងពេលនោះ។

**យេនឌ័រ៖** ការប្រែប្រួលអាសកាសធាតុបានប៉ះពាល់ដល់បុរស និងស្ត្រីតាមរបៀបផ្សេងគ្នា ដោយសារតែការចូលរួមកម្លាំងពលកម្មក្នុងផ្ទះ សហគមន៍ និងសង្គម។ ស្ត្រីមានផ្ទៃពោះប្រហែលជាទទួលរងដោយការប្រែប្រួលធាតុអាកាស និងអាកាសធាតុច្រើនជាងបុរស។

**វិស័យសុខាភិបាល៖** បាតុភូតធាតុអាកាសធ្ងន់ធ្ងរអាចបណ្តាលប៉ះពាល់ដោយផ្ទាល់ និងប្រយោលទៅលើការស្លាប់ រងរបួស មានជំងឺ និងបញ្ហាខួរក្បាល។ ការកើនឡើងជំងឺគ្រុនឈាម និងជំងឺឆ្លងតាមទឹកត្រូវបានកត់ត្រា ព្រមទាំងប៉ះពាល់ខ្លាំងបំផុតទៅលើកុមារ និងគ្រួសារក្រីក្រក្នុងសង្គមដែលបានបែងចែកតាមរយៈវិសមភាពអាហាររូបត្ថម្ភ និងលក្ខខណ្ឌសុខភាពដែលងាយទទួលរងគ្រោះ។

**ហេដ្ឋារចនាសម្ព័ន្ធ៖** គ្រោះទឹកជំនន់ និងភាពរាំងស្ងួត ក្នុងនោះគ្រោះទឹកជំនន់បណ្តាលដាច់ផ្លូវជនបទ និងផ្លូវជាតិតាមតំបនជនបទ ក៏ដូចជាតំបន់ទីក្រុង បង្កឱ្យមានឧបសគ្គដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងប្រទេស។

**ធនធានទឹក៖** ភាពរាំងស្ងួតយូរបង្កឱ្យមានការផ្គត់ផ្គង់ទឹកមានកំណត់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងដំណើរការផលិតកម្មកសិកម្ម។ ការហៀរចេញ និងការបំពេញទឹកក្រោមដី និងគុណភាពទឹកលើផ្ទៃដីត្រូវបានប៉ះពាល់ដោយគ្រោះទឹកជំនន់ និងទឹកជំនន់យ៉ាងគំហុក ក៏ដូចជាលក្ខខណ្ឌទីជម្រាលមិនល្អ និងផ្ទៃរងទឹកភ្លៀង ព្រមទាំងការគ្រប់គ្រងតំបន់វាលទំនាប។

**តំបន់ឆ្នេរសមុទ្រ៖** ការកើនឡើងនីវ៉ូទឹកសមុទ្របណ្តាលឱ្យលេចធ្លាយចូលទឹកប្រៃធ្វើឱ្យប៉ះពាល់ដោយផ្ទាល់លើអនាម័យទឹក ជីវចម្រុះសមុទ្រ និងអនាម័យ។ ផលប៉ះពាល់ទាំងអស់ខាងលើបានបង្កឱ្យមានឥទ្ធិពលដោយផ្ទាល់ និងប្រយោលទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ។ ប្រជាជនកម្ពុជាភាគច្រើនពឹងផ្អែកទៅលើវិស័យកសិកម្មជាប្រភពប្រាក់ចំណូលដ៏សំខាន់ ហើយជាវិស័យមួយងាយទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ បាតុភូតនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការថយចុះនៃធនធានទឹក សំដៅដល់គុណភាព និងទឹកដែលមាន។ ការបំផ្លាញហេដ្ឋានរចនសម្ព័ន្ធដោយសារតែភាពរាំងស្ងួត និងខ្យល់ព្យុះបានគំរាមកំហែងដល់ការទំនាក់ទំនង ការផ្លាស់ប្តូរផលិតផលជាតិ និងអន្តរជាតិ និងបន្តឱ្យមានសេវាកម្មផ្សេងៗដូចជាអគ្គិសនី និងការផ្គត់ផ្គង់ទឹកនៅតាមតំបន់ជនបទ និងទីប្រជុំជន។ ការហូរចូលនៃទឹកប្រៃនៅតាមតំបន់ឆ្នេរសមុទ្របានបង្កដល់ការគំរាមកំហែងដល់ការប្រមូលផលពីវារីវប្បកម្ម និងសកម្មភាពសេដ្ឋកិច្ចដល់ប្រជាជននៅតំបន់ទាំងនេះ។ ការកើនឡើងជំងឺគ្រុនឈាម និងជំងឺឆ្លងតាមទឹក

ផ្សេងៗទៀតហួសកំណត់ពីសេវាកម្មសុខភាពសារធារណៈបណ្ដាលមកពីការវិនិយោគថវិការដ្ឋ ព្រមទាំងប៉ះពាល់ដល់ផលិតកម្មជាតិ និងសុខមាលភាពរបស់ប្រជាជន។

ទិន្នន័យដែលបានប្រមូលកំឡុងពេលធ្វើកិច្ចសម្ភាសបានបង្ហាញថាតំណាងអាជ្ញាធរថ្នាក់ជាតិ និងវិស័យឯកជនបានយល់ដឹងច្បាស់ពីផលប៉ះពាល់ជាសក្ដានុពលពីការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសរបស់ពួកគេ។ទោះជាយ៉ាងនេះក៏ដោយ វាមិនទាន់បញ្ជាក់ច្បាស់នៅឡើយថាអ្វីដែលពួកគេនឹងគិតថាប៉ះពាល់ដល់ប្រជាជន និងសេដ្ឋកិច្ចជាតិ។ យោងទៅលើចម្លើយរបស់អ្នកចូលរួមផ្ដល់សម្ភាស ការយល់ដឹងពីសំណាក់តួអង្គពាក់ព័ន្ធពិតជាបានទូលំទូលាយ ផ្ទុយទៅវិញ រាល់ចម្លើយខ្លះនៅមានកម្រិត និងមានប្រសិទ្ធភាពតិចតួច។ តាមពិតដោយសារតែខ្វះខាតចំណេះដឹង និងជំនាញការប្រែប្រួលអាកាសធាតុ។ វាជាការចង់បានសម្រាប់ការដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតទាំងអស់ចាប់ពីថ្នាក់បឋមសិក្សារហូតដល់គ្រឹះស្ថានឧត្ដមសិក្សាកម្រិតឧត្ដមក្នុងគោលបំណងដើម្បីបង្កើតឱ្យមានអ្នកជំនាញអាជីពដើម្បីឆ្លើយតបផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅតាមវិស័យផ្សេងៗ។

នៅកម្រិតស្ថានប័ន មានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលមានតួនាទីជាក់ស្ដែងក្នុងការសម្របសម្រួលសកម្មភាពការងារឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ពង្រឹង និងជាដៃគូរសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនិងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

នៅកម្រិតក្រសួង ជនបង្គោលការប្រែប្រួលអាកាសធាតុ និងក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលការងារនេះ។ យោងទៅលើចម្លើយរបស់អ្នកចូលរួមផ្ដល់សម្ភាស ទំនួលខុសត្រូវរបស់ក្រុមការងារនេះមិនត្រូវបានកំណត់នៅឡើយជាពិសេសការប្រាស្រ័យទាក់ទងនៅក្នុងនាយកដ្ឋាននៃក្រសួងសាមីនីមួយៗ ដើម្បីធ្វើឱ្យជាក់ច្បាស់ថាការរៀបចំផែនការ កម្មវិធី និងការវិនិយោគតាមវិស័យនីមួយៗមានភាពច្បាស់លាស់ត្រឹមត្រូវដើម្បីធ្វើការសម្រេចចិត្តលើហានិភ័យការប្រែប្រួលអាកាសធាតុ និងឱកាស។ នៅក្នុងរយៈពេល ១៧ ឆ្នាំចុងក្រោយនេះ នាយកដ្ឋានការប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល និងគាំទ្រដល់គោលនយោបាយថ្នាក់ជាតិស្ដីពីការស្រាវជ្រាវ និងការអភិវឌ្ឍតាមរយៈការអនុវត្តផែនការសកម្មភាព ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយដែលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។ ដូចនេះ ការប្រែប្រួលអាកាសធាតុដើរតួនាទីយ៉ាងសំខាន់ក្នុងគោលនយោបាយថ្នាក់ជាតិស្ដីពីការស្រាវជ្រាវ និងការអភិវឌ្ឍ ជាធម្មតាមិនមានកម្រិតខ្ពស់នោះទេ និង

មានលក្ខណៈខុសគ្នាតិចតួចទៅតាមក្រសួងនីមួយៗ។ ការស្រាវជ្រាវក្នុងវិស័យសំខាន់រួមមាន៖ កសិកម្ម អប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធបានចូលរួមចំណែកយ៉ាងខ្លាំងដល់ថវិកាជាតិ។

សរុបសេចក្តីមក តម្រូវការចាំបាច់មួយដើម្បីបន្ត និងបង្កើនភាពជាដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សាសំខាន់ រីកលូតលាស់ពីការស្រាវជ្រាវនេះ។ ស្ថាប័នស្រាវជ្រាវអាចជួយវិស័យឯកជន និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធដើម្បីឱ្យមានកិច្ចពិភាក្សាជាយុទ្ធសាស្ត្រក្នុងការកំណត់វស័យអាទិភាព និងធ្វើសេចក្តីព្រាងរបៀបវារៈក្នុងការស្វែងយល់បាតុភូត និងសកម្មភាពណាល្អបំផុតសម្រាប់ដោះស្រាយ។ លទ្ធផលទទួលបានពីកិច្ចពិភាក្សាក្រុមបានបង្ហាញថាដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនេះរួមមាន៖ ១២ ក្រសួង-ស្ថាប័ន ព្រមទាំងគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុដែលបានចូលរួមក្នុងដំណើរការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចខាងក្រោម៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងកិច្ចការនារី
- ក្រសួងសុខាភិបាល
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងព័ត៌មាន
- ក្រសួងបរិស្ថាន
- ក្រសួងរ៉ែ និងថាមពល

## សមត្ថភាពថ្នាក់ជាតិស្តីពីការស្រាវជ្រាវនិងការអភិវឌ្ឍ និងតួនាទីរបស់វិស័យឯកជន

ទិន្នន័យដែលបានប្រើប្រាស់ដោយស្ថាប័ន និងវិស័យដែលពាក់ព័ន្ធដើម្បីវាស់វែងពីផលប៉ះពាល់ និងការប្រែប្រួលតាមរដូវកាលនីមួយៗជាប្រភេទទិន្នន័យឧតុនិយម (កម្ពស់ទឹកភ្លៀង សីតុណ្ហភាព ខ្យល់) ការប្រែប្រួលគម្របដី (ឧ. ការថយចុះដីព្រៃ ការថយចុះ ឬកើនឡើងកម្រិតទឹកសមុទ្រ) គុណភាពដី ទិន្នន័យជលសាស្ត្រ។ វាមិនបានបញ្ជាក់ច្បាស់ថាប្រភពព័ត៌មានណាមួយ និងសុពលភាព និងគុណភាពទិន្នន័យដែលបានធានាអះអាងនោះទេ។

មានម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍អន្តរជាតិជាច្រើនបានលើកកម្ពស់ការស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃលើការប្រែប្រួលអាកាសធាតុ។ អន្តរាគមន៍ទាំងនេះក៏បានជួយដល់ការសម្របសម្រួលដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន។ ស្ថាប័នសិក្សាស្រាវជ្រាវរបស់ប្រទេសជប៉ុនចំនួន ០២ ដែលបានសិក្សា និងវាយតម្លៃលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងត្រូវបានរកឃើញដោយស្ថាប័នរដ្ឋាភិបាល និងវិស័យឯកជន។

**មជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថានអន្តរជាតិ** (OECC)៖ ការស្រាវជ្រាវរួមគ្នាមួយលើប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល ការពិនិត្យគុណភាពទឹកក្នុងអណ្តូងរាក់នៅសណ្ឋាគារប្រណិតក្នុងទីក្រុងភ្នំពេញ និងសៀមរាប ប្រទេសកម្ពុជា ឆ្នាំ២០១៥។ បេសកកម្មរបស់ OECC ដើម្បីប្រមូលព័ត៌មានបរិស្ថានប្រចាំឆ្នាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដោយសហការរួមគ្នាជាមួយនឹងប្រទេសជប៉ុន។ សមាជិកទាំងអស់ក្នុងបេសកកម្មនេះត្រូវសហការគ្នាក្នុងការប្រឹក្សាពីបញ្ហាបរិស្ថាន ឬត្រួតពិនិត្យ/តាមដានវិភាគទៅលើបរិស្ថាន សហការក្នុងការផលិត ឬសាងសងសម្ភារការពារបរិស្ថាន ការផលិត ឬលក់សម្ភារត្រួតពិនិត្យបរិស្ថាន ឬស្ថាប័នជំនួញផ្សេងៗទៀត ស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងអង្គការមិនដើម្បីប្រាក់កំរៃផ្តោតទៅលើសកម្មភាពការអភិរក្សបរិស្ថាន។ គោលដៅក្នុងការអង្កេតរុក្ខជាតិ បរិយាកាស ទឹក ជីវចម្រុះ ការគ្រប់គ្រងសំរាម និងការយកចិត្តទុកដាក់លើសង្គម និងបរិស្ថាន។ សមាជិកទាំងអស់ចាប់ផ្តើមការអង្កេតជាទូទៅតាមរយៈការសិក្សាជាបឋមទស្សនកិច្ចសិក្សា និងទទួលបានព័ត៌មានពីមន្ត្រីនៅតាមក្រសួងពាក់ព័ន្ធ ម្ចាស់ជំនួយអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអង្គភាពផ្សេងៗទៀតផងដែរ។ បន្ទាប់ពីប្រមូលទិន្នន័យរួចសិក្ខាសាលាមួយត្រូវបានរៀបចំឡើងនៅទីក្រុងដែលមានបទបង្ហាញពីដំណោះស្រាយផលលំបាកបរិស្ថាននៅក្នុងប្រទេសគោលដៅទាំងអស់។

**វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក** (IGES)៖ សិក្សាស្រាវជ្រាវទិន្នន័យគោលដែលមានលក្ខណៈស្តង់ដារម៉ាស៊ីនកិនស្រូវក្នុងប្រទេសកម្ពុជា ដើម្បីអភិវឌ្ឍន៍មេគុណបញ្ចេញនៅក្នុងគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) សហការជាមួយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន។ វិទ្យាស្ថាននេះត្រូវបានបង្កើតឡើងដើម្បីសម្រេចបានគំរូថ្មីសម្រាប់ការរីកចំរើន និងអភិវឌ្ឍន៍គោលនយោបាយនវានុវត្តន៍ ព្រមទាំងការស្រាវជ្រាវជាយុទ្ធសាស្ត្រសម្រាប់វាស់វែងបរិស្ថាន ឆ្លុះបញ្ចាំងពីលទ្ធផលនៃការស្រាវជ្រាវនេះទៅក្នុងក្តីសម្រេចនយោបាយការអភិវឌ្ឍដោយចីរភាពទាំងក្នុងតំបន់ និងពិភពលោក។ IGES ប្រមូលព័ត៌មានបរិស្ថានហើយលក់ទៅឱ្យតួអង្គពាក់ព័ន្ធដើម្បីបានថវិកាស្រាវជ្រាវ។ នៅក្នុងប្រទេសកម្ពុជា វិស័យឯកជនដើរតួនាទីយ៉ាងសំខាន់មិនត្រឹមតែបានចូលរួមស្រាវជ្រាវការប្រែប្រួលអាកាសធាតុ ប្រសិនបើមានកិច្ចសហប្រតិបត្តិការជាអន្តរជាតិនិងក្រុមហ៊ុនធំៗធ្វើការសិក្សាពីផលប៉ះពាល់ពីការចូលរួមរបស់ពួកគេ វាមិនទំនង់ថាលទ្ធផលត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ។ ផលលំបាកចម្បងសម្រាប់អង្គការមិនមានរដ្ឋាភិបាលក្នុងស្រុកដែលបានចូលរួមយ៉ាងសកម្មចំពោះការស្រាវជ្រាវថ្នាក់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ គឺខ្វះខាតប្រភពមូលនិធិចុះអង្កេតតាមទីវាលទៅតាមក្របខណ្ឌគម្រោងជាក់លាក់មួយ។ កត្តាដែលសំខាន់មួយទៀតនោះគឺ ធនធានមនុស្សនៅមានកម្រិត។ តម្រូវការចាំបាច់សម្រាប់ដំណោះស្រាយនៅតែមានការកើនឡើង។ នាយកដ្ឋានប្រែប្រួលអាកាសធាតុជាក់ស្តែតកំពុងស្វែងរកអ្នកជំនាញខាងផ្នែកយុទ្ធសាស្ត្របន្សាំ និងការត់បន្ថយការប្រែប្រួលអាកាសធាតុ ក៏ដូចជាការវាយតម្លៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់។

## ការផ្តល់ហិរញ្ញវត្ថុ និងធនធានសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍការប្រែប្រួលអាកាសធាតុ

លទ្ធផលទទួលបានពីកិច្ចសម្ភាស វាបានបញ្ជាក់ថាមានផែនការសកម្មភាព និងយុទ្ធសាស្ត្រមួយចំនួនដើម្បីដោះស្រាយជាមួយការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធីខាងក្រោមបានអនុវត្តន៍៖

- ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ដែលមាន ៣ ដំណាក់កាលសំខាន់ៗ៖
  - រយៈពេលខ្លី (២០១៣-២០១៤)
  - រយៈពេលមធ្យម (២០១៤-២០១៨)
  - រយៈពេលវែង (២០១៩-២០២៣)
- យុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍបៃតង និងផែនការអភិវឌ្ឍន៍តាមវិស័យ

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP)
- យុទ្ធសាស្ត្រចតុកោណ
- ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាធាតុ (CCAP)
- ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (SCCSP)
- ក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ (CCFF)

CCCSP ជាមួយគ្នាផែនការសកម្មភាពដែលពាក់ព័ន្ធបានផ្តល់ជាក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់កម្មវិធីអន្តរាគមន៍ការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។ យន្តការហិរញ្ញប្បទានប្រែប្រួលអាកាសធាតុថ្នាក់ជាតិជួយគាំទ្រដល់វិធីសាស្ត្រដែលជាយុទ្ធសាស្ត្រតាមរយៈការដាក់ចេញគោលការណ៍ដូចខាងក្រោម៖

- ការរៀបចំវិស័យអាទិភាពថ្នាក់ជាតិ
- ការបញ្ចូលធនធាន
- ការប្រើប្រាស់តាមប្រព័ន្ធ និងនិតិវិធីជាតិ
- ការឧបត្ថម្ភដើមទុន

នៅក្នុងឆ្នាំ ២០១៤ សកម្មភាពខាងក្រោមនេះត្រូវបានយកមកពិភាក្សាដោយមានចាប់អារម្មណ៍និងក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុដ៏មានប្រសិទ្ធភាពសម្រាប់កម្ពុជា៖

- វិភាគលើឱកាសចល័តប្រភពធនធាន (ប្រភពខាងក្នុង និងខាងក្រៅ) ទាំងនៅកម្រិតជាតិ និងវិស័យជាអាទិភាព
- វាយតម្លៃពីថ្លៃដើមសម្រាប់ CCCSP និង SCCSPs ដោយធ្វើអាទិភាពលើគម្រោងពាក់ព័ន្ធខ្ពស់
- វាយតម្លៃពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមចំពោះផលប្រយោជន៍សរុប និងពុំមានសកម្មភាពលើចំហាកឆ្លើយតបជាច្រើនដើម្បីផ្តល់ជាអាទិភាពចំពោះការចំណាយក្នុង១វិស័យ និងអនុវិស័យ។
- វិភាគលើការអនុវត្តថ្នាក់ជាតិល្អៗ និងការអនុវត្តជាអន្តរជាតិដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងរៀបចំប្រភពមូលនិធិដែលបានដាក់បញ្ចូលសម្រាប់យន្តការហិរញ្ញប្បទានប្រែប្រួលអាកាសធាតុថ្នាក់ជាតិ និងក្រោមជាតិ។

- វិភាគលើភាពខ្វះចន្លោះសមត្ថភាព និងអនុសាសន៍ក្នុងការពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ និងក្រោមជាតិ។ ទាំងអស់នេះរួមបញ្ចូលអនុសាសន៍សម្រាប់ការងារបន្ថែមលើភាពដែលអាចកើតមានចំពោះការចល័តហិរញ្ញវត្ថុឯកជនសម្រាប់សកម្មភាពបន្សាំ និងការកាត់បន្ថយ។

ការគាំទ្រផ្នែកហិរញ្ញវត្ថុគឺទទួលបានពីម្ចាស់ជំនួយអន្តរជាតិដល់នាយកដ្ឋានការប្រែប្រួលអាកាសធាតុ (DCC) តាមរយៈមូលនិធិសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA-Trust Fund)។ CCCA-Trust Fund បានផ្តល់ថវិកាដល់ ១១ ស្ថាប័នជាតិដោយយោងទៅលើគម្រោងស្នើសុំ។ វិស័យជាអាទិភាពគឺ កសិកម្ម ហេតុដូចនេះ នាយកដ្ឋានប្រែប្រួលអាកាសធាតុបានសហការជាដៃគូជាមួយសាកលវិទ្យាល័យចំនួន ៤ មាន៖ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាលាជាតិកសិកម្មព្រែកលៀប និងសាកលវិទ្យាល័យមានជ័យ ដើម្បីលើកកម្ពស់ការពង្រឹងសមត្ថភាពទៅលើប្រធានបទពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។

មូលនិធិនេះបានផ្តល់ឱ្យស្ថាប័នក្រៅរដ្ឋាភិបាល និងវិស័យឯកជន ចំណែកឯស្ថាប័នរដ្ឋាភិបាលមិនត្រូវបានរាប់បញ្ចូលនោះទេដោយសារតែសមត្ថភាពនៅមានកម្រិត។ ជាទូទៅ ប្រភពមូលនិធិភាគច្រើនទទួលបានពីម្ចាស់ជំនួយអន្តរជាតិសម្រាប់អនុវត្តន៍គម្រោង និងអភិវឌ្ឍន៍ធនធានមនុស្ស។ សង្គមស៊ីវិល ស្ថាប័នអប់រំ និងក្រសួងពាក់ព័ន្ធជាអ្នកទទួល និងជាអ្នកគ្រប់គ្រងមូលនិធិ។ បច្ចុប្បន្ន នាយកដ្ឋានប្រែប្រួលអាកាសធាតុកំពុងសម្របសម្រួលលើកម្មវិធីចំនួន ៣ ដូចខាងក្រោម៖

- សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ផ្តល់មូលនិធិដោយ សហភាពអឺរ៉ុប (EU) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ទីភ្នាក់ងារសហប្រតិបត្តិការ និងអភិវឌ្ឍន៍អន្តរជាតិ ស៊ុយអែត (SIDA) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (DANIDA) ដែលមានថវិកាសរុប ១១ លានដុល្លារសហរដ្ឋអាមេរិចនៅក្នុងដំណាក់កាលទី១ (២០១០-២០១៤) ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងថ្នាក់ជាតិ និងសមត្ថភាពគាំទ្រដល់ការសម្របសម្រួល និងការអនុវត្តការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ដំណាក់កាលទី២ កំពុងចាប់ផ្តើមធ្វើបន្តលើគោលបំណងរបស់ខ្លួន ២០១៤-២០១៩ ដែលមានទឹកប្រាក់សរុប ១២.៤ លានដុល្លារសហរដ្ឋអាមេរិចផ្តល់មូលនិធិដោយ EU, UNDP និង SIDA។

- កម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ត្រូវបានអនុវត្តន៍ជាពីរដំណាក់កាល។ ដំណាក់កាលទី ១ ជួយគាំទ្រថ្នាក់ជាតិក្នុងការវាយតម្លៃ និអភិវឌ្ឍន៍ជាកម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)។ ដំណាក់កាលទី២ (ចាប់ពី ខែកញ្ញា ឆ្នាំ២០១៣-ខែសីហា ឆ្នាំ២០១៨) បានអនុវត្តន៍គម្រោងវិនិយោគចំនួន៧ របស់ SPCR ដែលផ្តោតសំខាន់ទៅលើ ៣ វិស័យ (កសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធ)។ កម្មវិធីត្រូវបានអនុវន្តន៍ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបណ្តាក្រសួងពាក់ព័ន្ធផ្សេងៗទៀត។
- បណ្តាញអាស៊ីអាគ្នេយ៍ស្តីពីការប្រែប្រួលអាកាសធាតុ (SEAN-CC) គាំទ្រថវិកាដោយកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ដើម្បីលើកកម្ពស់ការយល់ដឹងមន្ត្រីរដ្ឋាភិបាលធ្វើការពាក់ព័ន្ធការប្រែប្រួអាកាសធាតុនិងចូលរួមអភិវឌ្ឍន៍គោលការណ៍ណែនាំដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ។

## ប្រទេសកម្ពុជា៖ មុខវិជ្ជាសិក្សា

តំណាងក្រុមចំនួន ១៤ នាក់ របស់ស្ថាប័នគ្រឹះស្ថានឧត្តមសិក្សាមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម និង១៥ នាក់ មកពីសាកលវិទ្យាល័យ ហេងសំរិន ត្បូងឃ្មុំ និងសាកលវិទ្យាល័យស្វាយរៀងដែលបានចូលរួមក្នុងការអង្កេត។ លទ្ធផលពីកិច្ចពិភាក្សាក្រុមបានបង្ហាញថា ការស្រាវជ្រាវស្តីពីការប្រែប្រួលអាកាសធាតុ និងទិដ្ឋភាពផ្សេងៗគ្នានៃផលប៉ះពាល់លើវិស័យផ្សេងៗគ្នាត្រូវបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងទូលំទូលាយដូចជា៖

- ទឹក និងសន្តិសុខស្បៀង
- ការពង្រឹងស្ថាប័នរដ្ឋាភិបាលដើម្បីជួយកសិករបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- កសិកម្មវៃឆ្លាតខាងអាកាសធាតុ
- ការអភិរក្សកសិដ្ឋាន និងការប្រើប្រាស់ដំណាំធញ្ញជាតិចម្រុះប្រកបដោយនិរន្តរភាពតាមរយៈការចូលរួមបង្កាត់ពូជរុក្ខជាតិនិងធ្វើឱ្យមានសុវត្ថិភាពប្រព័ន្ធគ្រាប់ពូជក្នុងតំបន់នៅតាមបណ្តាខេត្តងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ
- ការវាយតម្លៃសេដ្ឋកិច្ចបន្សាំលើការប្រែប្រួលអាកាធាតុនៅក្នុងវស័យកសិកម្ម
- ការវាយតម្លៃការប្រែប្រួលអាកាសធាតុអតីតកាល ភាពងាយរងគ្រោះ និងការព្យាករអាកាសធាតុអនាគតក្នុងប្រទេសកម្ពុជា
- អភិបាលកិច្ចទឹក និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គម្រោងការស្តាររុក្ខជាតិពូជនៅប្រទេសកម្ពុជា
- ភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- ការអភិវឌ្ឍមេគុណសមីកាដើម្បីគណនាកាបូនក្នុងព្រៃឈើ
- ការកំណត់គ្រោះថ្នាក់ធម្មជាតិ
- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម
- ផលប៉ះពាល់នៃភាពរាំងស្ងួតលើជីវភាពរស់នៅតាមតំបន់ជនបទ
- ការសិក្សាពីការបញ្ចេញឧស្ម័នមេតានពីសត្វទំពារអៀងដោយប្រើប្រព័ន្ធ INVITRO SYSTEM
- ការផលិតឧស្ម័នមេតានដោយប្រើកាកសំណល់ចេញពីបន្លែ ផ្លែឈើ និងជីលាមកសត្វ
- មេរៀនស្តីពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចេញពីការចញ្ចឹមសត្វ
- ការពង្រឹងជីវភាពរស់នៅរបស់សហគមន៍តាមរយៈការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

ប្រធានបទខាងក្រោមបាននឹងកំពុងសិក្សានាពេលបច្ចុប្បន្ន៖

- ការពង្រីកការអនុវត្តគ្រប់គ្រងដីប្រកបដោយចីរភាព (SLM)
- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយប្រើការដាំដុះដោយផ្ទាល់
- ប្រសិទ្ធភាពនៃការស្តារព្រៃឈើលើតំបន់ដែលមានទឹកសម្រាប់កសិកម្មវៃឆ្លាត

- ការពង្រឹងសមត្ថភាពការស្រាវជ្រាវ និងនវានុវត្តន៍នៃការប្រែប្រួលអាកាសធាតុ
- គម្រោងការកសាងសមត្ថភាពបន្សាំតាមរយៈការពង្រីកបច្ចេកវិទ្យាថាមពលកកើតឡើងវិញនៅតំបន់ជនបទប្រទេសកម្ពុជា
- គម្រោងការធ្វើឱ្យប្រសើរឡើងភាពធន់នឹងការប្រែប្រួលអាកាសធាតុដល់សហគមន៍មូលដ្ឋាននៅតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា

កម្មវិធីស្រាវជ្រាវ និងប្រព័ន្ធផ្តល់មូលនិធិត្រូវបានផ្តល់ជូនដោយម្ចាស់ជំនួយថ្នាក់ជាតិនិងអន្តរជាតិដល់គ្រឹះស្ថានឧត្តមសិក្សាសម្រាប់ការបណ្តុះបណ្តាលវគ្គសិក្សាខ្លី និងការស្រាវជ្រាវ គម្រោងស្រាវជ្រាវ ការពង្រឹងសមត្ថភាព និងផ្តល់អាហាររូបករណ៍ដល់បរិញ្ញាបត្រជាន់ខ្ពស់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ខាងក្រោមនេះជាគម្រោង និងកម្មវិធីដែលបានអនុវត្តន៍៖

គម្រោងអនុវត្តន៍ពីអតីតកាល៖

- វគ្គបណ្តុះបណ្តាលខ្លីៗគាំទ្រដោយបណ្តាញអាស៊ី-ប៉ាស៊ីហ្វិកសម្រាប់ការផ្លាស់ប្តូរការស្រាជ្រាវសកល APN (ឥណ្ឌូណេស៊ី ហ្វីលីពីន និងកម្ពុជា)
- ការពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាលដើម្បីជួយកសិករបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុផ្តល់មូលនិធិដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា
- ការអភិរក្សកសិដ្ឋាន និងការប្រើប្រាស់ដំណាំធញ្ញជាតិចម្រុះប្រកបដោយនិរន្តរភាពតាមរយៈការចូលរួមបង្កាត់ពូជរុក្ខជាតិនិងធ្វើឱ្យមានសុវត្ថិភាពប្រព័ន្ធគ្រាប់ពូជក្នុងតំបន់នៅតាមបណ្តាខេត្តងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុផ្តល់មូលនិធិដោយវេទិកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
- ការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុក្នុងការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់គ្រឹះស្ថានអប់រំកសិកម្មនៅប្រទេសកម្ពុជាផ្តល់មូលនិធិដោយគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សាគាំទ្រដោយ ធនាគារពិភពលោក
- ការគាំទ្រដល់ការធ្វើសារពើភណ្ឌព្រៃឈើថ្នាក់ជាតិស្តីពី ការអភិវឌ្ឍសមីកា និងមេគុណបញ្ចេញផ្តល់ មូលនិធិដោយ៖ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)
- ជំនួយអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិជួយប្រទេសអភិវឌ្ឍន៍តិចតួចក្នុងការដំណើរការរៀបចំផែនការបន្សាំថ្នាក់ជាតិ (NAPs) គាំទ្រដោយ UNDP

- កម្មវិធីពង្រឹងសមត្ថភាពរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិជាមួយជំនួយពីពលរដ្ឋសហរដ្ឋអាមេរិច UNDP-USAID ស្តីពីសេដ្ឋកិច្ចបន្សាំការសិក្សាបន្សាំការប្រែប្រួលអាកាសធាតុនៅអាស៊ីផ្តោតសំខាន់ទៅ លើវិស័យកសិកម្មផ្តល់មូលនិធិដោយ UNDP
- ការវាយតម្លៃការប្រែប្រួលអាកាសធាតុអតីតកាល ភាពងាយរងគ្រោះ និងការព្យាករអាកាសធាតុអនាគត ក្នុងប្រទេសកម្ពុជាផ្តល់មូលនិធិដោយមូលនិធិបៃតងឥណ្ឌា
- អភិបាលកិច្ចទឹក និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជាផ្តល់មូនលិធិដោយ វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (CDRI)
- ការផ្តល់អាហាររូបករណ៍ដល់និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ជំនាញការគ្រប់គ្រងធនធានធម្មជាតិដែលគាំទ្រថវិកាដោយគម្រោង USAID-Post Harvest ក្រសួងបរិស្ថាន និងអង្គការវីនរ៉ក់អន្តរជាតិ
- ការអភិវឌ្ឍកម្មវិធីសិក្សាស្តីពីការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ស្តីពីការប្រែប្រួលអាកាសធាតុផ្តល់ថវិកាដោយ USAID Leaf Program
- គម្រោងការស្តារព្រុក្ខជាតិពូជនៅប្រទេសកម្ពុជាដោយមានការចូលរួមពីការស្រាវជ្រាវដោយមានការស្រាវជ្រាវប្រព័ន្ធអេកូឡូស៊ីព្រៃឈើជាមួយសហគមន៍ព្រៃឈើក្រោមការឧបត្ថម្ភដោយវិទ្យាស្ថានសម្រាប់យុទ្ធសាស្ត្រពិភពលោករបស់ប្រទេសជប៉ុន
- ការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាស្តីពីភាពធន់អាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី
- គាំទ្រដល់ការអភិវឌ្ឍដល់មេគុណស្រូប និងបញ្ចេញសម្រាប់សកម្មភាពទាក់ទងនឹង REDD+ និងការធ្វើ តែសការគ្រប់គ្រងសកម្មភាពបង្ហាញផ្តល់មូលនិធិដោយ FAO
- ការពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុដល់គ្រូបង្គោលផ្តល់មូលនិធិដោយគណៈកម្មការទន្លេមេគង្គ

គម្រោងអនុវត្តន៍នាពេលបច្ចុប្បន្ន៖

- គម្រោងពង្រីកបច្ចេកទេសអនុវត្តន៍ការគ្រប់គ្រងដីប្រកបដោយចីរភាព(SLM) តាមរយៈកសិករខ្នាតតូច៖ ធ្វើការជាមួយសេវាកម្មផ្សព្វផ្សាយកសិកម្ម ដើម្បីកំណត់ វាយតម្លៃ និង ផ្សព្វផ្សាយការអនុវត្ត SLM ផ្តល់មូលនិធិដោយមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)

- ប្រសិទ្ធភាពនៃការស្ដារព្រៃឈើលើតំបន់ដែលមានទឹកសម្រាប់កសិកម្មវែល្លាត៖ ករណីសិក្សានៅប្រទេសកម្ពុជា (FRAWASA) ផ្ដល់មូលនិធិដោយរដ្ឋាភិបាលស៊ុយអែត
- ការពង្រឹងសមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម ហៅកាត់ថា ("REACT") ផ្ដល់មូលនិធិដោយសហភាពអឺរ៉ុប (EU)
- គម្រោងការកសាងសមត្ថភាពបន្សាំតាមរយៈការពង្រីកបច្ចេកវិទ្យាថាមពលកកើតឡើងវិញនៅតំបន់ជនបទ ប្រទេសកម្ពុជាផ្ដល់មូលនិធិដោយមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)
- គម្រោងការធ្វើឱ្យប្រសើរឡើងភាពធន់នឹងការប្រែប្រួលអាកាសធាតុដល់សហគមន៍មូលដ្ឋាននៅតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជាផ្ដល់មូលនិធិក្រសួងបរិស្ថាន/កម្មវិធីបរិស្ថានសហប្រជាជាតិ

លទ្ធផលទទួលបានពីកិច្ចសម្ភាសបានបង្ហាញថា កត្តាសំខាន់សម្រាប់ប្រធានស្រាវជ្រាវ និងរបៀបវារៈគឺជាការអនុវត្តន៍គោលនយោបាយថ្នាក់ជាតិ និងការបំពេញបន្ថែមទៅលើគោលបំណងដែលមានស្រាប់។ ជាក់ស្ដែង សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) បានផ្ដល់ព័ត៌មានដែលជួយគាំទ្រដល់សេចក្ដីសម្រេចចិត្តគ្រប់កម្រិត។ បន្ថែមពីនេះទៀត គោលបំណងរបស់សាកលវិទ្យាល័យដើម្បីផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាដល់និស្សិត បុគ្គលិកសិក្សា អ្នកស្រាវជ្រាវវ័យក្មេង និងនៅកម្រិតសហគមន៍មូលដ្ឋានដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយបន្ត។ តាមរយៈការបង្កើតឱ្យមានការស្រាវជ្រាវ និងអភិវឌ្ឍន៍ស្ដីពីការប្រែប្រួលអាកាសធាតុ ស្ថាប័នគ្រឹះស្ថានឧត្តមសិក្សាមានសមត្ថភាពគ្រប់គ្រាន់ និងអាចទទួលបានការគាំទ្រផ្នែកមូលនិធិពីម្ចាស់ជំនួយជាតិ និងអន្តរជាតិ។ កាលពីមុន មិនមានស្ថាប័នថ្នាក់កណ្ដាលណាមួយសម្របសម្រួលដល់បណ្ដាញស្ថាប័នស្រាវជ្រាវនោះទេ។ គ្រឹះស្ថានឧត្តមសិក្សា និង ដេប៉ាត់ម៉ង់នៅក្នុងសាកលវិទ្យាល័យតែមួយនៅតែបន្តធ្វើការជាលក្ខខណៈបុគ្គលក្រោមរូបភាពនៃលក្ខខណ្ឌស្រាវជ្រាវ និងធនធានដែលមានស្រាប់នៅក្នុងប្រទេស។ ហេតុដូចនេះ ការប្រាស្រ័យទាក់ទងនៅតែបន្តពឹងអាស្រ័យលើទំនាក់ទំនងបុគ្គលរវាងអ្នកស្រាវជ្រាវ អ្នកសម្របសម្រួល បុគ្គលិករដ្ឋបាល និងមន្ត្រីជាន់ខ្ពស់នៅក្នុងមហាវិទ្យាល័យនីមួយៗ។ មិនមានស្តង់ដារណាមួយក្នុងការបង្កើតឱ្យមានសមសភាពក្រុមការងារស្រាវជ្រាវដែលបានកសាងឡើងយោងទៅលើតម្រូវការអ្នកជំនាញទាំងអស់នោះ និងប្រធានបទស្រាវជ្រាវ។ សម្រាប់ការអនុវត្តគម្រោងរួមគ្នារវាងស្ថាប័នដែលមានកិច្ចព្រមព្រៀងពហុភាគី

(អនុសារណៈយោគយល់គ្នា) ត្រូវបានបញ្ជាក់ឡើង និងមានលិខិតកិច្ចព្រមព្រៀងដែលមានលក្ខខណ្ឌច្បាស់លាស់ត្រូវបានចុះហត្ថលេខាដោយអ្នកទទួលខុសត្រូវគម្រោង។ ប៉ុន្តែនៅពេលដែលមានភាគីអនុវត្តន៍ក្នុងស្ថាប័នតែមួយមិនមានកិច្ចព្រមព្រៀងជាផ្លូវការទេ និងបុគ្គលិកអាចចូលរួមអនុវត្តន៍គម្រោងក្រោមលក្ខខណ្ឌធម្មតារបស់ស្ថាប័នពួកគេ។ បើទោះបីជាយ៉ាងណាក៏ដោយ ការបង្កើនយន្តការទាំងអស់ត្រូវបានរៀបចំបានល្អប្រសើរ តួនាទីរបស់សាកលវិទ្យាល័យចំពោះការស្រាវជ្រាវ និងការអភិវឌ្ឍសម្រាប់ការពង្រឹងសមត្ថភាពថ្នាក់ជាតិដែលនៅមានកម្រិត។ ផ្ទុយទៅវិញ ការអនុវត្តគម្រោងរួមគ្នាជាមួយមហាវិទ្យាល័យនិងមូលនិធិសម្រាប់អ្នកស្រាវជ្រាវវ័យក្មេងនិងមេរៀនគ្រោងនឹងដាក់បញ្ចូលក្នុងការស្រាវជ្រាវលើលើប្រធានបទជាក់លាក់ណាមួយ។ ការរៀបចំវេទិកាថ្នាក់ជាតិមួយក្នុងគោលបំណងដើម្បីចែករំលែកព័ត៌មានដល់គ្រឹះស្ថានឧត្តមសិក្សា បើយោងទៅតាមអ្នកចូលរួមផ្តល់ចម្លើយបានបង្ហាញថា រាល់ព័ត៌មានទាំងអស់មិនទាន់មានស្តង់ដារ ហើយក៏មិនអាចរកបានជាសាធារណៈទេ។

ការស្រាវជ្រាវ និងការអភិវឌ្ឍទទួលប៉ះពាល់ជាអវិជ្ជមានដោយសារខ្វះចំណេះដឹង និងបទពិសោធន៍ ថវិកានៅមានកំណត់ អវត្តមានទិន្នន័យក្នុងស្រុក សម្ភារចាស់ៗ និងមិនមានប្រើប្រាស់គ្រប់គ្រាន់ក្នុងមន្ទីរពិសោធន៍ និងឧបករណ៍វាស់វែងសម្រាប់ទីវាល។ ឧបសគ្គទាំងអស់នេះផងដែរបាននាំឱ្យមានអារម្មណ៍ថាមិនបានសម្រេចការងារ និងខ្វះការលើកទឹកចិត្តនូវអ្វីដែលបានអនុវត្តន៍សម្រាប់អ្នកស្រាវជ្រាវទាំងអស់ ការទំលាយចេញគំនិតច្នៃប្រឌិតនិងសក្តានុពលនៃការវិភាគតាមរយៈអង្កេត និងពន្យឺតការស្វែងរកដំណោះស្រាយសមរម្យដល់កិច្ចអន្តរគមន៍ក្នុងតំបន់។ ជាទូទៅចំពោះចំណេះដឹងសាស្ត្រាចារ្យ និស្សិត ចូលរួមក្នុងគម្រោងដើម្បីប្រមូលទិន្នន័យ ការងារទីវាលមូលនិធិស្រាវជ្រាវផ្សេងៗ និងការសរសេរនិក្ខេបបទបញ្ចប់ការសិក្សាដែលពួកគេដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រាវជ្រាវដោយខ្លួនរបស់ពួកគេ និងចំណុចខ្វះខាតសម្រាប់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រលើការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ វិធីសាស្ត្រ និងម៉ូដែលអាកាសធាតុធ្ងន់ធ្ងរ ឬការវិភាគទៅលើផលប៉ះពាល់ និងការតាមដាន ការវាយតម្លៃភាពងាយរងគ្រោះ ការវាយតម្លៃរូបភាពលំហរអាកាស និងចំណេះដឹងផ្នែកទន់ដ៏មានសារៈសំខាន់ដូចជាប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ជាដើម។ ជារួម សំណូមពរលើប្រធានបទបណ្តុះបណ្តាលចាប់ពីចំណេះដឹងមូលដ្ឋានគ្រឹះការប្រែប្រួលអាកាសធាតុរហូតដល់ទទួលបានចំណេះដឹងជំនាញការស្រាវជ្រាវក្នុងវិស័យផ្សេងៗ៖

- មូលដ្ឋានគ្រឹះនៃការប្រែប្រួលអាកាសធាតុ
- ការបន្សាំ និងការកាត់បន្ថយប្រែប្រួលអាកាសធាតុ

- យុទ្ធសាស្ត្រការប្រែប្រួលអាកាធាតុ
- ការគ្រប់គ្រងកាកសំណល់ និងការបំពុលខ្យល់
- ម៉ូដែលអាកាសធាតុ
- វិធីសាស្ត្រក្នុងការស្រាវជ្រាវការប្រែប្រួលអាកាសធាតុ
- ការប្រែប្រួលអាកាធាតុ និងសុវត្ថិភាពស្បៀងអាហារ
- ការភិរក្សជីវចម្រុះ
- ការគ្រប់គ្រងសត្វល្អិតចង្រៃ
- ការសរសេរសំណើស្នើសុំមូលនិធិ
- ការសរសេរបែបវិទ្យាសាស្ត្រ

## ប្រទេសកម្ពុជា៖ និស្សិត

និស្សិតចំនួនបីក្រុម មកពីសកលវិទ្យាល័យខុសៗគ្នាចំនួនបីបានចូលរួមក្នុងការផ្តល់សម្ភាស ជាពិសេសនិស្សិតចំនួន ១៤ នាក់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ៧ នាក់ មកពីសាកលវិទ្យាល័យហេង សំរិន ត្បូងឃ្មុំ និង ១៤ នាក់មកពីសាកលវិទ្យាល័យស្វាយរៀង ជាសរុបមានអ្នកចូលរួម ៣៥ នាក់។ ជាលទ្ធផលទទួលបានពីការសម្ភាសបានបង្ហាញថា មុខវិជ្ជាសិក្សាស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងកម្មវិធីសិក្សាថ្នាក់អនុបណ្ឌិតមានដូចជា៖និរន្តរភាពកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិបានផ្តល់ដោយសាកលវិទ្យាល័យ។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធីសិក្សាការប្រែប្រួលអាកាសធាតុពេញលេញមិនទាន់មាននៅឡើយ។ សិក្ខាសាលាដែលមានប្រធានបទពាក់ព័ន្ធ ការប្រែប្រួលអាកាសធាតុ ក៏អាចចូលរួមសិក្សាបានពីពេលមួយទៅពេលមួយទៀតនៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យហេង សំរិនត្បូងឃ្មុំ និងសាកលវិទ្យាល័យស្វាយរៀង។ កង្វះខាតសម្ភារបរិក្ខារៀនសូត្រ និងអត្ថបទស្រាវជ្រាវពាក់ព័ន្ធជាភាសាជាតិត្រូវបានលើកឡើងថាជាឧបសគ្គដល់ដំណើរការសិក្សានិងបង្កើនការយល់ដឹង។

ចំពោះទស្សនៈយល់ឃើញរបស់និស្សិត មានចំណាប់អារម្មណ៍ទៅលើប្រធានបទពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅមានកម្រិត ដោយយោងលើតម្រូវការទីផ្សារការងារទាបរបស់កម្ពុជា។ ទោះជាយ៉ាងណា តម្រូវការមានការកើនឡើងត្រូវបានគេកត់សម្គាល់។ ឧបសគ្គមួយផ្សេងទៀតដែលត្រូវបានគេលើកឡើង និងចាត់ទុកថាអនុវត្តន៍បានសម្រាប់ការសិក្សានោះគឺ ថ្លៃសិក្សាខ្ពស់ និងទីតាំងសាកលវិទ្យាល័យទាំងអស់ស្ថិតនៅក្នុងទីក្រុងធំៗប៉ុណ្ណោះ។ ហេតុដូច្នេះ ហើយទើប

យុវជនដែលរស់នៅតាមតំបន់ជនបទមិនមានឱកាសដូចគ្នាទៅនឹងនិស្សិតដែលរស់នៅក្នុងទីក្រុង ដែលខ្វះខាតអាហារូបករណ៍ និងសម្ភារសិក្សាក្នុងការទទួលបានការអប់រំបានខ្ពស់សម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប។

ទាក់ទងនឹងប្រសិទ្ធភាពនៃកម្មវិធីក្នុងការរៀបចំនិស្សិតឱ្យទទួលបានជោគជ័យក្នុងអាជីពនាពេលអនាគតនៅក្នុងវិស័យការប្រែប្រួលអាកាសធាតុ តាមការយល់ឃើញបង្ហាញថាប្រធានបទទាំងនេះនៅតែទូលំទូលាយពេក និងមានតែទ្រឹស្តីប៉ុណ្ណោះ។ ជំនាញ និងការប្រើប្រាស់ឧបករណ៍ជាក់លាក់បន្ថែមទៀតត្រូវបានទាមទារដោយអ្នកសិក្សាវ័យក្មេងដើម្បីរៀបចំឱ្យបានជោគជ័យដល់ពួកគេសម្រាប់ទីផ្សារការងារ។ ការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចពីការបាត់បង់ និងសឹករេចរិលព្រៃឈើ (REDD+) យន្តការអភិវឌ្ឍន៍ស្អាត (CDM) ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) សេវាកម្មបរិស្ថាន ការវិភាគគោលនយោបាយ ម៉ូដែលអាកាសធាតុ ដើម្បីវិភាគការប្រែប្រួលអាកាសធាតុ និងកាបូនស្តុក ម៉ូដែលសម្រាប់វាយតម្លៃនៃការទូទាត់សេវាកម្មបរិស្ថាន ផែនការប្រើប្រាស់ដី និងផែនការគ្រប់គ្រងដី ការអភិរក្សតំបន់ដីសើមជាប្រធានបទដែលលើកឡើងពីអ្នកចូលរួម។ ការពិនិត្យឡើងវិញនៃវិធីសាស្ត្របង្រៀន និងការបកប្រែលើសម្ភារបង្រៀនជាភាសាជាតិ គឺជាតម្រូវការចាំបាច់ផងដែរ។ កង្វះខាតឧបករណ៍ និងមន្ទីរពិសោធន៍ ជាកត្តារារាំងដល់វិធីសាស្ត្រអនុវត្តន៍ជាក់ស្តែងដើម្បីទទួលបានជំនាញបច្ចេកទេសដែលត្រូវបានគេគិតថាសំខាន់ជាងនៅក្នុងការបង្រៀនបែបទ្រឹស្តីជាមួយនឹងបទបង្ហាញដោយប្រើស្លាយបញ្ចាំង និងសៀវភៅ។

ចំនួនស្ថាប័នស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ កំពុងរីកលូតលាស់បន្តិចម្តងៗនៅក្នុងប្រទេស ដែលបង្កើតអោយមានឱកាសការងារបន្ថែមសម្រាប់និស្សិតដែលបានបញ្ចប់ការសិក្សាវ័យក្មេង ក៏មានការយកចិត្តទុកដាក់ពីអន្តរជាតិ និងបញ្ហាបការប្រែប្រួលអាកាសធាតុដែលជាឥទ្ធិពលដល់ការលើកកម្ពស់ការយល់ដឹងអំពីទំនាក់ទំនង ការប្រែប្រួលអាកាសធាតុ និងតម្រូវការដោះស្រាយបញ្ហាភ្លាមៗ។ ដូច្នេះ និស្សិតអាចមើលឃើញឱកាសជោគជ័យមកដល់សម្រាប់មុខរបរដែលមានសក្តានុពលនៅក្នុងវិស័យនេះ។ បណ្តាញសាកលវិទ្យាល័យ និងវិស័យឯកជនត្រូវបានបើកឱ្យដំណើរការដោយមានកម្មវិធីផ្លាស់ប្តូរកម្មសិក្សាដែល មើលឃើញថាមិនគ្រប់គ្រាន់ដើម្បីបង្កើតជាមូលដ្ឋានដ៏រឹងមាំមួយចូលទៅក្នុងទីផ្សារការងារនេះទេ។ ជាថ្មីម្តងទៀត នៅពេលដែលកម្មវិធីនេះមានឥទ្ធិពលជាវិជ្ជមានក្នុងការចាប់ផ្តើមសហការដោយជោគជ័យជាមួយក្រុមហ៊ុន និងអង្គការខាងក្រៅ និស្សិតនឹងរកឃើញថាចំណុចចន្លោះប្រហោងរបស់ពួកគេនៅកន្លែងការងារ។ ទោះបីជាកម្មវិធីអាហារូបករណ៍និងជំនួយក៏នៅតែមិនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវ

ការនោះ តារាងបញ្ជីឱកាសទទួលបានអាហារូបករណ៍ត្រូវបានផ្តល់ដោយស្ថាប័នសាធារណៈព្រម ទាំងអង្គការអន្តរជាតិ៖

**វិស័យសាធារណៈ**

- ក្រសួងបរិស្ថាន (MoE)
- ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA)
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)

**វិស័យឯកជន**

- កម្មវិធីសិក្សាថ្នាក់បណ្ឌិត: សាកលវិទ្យាល័យណាហ្គោយ៉ា (ជប៉ុន), ចនអាលហ្វ្រេហ៍ (ប្រទេសអូស្ត្រាលី)
- វិនរ៉ក់អន្តរជាតិ Winrock International
- ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ(USAID)
- មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអាស៊ីអាគ្នេយ៍ (CSEAS)
- អង្គការអភិរក្សត្រីពិភពលោក (World Fish)
- មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR)
- សាកលវិទ្យាល័យក្យូតូ (ប្រទេសជប៉ុន)
- អង្គការអភិរក្សសត្វព្រៃ (WCS)
- អង្គការអន្តរជាតិត្រូពិច (ITTO)

## ប្រទេសឡាវ ៖ អាជ្ញាធរជាតិ និងវិស័យឯកជន

មានតំណាងក្រុម ១២ រូប មកពីអាជ្ញាធរជាតិ និងវិស័យឯកជន ជាពិសេសអ្នកផ្តល់ជំនួយអន្តរជាតិបានចូលរួមក្នុងកិច្ចពិភាក្សានេះ។ ដោយសារតែមិនអាចប្រមូលអ្នកចូលរួមសម្ភាសជាក្រុមបាន ក្រុមអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានជាតិសម្រាប់ស្រាវជ្រាវសេដ្ឋកិច្ច (NIER) បានធ្វើកិច្ចសម្ភាសយ៉ាងស៊ីជម្រៅជាបុគ្គល ឬជាក្រុមតូចៗនៅពេលណាដែលអាចធ្វើបាន។

### ទស្សនៈ និងការយល់ដឹង

ភាគច្រើននៃប្រជាជនឡាវ (៧០%) បានធ្វើការងារនៅក្នុងវិស័យកសិកម្ម (ផលិតកម្មស្រូវ) ឬអនុវត្តន៍កសិកម្មចិញ្ចឹមជីវិត។ វិស័យនេះរងផលប៉ះពាល់យ៉ាងខ្លាំង និងងាយទទួលរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុជាមួយនឹងផលវិបាកយ៉ាងធ្ងន់ធ្ងរទៅលើស្ថេរភាពសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍជាតិ។ ស្ថានភាពអាកាសធាតុធ្ងន់ធ្ងរ និងគ្រោះមហន្តរាយជាច្រើនត្រូវបានចុះបញ្ជីរួចហើយក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដែលបានធ្វើអោយខូចខាតដល់ផលិតកម្មកសិកម្មជាតិ និងជីវភាពរស់នៅរបស់សហគមន៍ជនបទ។

- ទឹកជំនន់បានបំផ្លាញផលដំណាំដែលមិនទាន់បានប្រមូលផលរួច ការចិញ្ចឹមសត្វ កន្លែងទុកដាក់ស្រូវ ប្រព័ន្ធធារាសាស្ត្រ និងបានរួមចំណែកធ្វើឱ្យកើនឡើងសត្វល្អិតរុក្ខជាតិចង្រៃ និងជម្ងឺសត្វបន្ថែម។
- គ្រោះរាំងស្ងួតបានបំផ្លិតបំផ្លាញដំណាំ បណ្តាលឱ្យមានការពន្យារពេលក្នុងការដាំដំណាំដោយសារតែខ្វះទឹក និងរួមចំណែកដល់ការកើនឡើងសត្វល្អិត (ឧទាហរណ៍សត្វកណ្តូប) រុក្ខជាតិ និងជំងឺសត្វ។ នៅក្នុងតំបន់រាំងស្ងួតបំផុត និងក្នុងរយៈពេលនេះស្មៅសម្រាប់សត្វចិញ្ចឹមមិនគ្រប់គ្រាន់ ជាលទ្ធផលកសិករនិងអ្នកបង្កាត់ពូជត្រូវតែស្វែងរកចំណីបន្ថែម តម្លៃទៅលើការចំណាយប្រចាំឆ្នាំដែលលើសជាងរាល់ឆ្នាំ។
- ភ្លៀងធ្លាក់លាយព្យុះនិងខ្យល់កន្ត្រាក់បង្កឱ្យមានទឹកជំនន់ធ្ងន់ធ្ងរ និងការបាក់ដីដែលបំផ្លាញដីស្រែចំការនិងសត្វចិញ្ចឹម។

តំបន់ទេសចរណ៍សំខាន់ៗនៅក្នុងប្រទេសមានដូចជា៖ ប្រាសាទ និងតំបន់ប្រវត្តិសាស្ត្រទេសភាពត្រូពិច ទឹកជ្រោះ និងរូងភ្នំ។ តាមលទ្ធផលសម្ភាសបានបង្ហាញថា ផលវិបាកនៃការប្រែប្រួលអាកាសធាតុមិនទាន់មានប៉ះពាល់ខ្លាំងខ្លាដល់វិស័យទេសចរណ៍ក្នុងស្រុកនៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ ទឹកជំនន់ ការរអិលបាក់ដី និងភាពរាំងស្ងួតមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសកម្មភាពទេសចរណ៍ដោយធ្វើអោយបណ្តាញផ្លូវថ្នល់ខូចខាតដែលអាចរាំងដល់ដំណើរទស្សនកិច្ចទៅកាន់តំបន់ដែលមានផលប្រយោជន៍ខាងវប្បធម៌។ ម្យ៉ាងវិញទៀត ភាពរាំងស្ងួតបណ្តាលឱ្យមានកម្រិតទឹកទាប នៅកន្លែងទឹកធ្លាក់មួយចំនួន ដែលបង្កើតបានជាការទាក់ទាញដ៏សំខាន់មួយសម្រាប់ភ្ញៀវទេសចរណ៍មកទស្សនាប្រទេសឡាវ។ លើសពីនេះទៀត ការរួមបញ្ចូលគ្នានៃរយៈពេលរាំងស្ងួតយូរអង្វែងនិងសកម្មភាពកសិកម្មពនេចរ ជាការរួមចំណែកដល់ការកើនឡើងនូវភ្លើងឆេះព្រៃដែលបង្កឱ្យមានផលប៉ះពាល់ដល់ធម្មជាតិ និងវិស័យព្រៃឈើ។ ជំងឺឆ្លង

តាមរយៈទឹក និងសត្វល្អិតបានរីករាលដាលនៅពេលមានគ្រោះរាំងស្ងួត និងទឹកជំនន់បានជះឥទ្ធិពលអវិជ្ជមានទៅលើការលូតលាស់ព្រៃឈើ និងផលិតភាព។ លើសពីនេះទៅទៀត ការបាត់បង់ជីវចម្រុះបានផ្តល់ផលវិបាកលើតុល្យភាពដែលមានលក្ខណៈឃើតយ៉ាវដល់ប្រព័ន្ធអេកូឡូស៊ី។

លក្ខខណ្ឌអាកាសធាតុធ្ងន់ធ្ងរ និងគ្រោះមហន្តរាយធម្មជាតិដែលទទួលឥទ្ធិពលដោយសារការប្រែប្រួលអាកាសធាតុបានប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដូចជា៖ ការខូចខាតផ្លូវថ្នល់ និងបណ្តាញទំនាក់ទំនង បណ្តាញបញ្ជូនអគ្គិសនី ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋដូចជា៖ ប្រព័ន្ធធារាសាស្ត្រនៅក្នុងតំបន់ និងអាគារឯកជន ក៏ដូចជាការអប់រំសាធារណៈ និងសេវាកម្មសុខភាព ការផ្គត់ផ្គង់ទឹក និងបញ្ហាអនាម័យ។ លើសពីនេះទៀត ដោយពិចារណាលើការពឹងផ្អែកខ្លាំងសម្រាប់ការផ្គត់ផ្គង់ថាមពលជាតិលើទំនប់វារីអគ្គិសនី ការប្រែប្រួលនៃវដ្តជលសាស្ត្រដែលបណ្តាលមកពីការកើតមាននៃលក្ខខណ្ឌអាកាសធាតុធ្ងន់ធ្ងរ គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់វិស័យថាមពលផងដែរ។

ផលវិបាកដោយផ្ទាល់នៃការខូចខាតដែលបានលើកឡើងនោះ ជាការរួមចំណែកដ៏ធំនៃថវិការដ្ឋចូលទៅក្នុងសំណង់និងការកសាងឡើងវិញ ការផ្តល់ហិរញ្ញប្បទានមានកំណត់ដែលរកបានសម្រាប់គោលដៅចម្បងផ្សេងទៀតរបស់ប្រទេសជាតិ ដូចជាការកាត់បន្ថយភាពក្រីក្រ។ ជាការពិតណាស់ កសិករមានផលប៉ះពាល់ច្រើនជាងគេទៅការបង្កបង្កើនផលរហូតដល់ ៧០% នៃប្រជាជន ហើយវិស័យកសិកម្មចូលរួមចំណែកដ៏សំខាន់នៃផលិតកម្មជាតិ។ សកម្មភាពសេដ្ឋកិច្ច និងការដឹកជញ្ជូនទំនិញនៅក្នុងប្រទេសបានទទួលរងផលប៉ះពាល់ដោយការរំខានការសាងសង់ផ្លូវថ្នល់ និងការបំផ្លាញបណ្តាញអគ្គិសនី។ ការរាតត្បាតបន្ទាប់ពីគ្រោះមហន្តរាយមានដូចជាទឹកជំនន់ និងភាពរាំងស្ងួត បង្កើនការចំណាយរបស់ជាតិទៅលើវិស័យសុខាភិបាលហើយក្នុងករណីខ្លះនាំឱ្យបាត់បង់ជីវិត។ ផ្អែកលើការស៊ើបអង្កេតបច្ចុប្បន្ន បានបង្ហាញ ថាក្នុងចំណោមអាជ្ញាធរ និងការយល់ដឹងរបស់វិស័យឯកជនទៅលើការប្រែប្រួលអាកាសធាតុ មានលក្ខណៈទូលំទូលាយ និងការយល់ដឹងពីផលវិបាករបស់វាយ៉ាងច្បាស់លាស់និងស៊ីជម្រៅ។ ទោះជាយ៉ាងណាក៏ដោយ កម្រិតនៃភាពធ្ងន់ធ្ងរ ពេលវេលាជាក់លាក់ និងលក្ខខណ្ឌអាកាសធាតុធ្ងន់ធ្ងរនៅតែជាបញ្ហាលំបាកក្នុងការទាយទុកមុន ហេតុនេះហើយមានតែការពារប៉ុណ្ណោះ។

តាមរយៈកសិករឡាវមិនមានចំណេះដឹងខាងវិទ្យាសាស្ត្រអំពី ការប្រែប្រួលអាកាសធាតុក៏ដោយ ពួកគេបានដឹងច្បាស់ថាអាកាសធាតុកំពុងប្រែប្រួលមិនអំណោយផល ហើយប៉ះពាល់អវិជ្ជមានដល់ជីវភាពរស់នៅរបស់ពួកគេ។ សីតុណ្ហភាពកំពុងកើនឡើង របបទឹកភ្លៀងបានផ្លាស់ប្តូរ ទឹក

ជំនន់ ភាពរាំងស្ងួត ព្យុះ និងការរអិលបាក់ដី ការរីករាលដាលនៃជម្ងឺបាននឹងកំពុងបន្តកើតឡើងញឹកញាប់ជាងមុន។ ពួកគេទទួលស្គាល់ថា ត្រូវសម្របខ្លួនទៅនឹងការផ្លាស់ប្តូរបែបនេះ។ ទោះជាយ៉ាងណា រហូតមកដល់ពេលនេះការឆ្លើយតបរបស់ពួកគេមិនមានប្រសិទ្ធភាពដោយសារចំណេះដឹងមានកម្រិតនៃយុទ្ធសាស្ត្របន្ស៊ុំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

រដ្ឋាភិបាលឡាវ មានការយល់ដឹងកាន់តែច្រើន ថាប្រទេសនេះងាយនឹងរងគ្រោះខ្លាំងណាស់ទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅឆ្នាំ ២០០៨ គណៈកម្មាធិការដឹកនាំថ្នាក់ជាតិស្តីពីយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើងដើម្បីបង្កើតទម្រង់យុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ កម្មវិធីនិងគម្រោងសម្រាប់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ នៅក្រោមការចង្អុលបង្ហាញពីគណៈដឹកនាំថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសចំនួន ៨ នាក់ ដែលមានមន្ត្រីតំណាងក្រសួងពាក់ព័ន្ធនិងភាគីពាក់ព័ន្ធត្រូវបានបង្កើតឡើង។ នៅឆ្នាំ ២០០៩ ការប្រែប្រួលអាកាសធាតុ រួមបញ្ចូលជាកាតព្វកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មាធិការបរិស្ថានជាតិដែលបានដឹកនាំដោយឧបនាយករដ្ឋមន្ត្រី។ នៅឆ្នាំដដែលនោះ កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុលើកទី១ (NAPA) ត្រូវបានបង្កើតឡើង។ នៅក្នុងឯកសាររបស់ កម្មវិធីសកម្មភាពបន្សាំថ្នាក់ជាតិលើកទី ១ នេះវិស័យចំនួន ៤ រួមមាន (កសិកម្ម ព្រៃឈើ ធនធានទឹក និងសុខភាពសាធារណៈ) ត្រូវបានកំណត់ថាជាវិស័យដែលត្រូវការការបន្សុំជាបន្ទាន់។ ជាពិសេសសម្រាប់វិស័យព្រៃឈើ រដ្ឋាភិបាលបានណែនាំគោលនយោបាយកំណត់ការកាប់បំផ្លាញព្រៃឈើ និងការអនុវត្តកសិកម្មពនេចរ។ លើសពីនេះទៀតសារៈសំខាន់នៃការដោះស្រាយបញ្ហាប្រឈមដែលបង្កើតឡើងដោយការប្រែប្រួលអាកាសធាតុបានរួមបញ្ចូល និងពិភាក្សានៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ៥ ឆ្នាំម្តង លើកទី៧ របស់ឡាវចាប់តាំងពីឆ្នាំ ២០១១ ។

សម្រាប់វិស័យជាអាទិភាពជាតិលើការស្រាវជ្រាវ និងការអភិវឌ្ឍ គ្រប់ក្រសួងទាំងអស់សុទ្ធតែមានវិទ្យាស្ថានស្រាវជ្រាវផ្ទាល់ខ្លួនដែលមានជំនាញខាងវិស័យ ដែលទាក់ទងទៅនឹងមុខងាររបស់ក្រសួងនីមួយៗ។ ដូច្នេះ ការពិបាកក្នុងការធ្វើសេចក្តីសម្រេចចិត្តថាវិស័យណាខ្លះដែលយកចិត្តទុកដាក់សំខាន់ទៅលើការស្រាវជ្រាវ និងការអភិវឌ្ឍគោលនយោបាយជាតិ។ យ៉ាងណាក៏ដោយបើនិយាយអោយទូលំទូលាយសកម្មភាពរបស់រដ្ឋាភិបាលឡាវគឺផ្តោតសំខាន់ទៅលើការបញ្ចប់ការសិក្សាពីប្រទេសក្រីក្របំផុតដោយដោះស្រាយការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍធនធានមនុស្ស និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច។ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ការខិតខំ

ប្រឹងប្រែងភាគច្រើន គឺផ្តោតលើការត្រួតពិនិត្យ និងទប់ស្កាត់ហានិភ័យសម្រាប់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ និងការកសាងហេដ្ឋារចនាសម្ព័ន្ធធំៗថ្មីនៅពេលដែលមិនចាំបាច់ថែរក្សាបរិស្ថានក្នុងភាពសំបូរបែប និងភាពស្រស់បំព្រង។

## សមត្ថភាពថ្នាក់ជាតិស្តីពី R&D និងតួនាទីវិស័យឯកជន

ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលទៅលើវិស័យជាច្រើននៅលើផ្នែកសេដ្ឋកិច្ចថ្នាក់មូលដ្ឋាន ការវាយតម្លៃផលប៉ះពាល់របស់វាតម្រូវឱ្យមានការចូលរួមរវាងគ្រប់ស្ថាប័នរដ្ឋាភិបាលជាច្រើន និងភាគីពាក់ព័ន្ធ។ ក្រសួងនីមួយៗវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅតាមផ្នែករបស់ខ្លួន ដែលទទួលខុសត្រូវ បន្ទាប់ដាក់ជូនរបាយការណ៍វាយតម្លៃនោះទៅឱ្យក្រសួងបរិស្ថាន និងធនធានធម្មជាតិ (MoNRE) មានការិយាល័យរបស់ខ្លួនដែលដើរតួនាទីជាអាជ្ញាធរជាតិយន្តការអភិវឌ្ឍន៍ស្អាត ឬស្ថាប័នជាតិគោលសម្រាប់ (UNFCCC) ដែលទទួលខុសត្រូវក្នុងការចងក្រង និងផលិតរបាយការណ៍សម្រាប់សេចក្តីជូនដំណឹងជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ បញ្ជីរាយនាមឈ្មោះក្រសួងដែលចូលរួមក្នុងការវាយតម្លៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុមានដូចជា៖

- ក្រសួងកសិកម្ម និងរុក្ខាប្រមាញ់
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងសាធារណការ
- ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម
- ក្រសួងសុខាភិបាល
- ក្រសួងអប់រំ និងកីឡា
- ក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ក្រសួងការងារ និងសុខុមាលភាពសង្គម (ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ)

នាពេលបច្ចុប្បន្នទាក់ទងទៅនឹងការចែករំលែកព័ត៌មានដែលប្រមូលបាន និងការស្វែងរកព័ត៌មានដែលមានមិនទាន់មានជាទម្រង់ (Platform) ឌីជីថលសាធារណៈដើម្បីសម្របសម្រួលក្នុងការផ្តល់ប្រឹក្សា និងផ្លាស់ប្តូរព័ត៌មាននោះទេ។ ក្នុងករណីខ្លះ ក្រសួងពាក់ព័ន្ធនីមួយៗ ធ្វើការប្រមូលព័ត៌មាន ដាក់ឱ្យដំណើរការ រក្សាទុកនិងថែរក្សាព័ត៌មានទាក់ទងនឹង CC នៅក្នុងផ្នែកដែលខ្លួនទទួលខុសត្រូវតែប៉ុណ្ណោះ។ យ៉ាងណាក៏ដោយនាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែ

ប្រួលអាកាសធាតុ (DDMC) នៅក្រោមក្រសួងបរិស្ថាន និធនធានធម្មជាតិទទួលបានព័ត៌មានថ្មីៗអំពីការប្រែប្រួលអាកាសធាតុពីក្រសួងនីមួយៗ អាស្រ័យដូចនេះព័ត៌មានដែលអាចរកបានភាគច្រើនទាក់ទងនឹងការប្រែប្រួលអាចយកចេញពី DDMC។ ប្រភពផ្សេងទៀតដែលត្រូវបានប្រើប្រាស់ជាទូទៅ គឺគេហទំព័របណ្តាអង្គការអន្តរជាតិ និងស្ថាប័នស្រាវជ្រាវ និងបរិស្ថាន។ ការចូលរួមរបស់វិស័យឯកជនក្នុងសកម្មភាព R&D ថ្នាក់ជាតិក្នុងផ្នែកការប្រែប្រួលកាសធាតុ(ការបន្សាំ និងការកាត់បន្ថយ) នៅមានកម្រិតនៅឡើយសកម្មភាពរបស់ស្ថាប័នឯកជនក្នុង ស្រុក និងអន្តរជាតិភាគច្រើនផ្តោតលើវិស័យថាមពលតាមរយៈការកសាងភាពជាដៃគូដើម្បីអភិវឌ្ឍន៍គម្រោងវារីអគ្គិសនីដែលជាប្រភពថាមពលកកើតឡើងវិញ និងអាកាសធាតុល្អ (climate-friendly)។ អ្នកអភិវឌ្ឍន៍វារីអគ្គិសនីជាញឹកញាប់ចូលរួមចំណែកក្នុងការការពារទីជម្រាលដោយសារតែតម្រូវការទឹកក្នុងការផលិតវារីអគ្គិសនី។ ប្រភេទមួយទៀតនៃថាមពលកកើតឡើងវិញដែលឡាវឱ្យឈ្មោះថា Sunlabob កំពុងប្រើ គឺថាមពលពន្លឺព្រះអាទិត្យ (ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ PV ប្រព័ន្ធកម្តៅដោយពន្លឺព្រះអាទិត្យ)។ នៅក្នុងវិស័យទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ដំណើរផ្សងព្រេង និងអេកូទេសចរណ៍មួយហៅឈ្មោះថា Green Discover ប្រទេសឡាវបានទទួលយកវិធីសាស្ត្រដោយមានការចូលរួមសម្រាប់អាជីវកម្មរបស់ខ្លួន។ វាផ្តល់ការងារដល់ប្រជាពលរដ្ឋក្នុងតំបន់នៅកន្លែងដែលក្រុមហ៊ុនទេសចរណ៍ត្រូវបានផ្តល់ជូន។ ប្រភពចំណូលថ្មីទាំងនេះបានលើកទឹកចិត្តប្រជាពលរដ្ឋក្នុងតំបន់ឱ្យចូលរួមក្នុងការការពារព្រៃឈើ ការដាំដើមឈើឡើងវិញ និងកាត់បន្ថយសកម្មភាពប្រមាញ់សត្វព្រៃរបស់ពួកគេ។ ឧបសគ្គចម្បងៗ ក្នុងការចូលរួមរបស់វិស័យឯកជននៅក្នុង R&D សម្រាប់ CC គឺផ្នែកហិរញ្ញវត្ថុមានកម្រិតរួមជាមួយនឹងសមត្ថភាពធនធានមនុស្ស និងបច្ចេកវិទ្យាដែលមាននៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃ CC នៅក្នុងវិស័យកសិកម្ម និងព្រៃឈើ។ កង្វះអ្នកជំនាញក្នុងការវាយតម្លៃ CC ក៏ជះឥទ្ធិពលដល់វិស័យសាធារណៈដែលបុគ្គលិកភាគច្រើនបានទទួលចំណេះដឹងអំពី CC តាមរយៈការធ្វើការលើគម្រោង និងកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី (រៀបចំវេទិកា និង សិក្ខាសាលា) ដែលភាគច្រើនត្រូវបានផ្តល់ដោយម្ចាស់ជំនួយអន្តរជាតិ ឬដៃគូដែលគ្រប់គ្រងគម្រោងតែប៉ុណ្ណោះ។ លើសពីនេះទៀត ការរៀបចំពីមន្ត្រីមូលដ្ឋាន គឺផ្តោតសំខាន់លើទ្រឹស្តីជាជាងការអនុវត្តជាក់ស្តែងដែលទាមទារទីប្រឹក្សាពីខាងក្រៅដើម្បីគ្រប់គ្រងគម្រោងស្រាវជ្រាវទាក់ទងទៅនឹងនឹង CC ។ ការបណ្តុះបណ្តាលដល់អ្នកជំនាញក្នុងស្រុកដោយមានការអនុវត្តផ្ទាល់លើការស្រាវជ្រាវ និងជំនាញការសរសេរច្បាស់លាស់បានក្លាយទៅជាអាទិភាពមួយដោយយោងទៅលើការសម្ភាសពីអ្នកចូលរួមដើម្បីបង្កើតជាមូលដ្ឋានគ្រឹះរឹងមាំក្នុងការជម្រុញ R&D លើ CC នៅថ្នាក់ជាតិ។

## ហិរញ្ញប្បទាន និងធនធាន

ចាប់តាំងពីឆ្នាំ ២០០០ មក មានគោលនយោបាយផែនការសកម្មភាព និងកម្មវិធីមួយចំនួនត្រូវបានដាក់ចេញដោយរដ្ឋាភិបាល និងដាក់ចេញនូវទីភ្នាក់ងារដូចជា៖

- របាយការណ៍ជាតិលើកទី១ស្តីការប្រែប្រួលអាកាសធាតុផ្ញើទៅកាន់ UNFCCC-សាធាណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (២០០០)
- របាយការណ៍ជាតិលើកទី២ស្តីការប្រែប្រួលអាកាសធាតុផ្ញើទៅកាន់ UNFCCC-សាធាណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (២០១៣)
- កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (២០០៩)
- យុទ្ធសាស្រ្តថ្នាក់ជាតិទៅនឹងការប្រែប្រួលអាកាសធាតុនៃសាធាណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (២០១០)
- ផែនការសកម្មភាពទៅនឹងការប្រែប្រួលអាកាសធាតុសាធាណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ(២០១៣
- ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេល ៥ឆ្នាំ លើកទី៨ (២០១៦)

មកដល់ពេលបច្ចុប្បន្ន យុទ្ធសាស្រ្តថ្នាក់ជាតិស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានធ្វើសមាហរណកម្មទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេល៥ឆ្នាំលើកទី ៨ (NSEDP) ឆ្នាំ២០១៦-២០២០ ដែលគ្របដណ្តប់លើគ្រប់វិស័យទាំងអស់នៃផ្នែកសេដ្ឋកិច្ច។ ដោយផ្អែកទៅលើ NSEDP តាមក្រសួងនីមួយៗបង្កើតផែនការអនុវត្ត និងផែនការការងារប្រចាំឆ្នាំរបស់ពួកគេហើយតម្រូវឱ្យដាក់ជូននូវរបាយការណ៍ចុងបញ្ចប់នៃការអនុវត្ត។ ប្រសិទ្ធភាពនៃការអនុវត្ត NSEDP ត្រូវបានរងឥទ្ធិពលយ៉ាងខ្លាំងដោយសារការស្វែងរកមូលនិធិ។ ដោយសារគោលបំណងចម្បងរបស់រដ្ឋាភិបាលឡាវ គឺការប្រែក្លាយប្រទេសខ្លួនពីប្រទេសអភិវឌ្ឍន៍តិចតួចត្រឹមឆ្នាំ ២០២៥ ហើយអាទិភាពបច្ចុប្បន្នរបស់ខ្លួន គឺបង្កើនសេដ្ឋកិច្ច អភិវឌ្ឍន៍ធនធានមនុស្ស និងលើកកម្ពស់សុខភាពសាធារណៈដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការប្រែក្លាយប្រទេសខ្លួន។ ជាលទ្ធផលនេះមានមូលនិធិសាធារណៈតិចតួចដែលអាចរកបានសម្រាប់ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។ ជាលទ្ធផលប្រទេសឡាវត្រូវបន្តពឹងផ្អែកលើម្ចាស់ជំនួយអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាសម្រាប់ការគាំទ្រលើការផ្តល់ហិរញ្ញប្បទានដល់សកម្មភាព និងការស្រាវជ្រាវលើការកាត់បន្ថយ និងបន្សាំការប្រែប្រួលអាកាសធាតុ។ ការគាំទ្រត្រូវបានផ្តល់ឱ្យក្នុងទម្រង់ជាហិរញ្ញប្បទាន ការកសាងសមត្ថភាព

និង កម្មវិធីសម្បទានសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធន់ទ្រាំនឹងអាកាសធាតុ។ ជំនួយហិរញ្ញវត្ថុត្រូវបានចែកចាយក្នុងចំណោមវិស័យសំខាន់ៗជាពិសេសវិស័យកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដី ការគ្រប់គ្រងធនធានទឹក ថាមពល និងការដឹកជញ្ជូន និងការអភិវឌ្ឍទីក្រុង។ ម្ចាស់ជំនួយអន្តរជាតិសំខាន់ៗនិងដៃគូអភិវឌ្ឍន៍ដែលបានផ្តល់មូលនិធិដល់សកម្មភាពពាក់ព័ន្ធនឹងអាកាសធាតុនៅក្នុងប្រទេសឡាវមានដូចខាងក្រោម៖

- ធនាគារពិភពលោក
- មូលនិធិអភិវឌ្ឍន៍ Nordic (NDF)
- សហភាពអឺរ៉ុប
- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)
- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
- ក្រសួងសហព័ន្ធអាឡឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍតាមរយៈ GIZ/kfw

ចាប់តាំងពីឆ្នាំ ២០១៣ រដ្ឋាភិបាលឡាវបានត្រៀម ១% នៃថវិកាសរុបបានមកពីការវិនិយោគសាធារណៈរបស់ខ្លួនសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ទូទៅ។ ទោះជាយ៉ាងណាក៏ដោយ បរិមាណនេះមិនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការនោះទេ។ ដូច្នេះជំនួយហិរញ្ញវត្ថុពីខាងក្រៅនៅតែជាប្រភពមូលនិធិដ៏សំខាន់សម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ នៅក្នុងប្រទេសឡាវ។ ក្រុមហ៊ុនឯកជនមួយចំនួនបានផ្តល់មូលនិធិខ្លះសម្រាប់ការស្រាវជ្រាវក្នុងផ្នែកដែលគេមានចំណាប់អារម្មណ៍ ជាទូទៅសកម្មភាពស្រាវជ្រាវរបស់ពួកគេរួមមាន៖ ការកាប់ឈើ ការនាំចេញផលិតផលកសិកម្ម ការអភិរក្សពពួករុក្ខជាតិ និងសត្វព្រៃក្នុងស្រុក។ ក្នុងករណីទាំងនេះរដ្ឋាភិបាលដើរតួជាអ្នកសម្របសម្រួលសម្រាប់ការបែងចែកមូលនិធិតាមរយៈក្រសួងដែលទទួលខុសត្រូវ។

## ប្រទេសឡាវ៖ ការអប់រំ

ក្រុមមួយដែលមានសមាជិក ២៤នាក់ មកពីមហាវិទ្យាល័យផ្សេងៗនៃសាកលវិទ្យាល័យជាតិឡាវ (NUOL) និងសាកលវិទ្យាល័យសុផានុវង្ស (SU) បានចូលរួមក្នុងការសិក្សានេះ។ វិសាលភាពនៃអ្នកចូលរួមមានចាប់ពីមហាវិទ្យាល័យវិទ្យាសាស្ត្របរិស្ថាន ដល់មហាវិទ្យាល័យនយោបាយ និង

ច្បាប់។ ការស្រាវជ្រាវទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វាទៅលើបរិស្ថានក្នុងមូលដ្ឋានត្រូវបានផ្តោតទៅលើ៖

- ជីវៈចម្រុះ
- ផលិតកម្មកសិកម្ម និងបញ្ហាទាក់ទងទៅនឹងធារាសាស្ត្រ
- ការគ្រប់គ្រងព្រៃឈើ និងការការពារ
- មានការតាំងចិត្តក្នុងការបង់សម្រាប់សេវាកម្មបរិស្ថាន

ការសិក្សាស្រាវជ្រាវត្រូវបានផ្តល់ហិរញ្ញប្បទានជាចម្បងដោយម្ចាស់ជំនួយអន្តរជាតិ និងថវិការដ្ឋជាពិសេសក្នុងចំណោមអង្គការអន្តរជាតិ ធនាគារពិភពលោក មូលនិធិតូយ៉ូតា អង្គការអន្តរជាតិនៃហ្វ្រង់កូហ្វូនី (Agency Intergovernmental de la Francophonie) (AIF), មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC), REDD+ ត្រូវបានគេដាក់ឈ្មោះ។ នៅកម្រិតថ្នាក់រដ្ឋចំណែកនៃថវិកាជាតិត្រូវបានបែងចែកសម្រាប់ការស្រាវជ្រាវ ហើយវាត្រូវបានបែងចែករវាងក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្រសួងអប់រំ និងក្រសួងបរិស្ថាន និងធនធានធម្មជាតិ។ ជាធម្មតាថវិកាជាតិត្រូវបានគេដាក់ឱ្យអនុវត្តន៍បន្ទាប់ពីមានការដាក់គម្រោងសំណើរស្រាវជ្រាវពីអ្នកស្រាវជ្រាវជាលក្ខណៈបុគ្គល ឬ ពីក្រុមអ្នកស្រាវជ្រាវ។ ភាគច្រើនការស្រាវជ្រាវនៅកម្រិតសាកលវិទ្យាល័យ គឺត្រូវបានអភិវឌ្ឍន៍នៅក្នុងក្របខណ្ឌនៃវិន័យជាក់លាក់មួយខណៈពេលនៅកម្រិតអន្តរជាតិវិធីសាស្ត្រពហុជំនាញ គឺមានការប្រើប្រាស់ច្រើនជាង។ អតុល្យភាពរវាងចំនួនអ្នកស្រាវជ្រាវជាស្ត្រី និងបុរសនៅតែមានដែលបណ្តាលមកពីការរៀបចំនាសម្ព័ន្ធសង្គមតម្រូវឱ្យស្ត្រីត្រូវបានលើកទឹកចិត្តឱ្យមានកូនជាជាងបន្តការសិក្សារបស់ពួកគេ។ ជាទូទៅប្រធានក្រុមស្រាវជ្រាវនេះ គឺជាអ្នកមានតួនាទី ឬជាសាស្ត្រាចារ្យរងមួយរូបដែលបានរៀបចំការសិក្សាទាំងមូលផងដែរ។ ជាទូទៅ និស្សិតកម្រិតក្រោយឧត្តម និងបរិញ្ញាបត្រជាន់ខ្ពស់ជាមានតួនាទីជួយក្នុងការប្រមូលទិន្នន័យ។ ជាធម្មតា ការងារក្នុង ក្រុម និងតួនាទីត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានទំនាក់ទំនងជាបុគ្គល ឬលើការចាប់អារម្មណ៍ និងជំនាញពិតប្រាកដរបស់អ្នកស្រាវជ្រាវដើម្បីចូលរួមក្នុងការសិក្សា។ គ្មានការណែនាំជាផ្លូវការដល់ក្រុម ឬនីតិវិធីផ្លូវការណាមួយដែលមានការបោះឆ្នោត និងចងក្រងជាក្រុម ហេតុដូចនេះទំនងជាក្រុមដែលធ្វើការលើគម្រោងមួយអាចផ្លាស់ប្តូរក្នុងអំឡុងពេលនៃការសិក្សាហើយអ្នកចូលរួមធ្វើការភាគច្រើនចូលរួមសម្រាប់កិច្ចការដែលបានដាក់ដោយអ្នកគ្រប់គ្រងការស្រាវជ្រាវជាជាងដោយស្វយ័ត និងឯករាជ្យ។ នៅពេលដែលសមាសភាគមួយនៃក្រុមចង់អនុវត្តន៍ជំហានបន្ថែមទៀតនោះ ពួកគាត់ត្រូវតែទទួលការយល់ព្រមពីប្រធានក្រុមជាមុន

សិន។ ការធ្វើបែបនេះ គឺត្រូវបានប្រើទៅលើក្រុមស្រាវជ្រាវមួយចំនួន។ តាមការសិក្សាបានបង្ហាញថាក្រុមអ្នកស្រាវជ្រាវផ្តោតលើបញ្ហាការប្រែប្រួលអាកាសធាតុមិនទាន់ត្រូវបានបង្កើតឡើងនោះទេ។ តាមពិតទៅ នាពេលបច្ចុប្បន្នសាស្ត្រាចារ្យមានការចូលរួមច្រើនក្នុងការបង្រៀនទៅលើប្រធានបទទាំងនេះតាមរយៈទ្រឹស្តីជាជាងធ្វើការស្រាវជ្រាវដោយផ្ទាល់។ ទាក់ទងទៅនឹងទិន្នន័យ ពួកគេអាចរកបាននៅលើគេហទំព័ររបស់បណ្តាក្រសួង ទោះជាយ៉ាងនេះក៏ដោយពួកគេមានការលំបាកក្នុងដំណើរការចុចចូលមើលនៅក្នុងគេហទំព័រនោះ ដោយសេរីដោយសារវាមិនបានផ្តល់លក្ខណៈងាយស្រួលសម្រាប់អ្នកប្រើប្រាស់ ហើយព័ត៌មានមួយចំនួននៅមិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការងារស្រាវជ្រាវឡើយ។ បញ្ជីរាយនាមឈ្មោះប្រធានបទមានសក្តានុពលដើម្បីធ្វើការសិក្សាបានមកពីការផ្តល់សម្ភាសរបស់អ្នកចូលដូចជា៖

- ផលប៉ះពាល់នៃការបង្កើតទំនប់វារីអគ្គិសនី
- ផលប៉ះពាល់នៃការដាំចម្ការចេកនៅក្នុងប្រទេសឡាវបានផ្តល់ហិរញ្ញប្បទានដោយអ្នកវិនិយោគចិន
- ផលប៉ះពាល់នៃការដាំចម្ការកៅស៊ូនៅក្នុងប្រទេសឡាវ
- ផលប៉ះពាល់នៃការរុករករ៉ែនៅក្នុងប្រទេសឡាវ
- តម្លៃ និងអត្ថប្រយោជន៍នៃការដាំព្រៃនៅក្នុងប្រទេសឡាវ
- ផលប៉ះពាល់នៃទឹកជំនន់
- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើម៉ាក្រូ និងមីក្រូអេកូឡូស៊ីនៅមូលដ្ឋាន

ជាទូទៅ កត្តាដែលកំណត់លើការសស្រាវជ្រាវ និងការអភិវឌ្ឍស្តីពីកាប្រែប្រួលអាកាសធាតុគឺប្រភពហិរញ្ញវត្ថុហើយថវិការដ្ឋមានកំណត់ដែលជាទូទៅត្រូវបានប្រើប្រាស់សម្រាប់គម្រោងជាតិតាមតម្រូវការចាំបាច់ របស់ក្រសួងសាមីដែលទទួលខុសត្រូវ ហើយវាមានការពិបាកក្នុងការទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការស្រាវជ្រាវនៅកម្រិតសាកលវិទ្យាល័យ។ គម្លាតនៅផ្នែកអប់រំនេះដោយសាតែសមត្ថភាពមិនទាន់គ្រប់គ្រាន់ទាក់ទងនឹងចំណេះដឹងផ្នែកខាងក្រៅលើប្រធានបទនេះ និងជំនាញភាសាដែលចាំបាច់សម្រាប់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រការបោះពុម្ពផ្សាយដ៏មានសក្តានុពល និងការផ្លាស់ប្តូរទិន្នន័យ។ ការចែករំលែកទិន្នន័យគ្នាហាក់បីដូចជាមានការពិបាកពីព្រោះគ្មានបណ្តាញរឹងមាំត្រូវបានបង្កើតឡើងរវាងគ្រឹះស្ថានឧត្តមសិក្សាផ្សេងៗគ្នា ហើយការផ្លាស់ប្តូរព័ត៌មានភាគច្រើនពឹងផ្អែកលើទំនាក់ទំនងផ្ទាល់ជាលក្ខណៈបុគ្គល និងតាមកិច្ចសហការពីមុនៗមកតាមរយៈគម្រោងផ្សេងៗ។ កង្វះទិន្នន័យដែលគួរឱ្យជឿទុកចិត្តជាផ្លូវការក៏ប៉ះ

ពាល់ដល់ការអភិវឌ្ឍន៍នៃការសិក្សាផងដែរ ដោយសារដំណើរការប្រមូលទិន្នន័យបឋមមានតម្លៃថ្លៃដែលជាទូទៅតម្រូវឱ្យអ្នកចូលរួមធ្វើការងារដោយមិនទទួលបានថវិកា ពីព្រោះថវិកាមានកំណត់។ អ្វីដែលបានលេចឡើងថ្មីនៅក្នុងការស៊ើបអង្កេតនោះគឺការពិតដែលវិធីសាស្រ្តពហុ និងវិធីសាស្រ្តចម្រុះមិនត្រូវបានប្រើជាទូទៅ ហើយវិធីសាស្រ្តជាក់លាក់មួយជាមួយបានប្រើដោយយកការពិចារណាតិចតួចអំពីតំណភ្ជាប់ពាក់ព័ន្ធទៅវិស័យផ្សេងៗទៀត។ តួនាទីរបស់និស្សិតក្នុងការស្រាវជ្រាវនៅមានកម្រិតចំពោះការប្រមូលទិន្នន័យពួកគេមិនបានចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំការស្រាវជ្រាវនោះទេដោយសារតែចំណេះដឹងរបស់ពួកគេអំពីប្រធានបទដែលត្រូវធ្វើការស្រាវជ្រាវនៅមានកង្វះខាត ហើយមិនទាន់ដឹងវិធីសាស្រ្តស្រាវជ្រាវដែលគួរយកមកប្រើ។ គ្រូបង្រៀនវ័យក្មេងត្រូវការបង្កើនជំនាញភាសារបស់ពួកគេ និងការសរសេរបែបវិទ្យាសាស្រ្ត និងការពន្យល់ក៏ដូចជាការអនុវត្ត និងការសិក្សាលើវិធីសាស្រ្តស្រាវជ្រាវដែលសមស្របបំផុតសម្រាប់បញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពទាំងនេះអាចត្រូវបានធ្វើការជម្រុញតាមរយៈការបង្កើននូវបណ្តាញ និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នស្រាវជ្រាវអន្តរជាតិ និងគម្រោងផ្សេងៗ។

ជាចុងក្រោយអ្នកចូលរួមក្នុងក្រុមពិភាក្សាបានផ្តល់យោបល់លើប្រធានបទមួយចំនួនសម្រាប់ការបណ្តុះបណ្តាល៖

- ការកៀរគរធនធាននិងការសរសេរគម្រោងសំណើស្រាវជ្រាវសម្រាប់ដាក់ស្នើសុំមូលនិធិ
- វិធីសាស្រ្តស្រាវជ្រាវក្នុងការវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ
- វគ្គបណ្តុះបណ្តាលលើសូហ្វវែរស្ថិតិវិទ្យា ឧ.កម្មវិធីស្ថិតិវិទ្យា R

## ប្រទេសឡាវ៖ និស្សិត

អ្នកចូលរួមចំនួន ៥ នាក់មកពីសាកលវិទ្យាល័យជាតិឡាវ (NUOL) និង ១៦ នាក់មកពីសាកលវិទ្យាល័យសុផានូវង្ស (SU) បានចូលរួមក្នុងការស្រាវជ្រាវនេះដើម្បីរួមចំណែកដល់ការវាយតម្លៃស្ថានភាព R&D កម្រិតថ្នាក់ជាតិលើការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសឡាវ។ តាមរយៈការសម្ភាសបានបង្ហាញថាមានកម្មវិធីយុវជនមួយចំនួនដូចជា "គម្រោង SEED" ដែលលើកកម្ពស់ការអភិរក្សបរិស្ថានដែលជាកត្តាចម្បងសម្រាប់សង្គមឱ្យបានល្អជាមួយការបង្រៀនអំពីបរិស្ថាន ការសម្អាតតំបន់ទីសាធារណៈ។ មុខវិជ្ជាមួយចំនួនបង្រៀននៅក្នុងមហាវិទ្យាល័យវិទ្យាសាស្រ្តបរិស្ថានដូចជា៖ ផែនការប្រើប្រាស់ដី បរិស្ថាន និងការអភិវឌ្ឍ និងគោលនយោបាយបរិស្ថាននៅសាកល

វិទ្យាល័យជាតិឡាវ។ នៅក្នុង SU មហាវិទ្យាល័យសេដ្ឋកិច្ច និងទេសរចណ៍បង្រៀនមុខវិជ្ជាដែលយកចិត្តទុកដាក់លើការការពារបរិស្ថាន នៅក្នុងផែនការសកម្មភាពទេសចរណ៍ និងនៅក្នុងមហាវិទ្យាល័យស្ថាបត្យកម្ម ផលប៉ះពាល់នៃការសាងសង់អគារទៅលើជម្រកដែលមានស្រាប់ក៏ជាផ្នែកមួយនៃកម្មវិធីសិក្សាដែរ។ ទោះជាយ៉ាងណាក៏ដោយ ការបង្រៀនមានកម្រិត ហើយផ្តោតខ្លាំងទៅលើបរិស្ថាន និងមិនបានដាក់ឱ្យច្បាស់លាស់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ នៅពេលមានសិក្ខាសាលា ឬមុខវិជ្ជាពិសេសទៅលើប្រធានបទការប្រែប្រួលអាកាសធាតុ និស្សិតទទួលបានព័ត៌មានពីគេហទំព័ររបស់សាកលវិទ្យាល័យដែលជាទូទៅគេហទំព័រនោះមិនបានកែលម្អ។

មិនមានកិច្ចសហការរវាងមហាវិទ្យាល័យ និងវិស័យឯកជននៅលើផ្នែកការប្រែប្រួលអាកាសធាតុតាំងពីដើមមកនោះទេ ហើយនិស្សិត បរិញ្ញាបត្រជាន់ខ្ពស់ ភាគច្រើនស្វែងរកការងារនៅក្នុងស្ថាប័នរដ្ឋាភិបាល ឬតាមការិយាល័យរបស់ក្រសួងដែលទទួលខុសត្រូវលើការវាយតម្លៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងរៀបចំយុទ្ធសាស្ត្របន្សាំ និងកាត់បន្ថយ។ តាមទស្សនៈរបស់និស្សិតតាមក្រុមហ៊ុនឯកជនមិនតម្រូវឱ្យមានជំនាញជាឯកទេសលើការប្រែប្រួលអាកាសធាតុនោះទេ។

កម្មវិធី និងវគ្គបណ្តុះបណ្តាលអប់រំ នៅមានលក្ខណៈមិនទាន់ស៊ីជម្រៅរួមជាមួយឯកសារបង្រៀនមិនទាន់គ្រប់គ្រាន់ និងវិធីសាស្ត្របង្រៀនមិនទាន់គ្រប់គ្រាន់ផងដែរ។ ជារួម ហេដ្ឋារចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យផ្តល់សេវាកម្មនៅមានកម្រិតសម្រាប់និស្សិតទីតាំងដែលមាន និងឧបករណ៍ផងដែរ។ ឧទាហរណ៍៖ និស្សិតមិនអាចប្រើប្រាស់ Wi-Fi របស់សាលាបាន។ យោងតាមចំណេះដឹងរបស់អ្នកចូលរួមផ្តល់សម្ភាសបានបង្ហាញថាមិនមានអាហារូបករណ៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុនោះទេទៅតាមកម្មវិធីដែលមាននោះទេ។

## ប្រទេសវៀតណាម៖ អាជ្ញាធរមូលជាតិ និងវិស័យឯកជន

មន្ត្រីតំណាងសរុបចំនួន ១៥ រូប មកពីនាយកដ្ឋានកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន ជលវិទ្យា ឧតុនិយម និងការប្រែប្រួលអាកាសធាតុ គណៈកម្មាធិការថ្នាក់ស្រុក និងម្ចាស់ជំនួយអន្តរជាតិបានចូលរួមក្នុងការសម្ភាស។ គោលការណ៍ណែនាំសម្រាប់ការសម្ភាសត្រូវបានបែងចែកជា ៣ ផ្នែកសំខាន់ ដូចនេះ ការបង្ហាញទិន្នន័យនឹងធ្វើតាមលំដាប់ និងតាមរចនាសម្ព័ន្ធនេះ។

## ទស្សនៈ និងការយល់ដឹង

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជាច្រើនត្រូវបានសង្កេតឃើញហើយបានសិក្សារួចមក ហើយនៅក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាម។ វិស័យដែលទទួលផលប៉ះពាល់ខ្លាំងជាងគេ គឺវិស័យធនធានទឹក និងកសិកម្ម។ ជាពិសេស៖

- ការជ្រៀតចូលនៃទឹកប្រៃបានធ្វើឱ្យប៉ះពាល់ដល់ផលិតកម្មរុក្ខជាតិសម្រាប់កសិកម្ម និង ធនធានទឹកដែលមានសម្រាប់ការបង្កាត់ពូជ។
- ការបាក់ដីបានបំផ្លាញប្រព័ន្ធបង្ហូរទឹកនៅតំបន់ដីសណ្តទន្លេមេគង្គ។
- លក្ខខណ្ឌអាកាសធាតុធ្ងន់ធ្ងរ៖ ភ្លៀងមានរយៈពេលយូរមិនបានរំពឹងទុក ភាពរាំងស្ងួត និងព្យុះទីហ្វុងមិនទៀងទាត់បានបំផ្លាញដំណាំជាពិសេសនៅតំបន់ Sunken នៅក្បែរ សមុទ្រ។ ផលវិបាកធ្ងន់ធ្ងរជាច្រើនត្រូវបានគេសង្កេតតាំងពីឆ្នាំ ២០១៤ មកម្លេះ ។
- ដោយសារភាពរាំងស្ងួតមានបាតុភូតមួយចំនួននៃការកកអំបិលនៅក្នុងដីស្រែដែល បានកាត់បន្ថយផ្ទៃដីដាំដុះសម្រាប់ដំណាំកសិកម្ម និងចម្ការព្រៃឈើ។
- ការកើនឡើងសីតុណ្ហភាពក៏ដូចជារដូវរងារកាន់តែមានរយៈពេលយូរបានផ្លាស់ប្តូរ ប្រតិទិនដាំដុះ និងរចនាសម្ព័ន្ធដំណាំ ដែលកាត់បន្ថយទិន្នផលដំណាំ។ អាស្រ័យដូច នេះ វាពិបាកក្នុងការទស្សន៍ទាយ និងរៀបចំផែនការដាំដុះសមស្របនៅក្នុងមួយឆ្នាំៗ ដោយមិនឱ្យមានការខូចខាតដំណាំសម្រាប់ការប្រមូលផលចុងក្រោយនោះទេ។
- ការផ្លាស់ប្តូរនៃវដ្តជលសាស្ត្រដែលធ្លាប់ទៀងទាត់បានធ្វើឱ្យតំបន់មួយចំនួនស្ងួតហើយ បានផ្អាកផលិតកម្ម ក្នុងស្រុក។
- ការជ្រៀតចូលនៃទឹកសមុទ្រ គំរាមកំហែងដល់ប្រតិបត្តិការធម្មតានៃសកម្មភាព ឧស្សាហកម្មដែលស្ថិតនៅតំបន់ឆ្នេរនិងមន្ទីរពេទ្យចាប់តាំងពីធ្វើឱ្យច្រេះបំពង់ដែក និង ប្រព័ន្ធត្រជាក់។

ក្រៅពីវិស័យកសិកម្ម និងធនធានទឹក ការប្រែប្រួលអាកាសធាតុ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ លើវិស័យដទៃទៀតដែលជាវិស័យមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចប្រទេសជាតិ។ ឧទាហរណ៍ ៖ ក្នុងវិស័យទេសចរណ៍ការថយចុះអ្នកទេសចរប្រចាំឆ្នាំត្រូវបានសង្កេតឃើញមាននៅតាមតំបន់ ខ្លះដោយសារការជ្រៀតចូលទឹកប្រៃ ព្យុះ និងការបាត់បង់ជីវចម្រុះ។ ការខូចខាតមិនត្រូវបានធ្វើការ កំណត់កម្រិត ផ្លូវថ្នល់ និងសរសៃអាកទែធំៗ ក៏ត្រូវបានប៉ះពាល់ផងដែរដោយសារព្យុះធំៗ និងការ

បាក់ដីមិនទៀងទាត់។ ភាពភ័យខ្លាចនៃលក្ខខណ្ឌធាតុអាកាសធាតុធ្ងន់ធ្ងរក៏ប៉ះពាល់ដល់វិស័យទេសចរណ៍អន្តរជាតិផងដែរ ហើយបានថយចុះនូវភ្ញៀវទេសចរនៅក្នុងតំបន់។ សមាសភាគទាំងអស់នេះបានធ្វើឱ្យមានការខាតបង់ផ្នែកសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់និងមានការវិនិយោគខ្ពស់ក្នុងការជួសជុល និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍។ ព្រៃឈើបង្កើតបានជាបេតិកភ័ណ្ឌធម្មជាតិសម្រាប់ប្រទេសទាក់ទងនឹងការទាក់ទាញភ្ញៀវទេសចរ ការអភិរក្សជីវចម្រុះ និងផលិតផល។ បាតុភូតធាតុអាកាសធ្ងន់ធ្ងរបានបំផ្លិចបំផ្លាញព្រៃដាំតាមរយៈព្យុះខ្លាំង និងភ្លើងឆេះព្រៃដោយសារធាតុអាកាសក្តៅខ្លាំង។ ទន្ទឹមនឹងនេះភាពរាំងស្ងួតរយៈពេលយូរបានប៉ះពាល់ដល់ការដាំព្រៃឡើងវិញ និងការលូតលាស់នៃកូនឈើបន្ទាប់ពីដាំរួច។ ការជ្រៀតចូលទឹកប្រៃជាមូលហេតុបណ្តាលឱ្យមានផលវិបាកធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ និងហេដ្ឋារចនាសម្ព័ន្ធ។ កាត់បន្ថយភាពសម្បូរបែបនៃធនធានជលផលដោយសារប្រព័ន្ធទំនប់វារីអគ្គិសនី ដែលទប់ស្កាត់រំហូរពីខ្សែទឹកខាងលើចូលទៅក្នុងបឹងទឹកប្រៃក្បែរមាត់សមុទ្រ។ ទឹកប្រៃធ្វើឱ្យសឹករេចរិលសំណង់ ទំនិញ និងទ្រង់ទ្រាយភូមិសាស្ត្រដែលទាមទារការវិនិយោគសំខាន់ៗពីថវិកាជាតិ ឧទាហរណ៍៖ ការបាក់ដី ១គីឡូម៉ែត្របណ្តាលឱ្យខូចខាតដល់ ៧ ពាន់លានដុង (២៥០ 000 € ca) ដើម្បីសាងសង់ជញ្ជាំង និងជួសជុលទំនប់តូចៗដែលខូចខាត។ ប្រព័ន្ធថែទាំសុខភាពស្ថិតនៅក្រោមសម្ពាធបន្ទាប់ពីមានទឹក ជំនន់ធំៗឬ ព្យុះខ្លាំងៗដោយសារតែការកើនឡើងនៃជំងឺស្បែក ជំងឺគ្រុនឈាម និងជំងឺឆ្លងតាមទឹកផ្សេងៗទៀត។ ដោយសារទំហំព្រឹត្តការណ៍ធាតុអាកាសធ្ងន់ធ្ងរខ្លាំងទ្រព្យសកម្មរបស់ប្រជាពលរដ្ឋក្នុងតំបន់ត្រូវបានរងការខូចខាតជាបន្តបន្ទាប់ ឬជះឥទ្ធិពលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងអាជីវកម្ម។ ផលវិបាកនៃសេដ្ឋកិច្ចសង្គមទាំងអស់នេះតម្រូវឱ្យមានការវិនិយោគសំខាន់ៗពីថវិកាជាតិដែលអាចជំនួសឱ្យការអភិវឌ្ឍសេដ្ឋកិច្ច និងសុខុមាលភាពសង្គម។

លទ្ធផលទទួលបានពីសម្ភាសន៍បានបង្ហាញថា តួអង្គទាំងអស់ដែលចូលរួមក្នុងវិស័យកសិកម្ម ព្រៃឈើ ទេសចរណ៍និងវិស័យដទៃទៀតមានការយល់ដឹងពីផលប៉ះពាល់ ដែលមានសក្តានុពលពីការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន។ ទោះបីជាយ៉ាងណា ភាពមិនប្រាកដប្រជាអំពីប្រសិទ្ធភាពនៃសកម្មភាពបន្សាំ និងការកាត់បន្ថយដែលត្រូវធ្វើឡើងដោយសារវាមិនទាន់មានភាពច្បាស់លាស់នៅឡើយទេថាតើអ្វីនឹងជាបញ្ហាធ្ងន់ធ្ងរក្នុងរយៈពេលវែង។ ខេត្តនៅតាមដីសណ្តទន្លេមេគង្គត្រូវរងឥទ្ធិពលដោយផ្ទាល់ពីការប្រែប្រួលអាកាសធាតុ។ នៅក្នុងខេត្ត Ben Tre រដ្ឋាភិបាលបានអនុវត្តន៍គម្រោងដែលមានឈ្មោះថា "ប្រព័ន្ធធារាសាស្ត្រភាគខាងជើងខេត្ត Ben Tre" ដើម្បីកសាងប្រព័ន្ធធារាសាស្ត្រទំនប់តូចៗសម្រាប់ស្រុកចំនួន ៥ របស់ខ្លួន។ ប្រសិនបើមិនមានគម្រោងនោះទេ ផលិតកម្មកសិកម្មរបស់ខេត្ត Ben Tre នឹងមានដែនកំណត់ និងមិនមានការអភិវឌ្ឍន៍។

ទោះជាយ៉ាងណា បើទោះបីជាគម្រោងបែបនេះត្រូវបានអនុវត្តន៍ដើម្បីបញ្ចៀសផលប៉ះពាល់ភ្លាមៗ ដោយផ្ទាល់ក៏ទាមទារការអនុវត្តគោលនយោបាយរយៈពេលវែងដើម្បីឆ្លើយតបប្រកបដោយ ប្រសិទ្ធភាពនៃផលវិបាកមកពីការប្រែប្រួលអាកាសធាតុ។ ការយល់ដឹងជាសាធារណៈនៅមាន កម្រិតចំពោះប្រជាជនដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការប្រែប្រួលនេះ ខណៈពេលដែលអ្នក មិនទទួលរងឥទ្ធិពលនៅខ្វះចំណេះដឹងអំពីបញ្ហាដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រុមហ៊ុនធំៗ និងអ្នកផលិតហាក់ដូចជាមានផែនការច្បាស់លាស់ ហើយបានរៀបចំផែនការ សកម្មភាពឆ្លើយតបក្នុងការប្រឈមនឹងបញ្ហានោះ និងកាត់បន្ថយការខាតបង់សេដ្ឋកិច្ច។ នៅ កម្រិតគោលនយោបាយ រដ្ឋាភិបាលជាតិបានរៀបចំកម្មវិធី និងអន្តរាគមន៍ដើម្បីឆ្លើយតបបញ្ហានេះ ដោយប្រើចំហាកការប្រែប្រួលអាកាសធាតុ ផ្សេងៗគ្នាសម្រាប់ប្រទេសទាំងមូល និងអន្តរាគមន៍ ជាក់លាក់បន្ថែមទៀតសម្រាប់តំបន់រងផលប៉ះពាល់ញឹកញាប់ដូចជាករណីនៅក្នុងខេត្តដែលមាន ដីសណ្តជាដើម។ បណ្តាស្ថាប័នថ្នាក់ជាតិដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល សកម្មភាពចាំបាច់ដើម្បីដោះស្រាយជាមួយ ការប្រែប្រួលអាកាសធាតុ តាមរយៈការត្រួតពិនិត្យ តាមដាន (ប្រព័ន្ធព្យាករ និងការកំណត់អត្តសញ្ញាណវិស័យដែលងាយរងគ្រោះ) និងការដាក់ បញ្ចូលបញ្ហាការប្រែប្រួលអាកាសធាតុក្នុងអន្តរាគន៍គោលនយោបាយនៅក្នុងវិស័យនីមួយៗ។ ការផ្តោតសំខាន់លើការស្រាវជ្រាវ និងការអនុវត្តស្តីពីការប្រែប្រួលអាកាសធាតុមានដូចជា៖

- វាយតម្លៃផលប៉ះពាល់ និងទំហំនៃការប្រែប្រួលអាកាសធាតុ
- ការពង្រឹងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ការអភិវឌ្ឍ និងលើកកម្ពស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ
- កសាងចំហាកការប្រែប្រួលអាកាសធាតុ និងលក្ខខណ្ឌអាកាសធាតុធ្ងន់ធ្ងរ
- ការព្យាករធាតុអាកាស ប្រព័ន្ធប្រកាសអាសន្ន
- អភិវឌ្ឍន៍ម៉ូដែលបន្សាំសម្រាប់កសិកម្មនៅមូលដ្ឋាន
- ដាក់បញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធីសិក្សាសម្រាប់សិស្សនិស្សិតនៅ គ្រប់កម្រិតនៃការអប់រំ
- បណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីលើកកម្ពស់ធនធានមនុស្សសម្រាប់ស្ថាប័នស្រាវជ្រាវ និង អភិវឌ្ឍន៍
- ធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាលដើម្បីបំពេញតាមតម្រូវការរបស់អង្គការ ក្រុមហ៊ុន និងស្ថាប័នឯកជន និងសាធារណៈពាក់ព័ន្ធនឹងផ្នែកនេះ។

## សមត្ថភាពថ្នាក់ជាតិលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងតួនាទីវិស័យឯកជន

នៅកម្រិតស្ថាប័ន អង្គភាពរដ្ឋាភិបាលមួយចំនួនចូលរួមនៅក្នុងការវាយតម្លៃនៃការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅលើកម្រិតជាតិ និងកម្រិតសកល។ បញ្ជីរាយនាមឈ្មោះស្ថាប័ន និងតួនាទីរបស់ពួកគេនៅក្នុងជំនាញនេះមានដូចខាងក្រោម៖

- ក្រសួងធនធានធម្មជាតិ និងបរិស្ថាន៖ ការវាយតម្លៃផលប៉ះពាល់ និងការព្យាករ។
- ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ៖ រៀបចំផែនការ និងអភិវឌ្ឍន៍យុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងផលិតកម្មកសិកម្ម។
- ក្រសួងផែនការ និងវិនិយោគ៖ ការគ្រប់គ្រង និងបែងចែកមូលនិធិសម្រាប់ការអនុវត្ត និងការគាំទ្រដល់កម្មវិធី និងគម្រោងទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ។
- ក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា៖ ការកសាង និងជ្រើសរើសការស្រាវជ្រាវជាអាទិភាពទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍន៍កម្មវិធីបច្ចេកវិទ្យា។
- មជ្ឈមណ្ឌលព្យាករឧតុនិយម៖ ជលសាស្ត្រថ្នាក់ជាតិទទួលបន្ទុកក្នុងការត្រួតពិនិត្យលើការវាយតម្លៃ

នៃការត្រួតពិនិត្យតាមដានបរិស្ថានរួមទាំងផ្តល់ការព្យាករអំពីឧតុនិយម-ជលសាស្ត្រ និងឧត្តុភូតវិទ្យាសមុទ្រ ត្រួតពិនិត្យតាមដានការប្រែប្រួលអាកាសធាតុ និងវាយតម្លៃនិន្នាការអាកាសធាតុ ធ្វើសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍លើការស្រាវជ្រាវ និងការព្យាករឧតុនិយម ជលសាស្ត្រ សមុទ្រ ព្រមទាំងត្រួតពិនិត្យតាមដាន និងវាយតម្លៃ និងធ្វើការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍អំពីព័ត៌មានអាកាសធាតុ និងធាតុអាកាស។

ក្រសួងធនធានធម្មជាតិ និងបរិស្ថាន និងមជ្ឈមណ្ឌលព្យាករឧតុនិយម-ជលសាស្ត្រ គឺជាប្រភពព័ត៌មានយ៉ាងសំខាន់សម្រាប់វិស័យឯកជន និងសាធារណៈ។ ពួកគេអាចផ្តល់ជូនដូចជា៖

- ព័ត៌មានទូទៅពីធាតុអាកាសកាលពីអតីតកាល
- ចំហាកការប្រែប្រួលអាកាសធាតុ និងព្យាករពីឥទ្ធិពលអាកាសធាតុ
- ទិន្នន័យឧត្តុនិយមសម្រាប់តំបន់ជាក់លាក់ណាមួយ
- ប្រព័ន្ធប្រកាសអាសន្នអំពីបាតុភូតធាតុអាកាសធ្ងន់ធ្ងរ
- ម៉ូដែលដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

ជាទូទៅ វិស័យឯកជនមិនបានរួមចំណែកឱ្យបានជាក់លាក់ក្នុងផ្នែកការស្រាវជ្រាវ និងការអភិវឌ្ឍ សម្រាប់ការប្រែប្រួលអាកាសធាតុនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ មានក្រុមហ៊ុនឯកជនធំៗ មួយចំនួនកំពុងធ្វើការជាមួយស្ថាប័នជាតិដូចជា៖ ក្រុមហ៊ុន Loc Troi ក្រុមហ៊ុន Phuong Hoang ដែលលះបង់ថវិកាមួយផ្នែករបស់ពួកគេចំពោះការ បង្កើតការងារ និងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ស្ថាប័នរដ្ឋ និងភ្នាក់ងារគ្រប់គ្រងបានបង្កើតបណ្តាញមួយជាមួយវិស័យឯកជនដើម្បីសម្របសម្រួល និងអនុវត្តន៍ផែនការសកម្មភាព សម្រាប់ការបន្សាំទៅនឹង ការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ចំណេញដែលនៅសល់ ជាកត្តាជម្រុញដ៏សំខាន់ក្នុងដំណើរការធ្វើការសម្រេចចិត្តរបស់ភាគីពាក់ព័ន្ធនៃវិស័យឯកជន។ ហេតុដូច្នេះដែនកំណត់នៃការចែករំលែកថវិការបស់ពួកគេសម្រាប់ចូលទៅលើការស្រាវជ្រាវ និងរៀបចំផែនការក្នុងការដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្នុងរយៈពេលយូរ។ ក្នុងន័យនេះ ការយល់ដឹងនៅមានកម្រិត អំពីផលវិបាកនៃសេដ្ឋកិច្ចដែលមានសក្តានុពលដើរតួយ៉ាងសំខាន់ផងដែរ អាស្រ័យហេតុនេះ វាមានសារៈសំខាន់ណាស់ក្នុងការចូលរួម និងជូនដំណឹងដល់ក្រុមហ៊ុនឯកជនអំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុព្រមទាំងប៉ះពាល់ ដល់ប្រាក់ចំណេញរបស់ពួកគេនាពេលអនាគត។ ម៉្យាងទៀត នៅពេលដែលឥទ្ធិពលរបស់វាបង្ហាញច្បាស់ កង្វះខាតធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាល និងការអនុវត្តការប្រើបច្ចេកវិទ្យាជំនួសរារាំងដល់សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ជាទូទៅ មានការខ្វះខាតធនធានមនុស្ស និងអ្នកឯកទេសជំនាញលើ ការប្រែប្រួលអាកាសធាតុ។ បញ្ហានេះត្រូវបានគេសង្កេតឃើញនៅក្នុងការិយាល័យរបស់ក្រសួងធនធានធម្មជាតិ និងបរិស្ថានផងដែរ។ នៅតាមបណ្តាខេត្ត មុខវិជ្ជាវគ្គបណ្តុះបណ្តាលស្តីពីផលប៉ះពាល់ពី ការប្រែប្រួលអាកាសធាតុត្រូវបានគេធ្វើឡើងជារៀងរាល់ឆ្នាំ។ ក្រុមគោលដៅ គឺបុគ្គលិកសំខាន់ៗរបស់សាលាខេត្ត មន្ត្រីផ្នែកសុរិយោដី បរិស្ថាន និងប្រជាពលរដ្ឋជាពិសេសនៅតំបន់ដែលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុរួចមកហើយ។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅមុខវិជ្ជាទាំងនេះមានរយៈពេលតែមួយវគ្គ ឬមួយថ្ងៃ ហេតុដូចនេះមាតិកា គឺផ្តោតលើទ្រឹស្តីជាជាងការអនុវត្តជាក់ស្តែង។ កត្តាមួយទៀត គឺដោយសារតែថវិកាមានកម្រិតជាពិសេសនៅក្នុងរដ្ឋបាលថ្នាក់មូលដ្ឋាន អ្នកតំណាងសាធារណៈជាញឹកញាប់ ទទួលខុសត្រូវលើនាយកដ្ឋានជាច្រើនដែលធ្វើឱ្យពិបាកក្នុងការតាមដានបញ្ហានិងលើកកម្ពស់ដំណោះស្រាយឱ្យបានគ្រប់គ្រាន់។ ជួនកាលមន្ត្រីទាំងនេះមិនមានសមត្ថភាពលើប្រធានបទនេះទេ ហើយភារកិច្ចរបស់ពួកគេមាននៅក្នុងការអនុវត្តសកម្មភាព និងយន្តការដែលមកពីរដ្ឋាភិបាលថ្នាក់កណ្តាល។

## ការផ្តល់ហិរញ្ញប្បទាន និងប្រភពសម្រាប់ស្រាវជ្រាវ និងការអនុវត្តការប្រែប្រួលអាកាសធាតុ

មានគោលនយោបាយ និងផែនការសកម្មភាពបានដាក់ចេញដោយរដ្ឋាភិបាលជាច្រើនឆ្នាំមុនមក ហើយទាក់ទងនឹងយុទ្ធសាស្ត្រកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព។ ផែនការអន្តរាគមន៍ដែលបានដាក់ចេញផ្តោតទៅលើសង្គមគ្រប់ជាន់ថ្នាក់ខុសៗគ្នា និងវិស័យសេដ្ឋកិច្ចជាច្រើន។ បន្ថែមពីនេះទៀត ចំហាកការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតជាទ្រឹស្តីក្នុងការប្រមើលមើលពីការប្រែប្រួលរហូតដល់ចុងសតវត្សទី២១។ បញ្ជីរាយឈ្មោះគោលនយោបាយ និងកិច្ចអន្តរាគមន៍មួយចំនួនមានដូចខាងក្រោម៖

- ដំណោះស្រាយ២៤/NQ/TW(២០១៣) លើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់គណៈ កម្មាធិការថ្នាក់កណ្តាលនៃបណ្តាភាគី។
- យុទ្ធសាស្ត្រជាតិទៅនឹងការប្រែប្រួលអាកាសធាតុ ២០១១។
- ផែនការសកម្មភាពជាតិលើការប្រែប្រួលអាកាសធាតុ ២០១១-២០២០
- យុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង(២០១២)
- ផែនការអភិវឌ្ឍន៍បៃតង(២០១៤)

មានច្បាប់ជាច្រើនទាក់ទងទៅនឹងបន្សាំការប្រែប្រួលអាកាសធាតុ(ច្បាប់ស្តីពីការការពារបរិស្ថាននៅឆ្នាំ២០១៤ ច្បាប់ស្តីពីការការពារ និងការបង្ការគ្រោះមហន្តរាយធម្មជាតិក្នុងឆ្នាំ ២០១៣ ច្បាប់ស្តីពីធនធានទឹកក្នុងឆ្នាំ ២០១២ ច្បាប់ស្តីពីជីវចម្រុះក្នុងឆ្នាំ ២០០៨ ច្បាប់ភូមិបាលឆ្នាំ ២០០១ ច្បាប់ស្តីពីសារធាតុរ៉ែឆ្នាំ ១៩៩៦ ) ក៏ដូចជាគោលដៅកម្មវិធីថ្នាក់ជាតិដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ (២០០៨) ផងដែរ។ បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប៉ារីសនៅឆ្នាំ២០១៦ បទបញ្ញា និងគោលនយោបាយដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន $CO_2$ និងបង្កើនការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញត្រូវបានអនុវត្តន៍ផងដែរ ហើយជាអាទិភាពសម្រាប់ដំណោះស្រាយលើភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានកំណត់សម្រាប់ខេត្តនីមួយៗដើម្បីបង្កើតទីផ្សារពាណិជ្ជកម្មកាបូនសម្រាប់សកម្មភាពអាជីវកម្មដោយយកតាមគំរូដែលបានអនុវត្តន៍រួចហើយនៅអឺរ៉ុប។ រដ្ឋាភិបាលបានផ្តល់នូវធនធាន និងការកៀងគរផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេស និងអន្តរជាតិសម្រាប់ការអនុវត្តយុទ្ធសាស្ត្រផ្សេងគ្នា។ ថវិការបស់រដ្ឋត្រូវបានចែកចាយតាមលក្ខណៈវិនិច្ឆ័យទៅលើភាពធ្ងន់ធ្ងរ និងភាពបន្ទាន់សម្រាប់អន្តរាគមន៍ និងអ្វីដែលជាអាទិភាពដែលបានកំណត់សម្រាប់កំណើនសេដ្ឋកិច្ច។ រហូតមកដល់ពេលបច្ចុប្បន្ននេះការបែងចែកថវិកាទៅលើការស្រាវជ្រាវការប្រែប្រួលអាកាសធាតុនៅមានកម្រិត ហើយភាគច្រើនត្រូវបាន

បែងចែកទៅតាមបណ្តាខេត្តនានាក្នុងទម្រង់នៃការបណ្តុះបណ្តាលជាទ្រឹស្តីលើការប្រែប្រួល និងផលប៉ះពាល់។ ថវិកាដែលខិតខំប្រឹងប្រែងបានពីវិស័យឯកជននៅមានកម្រិតនៅឡើយ ហើយភាគច្រើននៃប្រភពធនធានហិរញ្ញវត្ថុ គឺទទួលបានពីម្ចាស់ជំនួយអន្តរជាតិ។ ម្យ៉ាងវិញទៀត ប្រសិនបើអាជីវកម្មខ្នាតតូចនិងក្រុមហ៊ុនចង់បានការគាំទ្រសម្រាប់ការស្រាវជ្រាវដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនោះ ពួកគេអាចទាក់ទងនាយកដ្ឋានកសិកម្ម និងអភិវឌ្ឍន៍ជនបទ ប្រធានគណៈកម្មាធិការដឹកនាំការងារលើការប្រែប្រួលអាកាសធាតុដែលជាអ្នកចែកចាយប្រភពធនធានហិរញ្ញវត្ថុ។ ម្ចាស់ជំនួយអន្តរជាតិរួមចំណែកក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍលើការប្រែប្រួលអាកាសធាតុ ក្នុងរូបភាពផ្សេងៗគ្នាដូចជា៖ ការឧបត្ថម្ភដើមទុន ផ្តល់ការបណ្តុះបណ្តាល ការអនុវត្តគម្រោងសាកល្បង ជួយសម្របសម្រួលការបង្កើតការងារ សាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងកែលម្អជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។ ដើមទុន និង ឧបត្ថម្ភធន ត្រូវបានបែងចែកផ្តល់ទៅឱ្យប្រជាជនដោយផ្ទាល់ដោយសារតែពួកគាត់ទទួលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ គម្រោង០២ ដែលទទួលបានពីមូលនិធិមានដូចខាងក្រោម៖

- JICA (ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន) គាំទ្រការកសាងប្រព័ន្ធធារាសាស្ត្រនៅក្នុងខេត្ត Ben Tre ដើម្បីទប់ស្កាត់ការហូរចូលទឹកសមុទ្រទៅក្នុងទន្លេ។ រដ្ឋាភិបាលបានខ្ចីទុនអន្តរជាតិរបស់ JICA ជាមួយកម្ចីអត្រាការប្រាក់ទាប។ បន្ទាប់មក JICA ទទួលបន្ទុករៀបចំផែនការ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងអំឡុងឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៣ ។
- គម្រោង AMD (ការបន្សាំនៅតំបន់ដីសណ្តទន្លេមេគង្គ)ទទួលបានហិរញ្ញប្បទានពីមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)។ AMD មានគោលបំណងបណ្តុះបណ្តាលនិងប្រឹក្សាយោបល់ជាមួយអ្នកនៅក្នុងមូលដ្ឋានអំពីការបង្កាត់ពូជ ការដាំដុះ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដើម្បីបន្សាំទៅនឹង ការប្រែប្រួលអាកាសធាតុ។ គម្រោង AMD កំពុងត្រូវបានអនុវត្តន៍នៅតាមបណ្តាស្រុកនានាក្នុងខេត្ត Ben Tre ចាប់តាំងពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០២០ ដោយផ្តល់អត្ថប្រយោជន៍ដល់គ្រួសារក្រីក្រ និងអ្នកមធ្យម។ គោលបំណងសំខាន់ គឺដើម្បីអភិវឌ្ឍន៍ ជីវភាពរស់នៅប្រកបដោយចីរភាពសម្រាប់កសិករដែលទទួលរងឥទ្ធិពលពីប្រែប្រួលរដូវកាលដែលធ្វើឱ្យផលិតកម្មដំណាំមានការថយចុះ។

## វៀតណាម៖ ការអប់រំ

កិច្ចសម្ភាសជាមួយក្រុមមួយមានសមាជិកចំនួន ១៨រូប មកពីស្ថាប័នអប់រំបានចូលរួមផ្តល់ការសម្ភាសជាក្រុម ហើយពួកគាត់ជាតំណាងមកពីសាកលវិទ្យាល័យសង្គម និងមនុស្សសាស្ត្រ ទីក្រុងហូជីមីញ (HCM-USSH) និងសាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហ៊ូ (HUAF) និងសាកលវិទ្យាល័យជាតិជាច្រើនទៀត ព្រមទាំងស្ថាប័នស្រាវជ្រាវផ្សេងៗមានដាក់ក្នុងបញ្ជីរាយនាមនៅក្នុងឧបសម្ព័ន្ធ។ តាមរយៈការសិក្សានេះលទ្ធផលបានបង្ហាញថាប្រធានបទស្រាវជ្រាវមួយចំនួនទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ ត្រូវបានធ្វើការសិក្សារួចមកហើយ និងដំណោះស្រាយក៏ត្រូវបានស្រាវជ្រាវផងដែរ ។

- ដំណោះស្រាយលើប្រព័ន្ធធារាសាស្ត្រដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងផលិតកម្មកសិកម្ម។
- សីតុណ្ហភាពនិងទឹកភ្លៀងកើនឡើង ព្រមទាំងកើតឡើងទឹកជន់លិចជាញឹកញាប់នៅតំបន់ទីក្រុង។ ការវាយ តម្លៃផលប៉ះពាល់ សកម្មភាពបង្ការ និងកាត់បន្ថយដើម្បីកំណត់ការខូចខាត។
- កម្រិតជីវភាពនៅក្រោមលក្ខខណ្ឌអាកាសធាតុថ្មី៖ តើមានតម្លៃអ្វីខ្លះ?
- ការវាយតម្លៃជីវភាពរស់នៅដែលមានភាពងាយរងគ្រោះទៅនឹងផលប៉ះពាល់ការប្រែប្រួលអាកាធាតុ និងការវិភាគពីសមត្ថភាពបន្សាំ ជាពិសេសនៅក្នុងវិស័យព្រៃឈើ។
- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រសម្រាប់ការត្រួតពិនិត្យតាមដាន និងការព្យាករ។
- ការខូចខាតនៅក្នុងសង្គមក្រោមផលប៉ះពាល់បណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ។
- ការគ្រប់គ្រង និងការពារព្រៃឈើ។
- ការស្រាវជ្រាវលើយន្តការដីសឹករេចរិល ភាពរាំងស្ងួត ការឡើងជាតិប្រៃ ការបាក់ដី និងការព្យាករ។
- ការសិក្សាលើការជ្រើសរើស និងបង្កាត់ពូជរុក្ខជាតិដែលអាចបន្សាំទៅតាមតំបន់ និងស្ថានភាពជាក់ស្តែង (ដីខ្សាច់, ជាតិប្រៃ, ភាពរាំងស្ងួត ... ) ។
- ការស្រាវជ្រាវអំពីរបៀបបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សានៅកម្រិតសាកលវិទ្យាល័យ

- ការស្រាវជ្រាវអំពីប្រភពថាមពលកកើតឡើងវិញ និងការអនុវត្តបច្ចេកវិទ្យាថាមពលប្រកបប្រសិទ្ធភាព។

អ្នកផ្តល់ហិរញ្ញប្បទានសំខាន់ៗសម្រាប់ការស្រាវជ្រាវក្នុងវិស័យនេះមានដូចជា៖

- កម្រិតថ្នាក់អន្តរជាតិ៖ ធនាគារពិភពលោក មូលនិធិ Sumitomo, មូលនិធិតូយ៉ូតា, អង្គការទស្សនៈពិភពលោក អង្គការអន្តរជាតិនៃហ្វ្រង់កូហ្វូនី Agence Intergouvernementale de la Francophonie (AIF), អង្គការ Nuffic ។
- កម្រិតរដ្ឋ៖ ថវិការដ្ឋាភិបាល ក្រសួងការងារ ជនពិការ និងសង្គមកិច្ច ក្រសួងវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា ក្រសួងអប់រំ ក្រសួងធនធានធម្មជាតិ និងបរិស្ថាន។
- ថ្នាក់ខេត្ត: នាយកដ្ឋានធនធានធម្មជាតិ និងបរិស្ថាន។
- ស្ថាប័នខាងក្នុង រួមមាន៖ សាកលវិទ្យាល័យជាតិវៀតណាម សាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហូជីមិញ សាកលវិទ្យាល័យកាន់ធឺ វិទ្យាស្ថានទីក្រុងហូជីមិញសម្រាប់សិក្សាលើការអភិវឌ្ឍ ។
- គម្រោង LUCCI: ការស្រាវជ្រាវអំពីកសិ-ព្រៃឈើដែលពាក់ព័ន្ធទៅនឹង ការប្រែប្រួលអាកាសធាតុ ។
- គម្រោង ACCCU: គាំទ្រការធ្វើសមាហរណកម្មក្នុងកម្មវិធីសិក្សាកសិកម្មទាក់ទងនឹងការព្រួយបារម្ភអំពីការប្រែប្រួលអាកាសធាតុនៅសកលវិទ្យាល័យកសិកម្ម៖ សាកលវិទ្យាល័យ Hong Duc សាកលវិទ្យាល័យ កសិកម្ម និងព្រៃឈើហ៊ូ និងសាកលវិទ្យាល័យជាតិកសិកម្មវៀតណាម (ទីក្រុងហាណូយ)។
- គម្រោង JICA សម្របសម្រួលដោយសាកលវិទ្យាល័យក្យូតូ និងសាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហ៊ូ ក្នុងការកសាងសមត្ថភាព លើកកម្ពស់ជីវភាពរស់ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិសម្រាប់ តំបន់ខ្ពង់រាប វាលទំនាប សហគមន៍បឹងផ្កាថ្មនៅក្នុងខេត្តThua Thien Hue ។

ក្រុមអ្នកស្រាវជ្រាវភាគច្រើនត្រូវបានបង្កើតឡើងដោយអ្នកជំនាញមកពីជំនាញផ្សេងៗគ្នា ហើយមានវិធីសាស្រ្តពហុជំនាញអាស្រ័យលើប្រធានបទដែលត្រូវបានកំណត់ថានៅមានចន្លោះប្រហោង ដើម្បីស្រាវជ្រាវនៅក្នុងផ្នែកនេះ។ កត្តាសំខាន់ៗដែលជះឥទ្ធិពលដល់ការបង្កើតក្រុមស្រាវជ្រាវមានដូចជា៖ថវិកាដែលអាចរកបាន បទពិសោធន៍ពីមុនពីការស្រាវជ្រាវ និងចំណេះដឹង

អំពីវិធីសាស្ត្រស្រាវជ្រាវសមស្របក៏ដូចជាជំនាញក្នុងការសរសេរឱ្យបានល្អ។ គ្រឹះស្ថានឧត្តមសិក្សាផ្តល់ហិរញ្ញវត្ថុសម្រាប់ការសិក្សារបស់ពួកគេបានមកពីថវិកាប្រចាំឆ្នាំ ហើយជាឧទាហរណ៍៖ ការស្រាវជ្រាវរបស់នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទទួលបានថវិការដ្ឋ។ ផ្ទុយមកវិញ ដើម្បីទទួលបានមូលនិធិ ការស្រាវជ្រាវមួយចាំបាច់ត្រូវតែអនុវត្ត ហើយប្រធានបទស្រាវជ្រាវចាំបាច់ត្រូវជ្រើសរើស។ បើទោះបីជា គម្រោងមួយចំនួនទទួលបានការគាំទ្រជាឧបករណ៍ និងសម្ភារ មានកម្រិត ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ក្នុងករណីខ្លះមិនត្រូវបានបង្ហាញឱ្យគេឃើញបានគ្រប់គ្រាន់ហើយព័ត៌មានអាចខុសៗគ្នាអាស្រ័យលើអ្នកផ្តល់ឱ្យ ហេតុដូច្នេះភាពជឿជាក់របស់ពួកគេ គឺត្រូវបានចោទសួរនៅពេលដែលវិធីសាស្ត្រប្រើមិនមានតម្លាភាព។ ចាប់តាំងពីការស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុមានឥទ្ធិពលលើវិស័យជាច្រើននៅកម្រិតខុសៗគ្នា វិធីសាស្ត្រពហុជំនាញនៅតែជាមូលដ្ឋានគ្រឹះ។ ក្រុមស្រាវជ្រាវជាទូទៅរួមបញ្ចូលទាំងអ្នកស្រាវជ្រាវដែលមានជំនាញផ្សេងៗគ្នាដូចជា៖ កសិកម្ម សេដ្ឋកិច្ច សិក្សាសង្គម ភូមិសាស្ត្រ ជីវវិទ្យា គីមីវិទ្យា វិទ្យាសាស្ត្របរិស្ថាន។

ឧទាហរណ៍៖

- នៅវិទ្យាស្ថានសម្រាប់សិក្សាការអភិវឌ្ឍទីក្រុងហូជីមិញគម្រោងពហុវិស័យមានអ្នកសិក្សាលើផ្នែកហិរញ្ញវត្ថុ ការអភិវឌ្ឍទីក្រុង អគារបៃតង និងការអភិវឌ្ឍបៃតង។
- គម្រោងស្រាវជ្រាវមួយផ្សេងទៀតដែលគាំទ្រដោយមូលនិធិ AIF រួមមានអ្នកស្រាវជ្រាវមួយចំនួនដែល មានជំនាញផ្នែកហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗប៉ុន្តែក៏មានអ្នកវិទ្យាសាស្ត្រផ្នែកសង្គមគាំទ្រលើផ្នែកស្ថិតិទិន្នន័យ និងការសិក្សាសង្គមតាមបែបគុណភាព។

ជាមួយក្រុមអ្នកស្រាវជ្រាវមួយក្រុម អ្នកនិពន្ធដំបូងដឹកនាំក្រុម និងបែងចែកវាទៅជាក្រុមតូចៗទៅតាមប្រធានបទស្រាវជ្រាវ។ សហអ្នកនិពន្ធប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកដោយផ្ទាល់ឬទំនាក់ទំនងតាមអ៊ីម៉ែលនៅអំឡុងពេលធ្វើការស្រាវជ្រាវ។ ជាធម្មតាប្រធានក្រុមស្រាវជ្រាវជាអ្នកទំនាក់ទំនងគ្នាដោយផ្ទាល់។ បើទោះបីជាកិច្ចសហប្រតិបត្តិការរវាងស្ថាប័នស្រាវជ្រាវមិនមានភាពរឹងមាំ ហើយកិច្ចសហប្រតិបត្តិការរវាងមហាវិទ្យាល័យក្នុងស្ថាប័ននីមួយៗមានលក្ខណៈពិបាក។ លើសពីនេះទៀត អង្គការអន្តរជាតិ និងម្ចាស់ជំនួយមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធរឹងមាំជាមួយស្ថាប័នជាតិជាពិសេសនៅក្នុងផ្នែកការប្រែប្រួលអាកាសធាតុ។ ទាក់ទងនឹងទិន្នន័យដែលអាចរកបាន ក្រសួងធនធានធម្មជាតិ និងបរិស្ថាន គឺជាអ្នកផ្តល់សេវាកម្មចម្បងដោយមាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងវិទ្យាស្ថានហូជីមិញសម្រាប់សិក្សាលើការ

អភិវឌ្ឍន៍ដែលជាទីកន្លែងអាចរកបាននូវព័ត៌មានជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយទម្រង់ (Plateform) សម្រាប់ការចែករំលែកទិន្នន័យមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ ហើយការទំនាក់ទំនងផ្ទាល់ខ្លួនរវាងអ្នកស្រាវជ្រាវ និងអ្នកស្រាវជ្រាវ និងជួនកាលរវាងស្ថាប័នស្រាវជ្រាវនីមួយៗ គឺជាវិធីសាស្ត្រដ៏ពេញនិយមបំផុតសម្រាប់កាផ្លាស់ប្តូរទិន្នន័យទៅវិញទៅមក។ទាក់ទងនឹងការផ្សព្វផ្សាយលទ្ធផល មិនមានទម្រង់លទ្ធផល (Platform reuslts) ក្នុងការប្រមូលទិន្នន័យអំឡុងពេលសិក្សាមិនអាចរកបាន ប្រសិនបើមិនត្រូវបានបោះពុម្ពផ្សាយនៅក្នុងឯកសារវិទ្យាសាស្ត្រ ឬចំណេះដឹងមានកម្រិតចំពោះអ្នកស្រាវជ្រាវដែលដឹងពីគម្រោងច្បាស់លាស់នោះហើយស្នើសុំជាលក្ខណៈបុគ្គល។ លើសពីនេះទៀត ក្នុងករណីនេះការចែករំលែកទិន្នន័យមិនត្រូវបានធានាទេ។ ប្រធានបទដែលគួរធ្វើការស្រាវជ្រាវបន្ថែមមានដូចជា៖

- ការស្រាវជ្រាវតាមបែបគុណភាពលើបញ្ហាសង្គមដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុដោយការសិក្សាអំពីទស្សនៈ និងការយល់ដឹង ព្រមទាំងដំណោះស្រាយដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ។
- ការសិក្សាស្រាវជ្រាវម្តងទៀតឱ្យបានទូលំទូលាយ ហើយនិងតំបន់ណា រងផលប៉ះពាល់តិចតួចមិនទាន់បានធ្វើការស្រាវជ្រាវ ជាពិសេសនៅតំបន់ដីសណ្តទន្លេមេគង្គ។
- ការស្រាវជ្រាវលើបញ្ហាសង្គមដែលទាក់ទងនឹងសុខភាព ការផ្គត់ផ្គង់ម្ហូបអាហារ និងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសហគមន៍ដែលមានភាពងាយរងគ្រោះបំផុត។

ឧបសគ្គចម្បងនៃការស្រាវជ្រាវគឺការគៀងគរប្រភពថវិកាជាពិសេសសម្រាបស្ថាប័នអប់រំ។ សម្ភារឧបករណ៍និងប្រភពធនធានមនុស្សដែលមានមានកម្រិតនៅឡើយដោយសារកង្វះថវិកា។ ការស្រាវជ្រាវត្រូវបានគាំទ្រនៅថ្នាក់ជាតិតាមរយៈអ្នកផ្តល់ឱ្យ ទោះជាយ៉ាងនេះក៏ដោយ ថវិកានៅតែមានដែនកំណត់ និងប្រើពេលវេលាច្រើន និងមានលក្ខខណៈការិយាធិបតេយ្យ។ ដូចនេះ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ជានិច្ចកាល ស្វែករកមូលនិធិពីម្ចាស់ជំនួយអន្តរជាតិ។ ឧបសគ្គចម្បងមួយសម្រាប់ការពង្រឹងសមត្ថភាពធនធានមនុស្សគឺជាឧបសគ្គលើផ្នែកប្រើប្រាស់ភាសានិងជំនាញក្នុងការសរសេរ។ តាមការពិត សិស្សនិស្សិតភាគច្រើន និងគ្រូបង្រៀនខ្លួនឯងមួយចំនួនមិនទាន់ចេះច្បាស់ពីភាសា និងមិនមានបទពិសោធន៍ជាមួយការសរសេរអត្ថបទវិទ្យាសាស្ត្ររហូតដល់ពួកគេបញ្ចប់ការសិក្សា។ ដូច្នេះ ការងាររបស់ពួកគេមានការលំបាកក្នុងការបកស្រាយពន្យល់និងវាក្យស័ព្ទនៅមានការលំបាក។ តាមរយៈការសម្ភាស លទ្ធផលបានបង្ហាញថាទំនាក់ទំនងជាលក្ខណៈបុគ្គល និងអ្នកស្គាល់គ្នា គឺជាកត្តាជម្រុញសំខាន់សម្រាប់ការចែករំលែកទិន្នន័យ និងកិច្ច

សហការក្នុងការស្រាវជ្រាវ ដែលនេះបង្ហាញថាទំនាក់ទំនងតាមបណ្ដាញនៅកម្រិតស្ថាប័ននៅមានភាពទន់ខ្សោយនៅឡើយ និងទាមទារឱ្យមានការលើកកម្ពស់បន្ថែមទៀត។ និស្សិតភាគច្រើនចូលរួមក្នុងក្រុមស្រាវជ្រាវមានតួនាទីជាជំនួយការ និងអ្នកប្រមូលទិន្នន័យ។ និក្ខេបបទនិងកម្មសិក្សារបស់ពួកគេគឺជាឱកាសសំខាន់ដើម្បីអនុវត្តន៍ជំនាញសរសេរ និងការវិភាគ ព្រមទាំងការសង្កេត។ ដោយទទួលបានចំណេះដឹងពីខាងក្រៅលើមុខវិជ្ជានេះ និស្សិតបញ្ចប់ការសិក្សាមិនមានលទ្ធភាពស្វែងរកចន្លោះប្រហោងសម្រាប់ស្រាវជ្រាវ និងអភិវឌ្ឍន៍សំណើស្រាវជ្រាវដែលមានសុពលភាពឡើយ។ កម្មវិធីសិក្សាថ្មីដែលនឹងត្រូវដាក់បញ្ចូលមាន៖

- ឧបករណ៍ជាក់លាក់អំពីការវាយតម្លៃហានិភ័យ ការគ្រប់គ្រងគ្រោះមហន្តរាយ ការបន្សាំនៅក្នុងខ្សែចង្វាក់ផលិតកម្មថ្មី។
- វិធីសាស្ត្រស្រាវជ្រាវវិទ្យាសាស្ត្រ និងម៉ូដែលវិភាគនៅក្នុងវិស័យផ្សេងៗគ្នា។
- ជំនាញក្នុងការព្យាករ
- ជំនាញផ្នែកទន់: សរសេរបែបវិទ្យាសាស្ត្រ ជំនាញភាសាអង់គ្លេស ទំនាក់ទំនង និងការគិតប្រកបដោយតក្កវិជ្ជា។
- ការប្រើប្រាស់ជំនាញផ្នែកទន់សម្រាប់រៀបចំផែនការអន្តរាគមន៍ និងត្រួតពិនិត្យតាមដានការប្រែប្រួលនៅក្នុងផែនទេសភាព និងចំណេះដឹងនៃភាសាសរសេរកូដសម្រាប់ការវិភាគស្ថិតិដូចជា "R" ឬ "Python"

ដូចនេះប្រធានបទដែលគួរធ្វើការបណ្ដុះបណ្ដាលមានដូចជា៖

- ម៉ូដែល និងវិធីសាស្ត្រប្រើប្រាស់ក្នុងការសិក្សាលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការព្យាករ។
- ការសរសេរបែបវិទ្យាសាស្ត្រ និងសរសេរសេចក្ដីព្រាងរបាយការណ៍ (ទម្រង់ វាក្យសព្ទ និងការបកស្រាយ)
- ដំណើរការបំពេញបែបបទស្នើសុំគៀងគរថវិកា(អ្វីដែលជាតម្រូវការដើម្បីទទួលបានជោគជ័យក្នុងការប្រគួតប្រជែងដើម្បីទទួលបានមូនិធិ)។

## ប្រទេសវៀតណាម៖ និស្សិត

មាននិស្សិតសរុបមានចំនួន ១១រូប មកពីសាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហ៊ូ (HUAF) និងសាកលវិទ្យាល័យសង្គម និងមនុស្សសាស្ត្រ ទីក្រុងហូជីមីញ (HCM-USSH) ក៏បានចូលរួមក្នុងការសិក្សានេះដែរ។ តាមរយៈការសម្ភាស លទ្ធផលបានបង្ហាញឱ្យដឹងថាមុខវិជ្ជាទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុមានដាក់បញ្ចូលទៅតាមមហាវិទ្យាល័យផ្សេងៗក៏ដូចជាកម្មវិធីមួយចំនួនដែរ។

- មហាវិទ្យាល័យភូមិសាស្ត្រ៖ មុខវិជ្ជារួមមាន ការប្រែប្រួលអាកាសធាតុ(១ក្រឌីត) រួមបញ្ចូលនៅក្នុងមុខវិជ្ជាការបំពុលខ្យល់
- មហាវិទ្យាល័យសិក្សាអំពីទីក្រុង៖ មុខវិជ្ជារួមមានបរិស្ថាន និងការអភិវឌ្ឍន៍ ហើយនឹងបរិស្ថានសង្គម
- កម្មវិធី “ដំណើរឆ្ពោះទៅអនាគត Kick-off to future” ដែលជាកម្មវិធីរបស់ JCI (Junior Chamber International) ដែលមានកំណត់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំនួន១៧គោលដៅ។ កម្មវិធីរួមមានមុខវិជ្ជាជំនាញផ្នែកទន់ចំនួន ១២មុខវិជ្ជា និងគាំទ្រដល់អ្នកចូលរួមក្នុងការអនុវត្តគម្រោង។ គម្រោងត្រូវតែមានគោលដៅ១ក្នុងចំណោមគោលដៅទាំងចំនួន១៧គោលដៅដែលបានរាយនាម។ ឧទាហរណ៍៖ ទាក់ទងទៅនឹងបញ្ហាបរិស្ថានគឺ “និយាយថាទេ ចំពោះក្រដាសអនាម័យមិនស្អាត”
- កម្មវិធីអភិវឌ្ឍន៍ទីក្រុងប្រកបដោយចីរភាព (SUDP) ជាកម្មវិធីរបស់សមាគមន៍អន្តរជាតិសម្រាប់ការសាងសង់បណ្តាញស្តុកទុកត្រជាក់ (IACSC)។ កម្មវិធីនេះមានជាប្រចាំឆ្នាំអនុវត្តន៍ដោយនាយកដ្ឋានសិក្សាតំបន់ទីក្រុង (HCM-USSH) សាកលវិទ្យាល័យសែនម៉ាឡេស៊ី (USM) នឹងសាកលវិទ្យាល័យក្រុងយូកូហាម៉ា (YCU)។ អំឡុងពេលកម្មវិធីសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យផ្សេងៗគ្នាបង្ហាញពីការស្រាវជ្រាវ និងការសិក្សាលើប្រធានបទពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ តាមភាពជាក់លាក់ផលប៉ះពាល់នៃ ការប្រែប្រួលអាកាសធាតុ និងរបៀបក្នុងការអភិវឌ្ឍតំបន់ទីក្រុងប្រកបដោយចីរភាពក៏ដូចជាការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក៏ត្រូវបានលើកយកមកបង្ហាញផងដែរ។

- កម្មវិធី TF SCALE និងកម្មវិធីផ្លាស់ប្តូរកម្មសិក្សាអំពីការការពារបរិស្ថានទឹករវាងវិទ្យាស្ថាន Rebulic Plytechnic (ប្រទេសសឹង្ហបុរី) និងវិទ្យាស្ថានរបស់យើង។
- មានសកម្មភាពសហគមន៍ជាច្រើនសម្រាប់និស្សិតស្ម័គ្រចិត្ត។ ទោះជាយ៉ាងណាក៏ដោយការប្រែប្រួលអាកាសធាតុ គឺជាប្រធានបទសំខាន់តាមរយៈសកម្មភាពទាំងនោះ។ ឧទាហរណ៍៖ "រដូវក្តៅបៃតង" "ទិវាម៉ោងសម្រាប់ភពផែនដី" ឬ "ការអភិរក្សអណ្តើកសមុទ្រ" ថ្វីបើមានវគ្គជាច្រើនដែលមានប្រធាន

បទជាក់លាក់ពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ ក៏ដោយ ការអនុវត្តជាក់ស្តែងនៅមានកម្រិតនៅឡើយហើយភាគច្រើនជាទ្រឹស្តី។ កម្មវិធីជាក់លាក់ និងទូលំទូលាយមានដូចជា "ដំណើរឆ្ពោះទៅអនាគត" ឬ "ការអភិរក្សអណ្តើកសមុទ្រ" គឺមានការជ្រើសរើសយ៉ាងខ្លាំងព្រោះថាចំនួនអ្នកចូលរួមមានកម្រិត។ លើសពីនេះទៅទៀត កម្មវិធីទាំងនោះត្រូវបានគេប្រារព្ធឡើងជាទូទៅនៅទីក្រុងហូជីមិញ និងទីក្រុងហាណូយដែលធ្វើឱ្យបេក្ខជនមួយចំនួនពិបាកក្នុងការចូលរួម។ កត្តាមួយទៀតគឺកម្មវិធីទាំងនោះ មិនត្រូវបានប្រកាសនៅលើគេហទំព័រផ្លូវការរបស់សាកលវិទ្យាល័យនោះទេ ដែលធ្វើឱ្យនិស្សិតមានការលំបាកក្នុងការទទួលបានព័ត៌មានពីបណ្តាញសង្គម និងអ្នកស្គាល់គ្នា។

ទាក់ទងនឹងប្រសិទ្ធភាពនៃមុខវិជ្ជាក្នុងការបំពេញតាមតម្រូវការរបស់វិស័យឯកជន និងទីផ្សារការងារ ជាទូទៅគំនិតរបស់និស្សិត គឺថាកម្មវិធីសិក្សាមិនបានដាក់បញ្ចូលការអនុវត្តជាក់ស្តែង និងសកម្មភាពចំណេះដឹងក្នុងការដោះស្រាយបញ្ហាទេ។ ដើម្បីលើកកម្ពស់គុណភាពនៃកម្មវិធីនេះ និស្សិតត្រូវបានផ្តល់យោបល់ថាមេរៀនគួរមានអន្តរកម្ម និងប្រើវិធីសាស្រ្តផ្សេងៗដូចជាការដើរតួសម្តែង ការផលិតវីដេអូខ្លី ឬការប្រកួតប្រជែងគ្នាទាក់ទងនឹងមេរៀន។ ការអនុវត្តនៃការស្រាវជ្រាវ និងករណីសិក្សាត្រូវបានគេមើលឃើញថាជាបញ្ហាប្រឈមដែលជម្រុញដល់ការយល់ដឹងអំពីប្រធានបទ និងដំណើរការស្រាវជ្រាវវិទ្យាសាស្រ្ត។ ការស្នើមួយទៀត គឺបង្កើតការសហការគ្នាជាមួយវិស័យឯកជនដើម្បីបង្កើតមាតិកាកម្មវិធី និងដំណើរការស្រាវជ្រាវបែបវិទ្យាសាស្រ្តត្រូវគ្នាជាមួយនឹងស្ថានភាពបច្ចុប្បន្នឬអាចព្យាករបាន។ លើសពីនេះទៀត នៅពេលដែលនិស្សិតចូលរួមនៅក្នុងគម្រោងជាក់ស្តែងលទ្ធផលអាចជាការចូលរួមចំណែកដល់ការអភិវឌ្ឍការស្រាវជ្រាវនិងសេដ្ឋកិច្ចរបស់ប្រទេស។ ម្យ៉ាងវិញទៀត មហាវិទ្យាល័យនីមួយៗគួរតែកសាងបណ្តាញអតីតនិស្សិតដែលបានធ្វើការឱ្យក្រុមហ៊ុនដែលពាក់ព័ន្ធនឹងបញ្ហាបរិស្ថានទូទៅ ឬក្នុងផ្នែកការប្រែប្រួលអាកាសធាតុតែម្តង។ ដោយសារការភ្ជាប់ទំនាក់ទំនងរវាងអតីតនិស្សិត និងនិស្សិតដើម្បីឱ្យអតីតនិស្សិតអាច

ចែករំលែកបទពិសោធន៍ការងារ និងស្រាវជ្រាវរបស់ពួកគេបានយ៉ាងងាយស្រួលជាកត្តាជម្រុញឱ្យមានបណ្ដាញប្រសិទ្ធភាពរវាងសាកលវិទ្យាល័យនិងវិស័យឯកជនផ្ដល់នូវការយល់ដឹងដ៏មានប្រយោជន៍ដើម្បីពង្រឹងកម្មវិធីសិក្សា។ និស្សិតកម្រិតបរិញ្ញាបត្រភាគច្រើនមិនទាន់បានសិក្សាពីផលប៉ះពាល់ជាមួយការប្រែប្រួលអាកាសធាតុនៅឡើយទេ ហើយជាលទ្ធផលពួកគេមានអកម្មក្នុងការជម្រុញ និងស្វែងរក។ ទាក់ទងទៅនឹងនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ដែលបានចូលរួមដោយផ្ទាល់ក្នុងសកម្មភាពស្រាវជ្រាវ និងសកម្មភាពវិជ្ជាជីវៈវាត្រូវបានគេសង្កេតឃើញថាពួកគេយល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់នៃការយល់ដឹងលើការប្រែប្រួលអាកាសធាតុសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងអនាគតនៃប្រទេសជាតិ។ សាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហ៊ូ (HUAF)មានបណ្ដាញយ៉ាងជិតស្និទ្ធនៅក្នុងមុខជំនួញក្នុងការជ្រើសរើស និងណែនាំឱកាសការងារសម្រាប់និស្សិត។ កិច្ចសហប្រតិបត្តិការជាមួយសមាគមន៍ក្រុមហ៊ុនជម្រុញឱ្យនិស្សិតក្នុងការអនុវត្តនិងសិក្សានៅក្រៅប្រទេស (ប្រទេសជប៉ុន អ៊ីស្រាអែល ប្រទេសហ្វាំងឡង់....)។ ក្នុងចំណោមនិស្សិត សក្ដានុពលនៃតម្រូវការនាពេលអនាគតសម្រាប់អាជីពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ហាក់ដូចជាត្រូវបានគេយល់យ៉ាងច្បាស់។ ម្យ៉ាងវិញទៀត និស្សិតមកពី HCM-HSSU បានបង្ហាញពីគុណសម្បត្តិក្នុងការជ្រើសរើសមុខវិជ្ជា ការប្រែប្រួលអាកាសធាតុ ឱ្យត្រូវនឹងមុខតំណែងក្នុងខណៈពេលដែលមុខវិជ្ជាផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស មានការពេញនិយមច្រើនជាង។ ទោះបីជាអាហារូបករណ៍ និងមូលនិធិមានភាពមិនទាន់គ្រប់គ្រាន់ក្នុងការគ្រប់ដណ្ដប់ ត្រូវការឱកាសហិរញ្ញប្បទានត្រូវបានផ្ដល់ដោយសាកលវិទ្យាល័យសាធារណៈក្នុងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យបរទេស។

- បរិញ្ញាបត្រជាន់ខ្ពស់ជំនាញការរៀបចំផែនការថ្នាក់តំបន់ និងនគរូបនីយកម្ម សាកលវិទ្យាល័យAmsterdam (ប្រទេសហូឡង់) សម្រាប់នាយកដ្ឋានសិក្សានគរូបនីយកម្ម (HCM-USSH)។
- កម្មវិធីអាហារូបករណ៍រដ្ឋាភិបាលជប៉ុន និងសាកលវិទ្យាល័យក្យូតូ (សាលាក្រោយឧត្ដមនៃការសិក្សាបរិស្ថានសកល (GEGES) សម្រាប់វគ្គសិក្សាខ្លី ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតជំនាញ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។
- កម្មវិធីចូលរួមវគ្គបណ្ដុះបណ្ដាលរវាងសាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហ៊ូ និងសាកលវិទ្យាល័យ Okayama សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតទាក់ទងទៅនឹងបរិស្ថាន។

- ចូលរួមកម្មវិធីរួមគ្នាសម្រាប់ថ្នាក់បណ្ឌិត និងវគ្គបណ្តុះបណ្តាលលើផ្នែកស្រាវជ្រាវរវាងសាកលវិទ្យាល័យកសិកកម្ម និងព្រៃឈើ និងសាកលវិទ្យាល័យមកពីស៊ុយអែតលើបសុសត្វ និងការប្រែប្រួលអាកាសធាតុ។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវត្រូវបានសង្ខេបដូចខាងក្រោម៖

- លទ្ធផលទទួលបានពី" អាជ្ញាធរជាតិ" និង "វិស័យឯកជន" បានផ្តល់ចម្លើយតាមប្រទេសនីមួយៗថា បើទោះបីជាការទទួលរងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុត្រូវបានអង្កេត និងសិក្សាស្រាវជ្រាវក៏ដោយ ភាពមិនច្បាស់លាស់ចម្បងៗបានបង្កើតឡើងដោយភាពគ្រោះថ្នាក់ និងការកើតឡើងព្រឹត្តិការណ៍ធាតុអាកាសធាតុធ្ងន់ធ្ងរ និងការប្រែប្រួលរយៈពេលយូរនៅក្នុងវដ្តផ្លាស់ប្តូររដូវកាល។ ករណីនៅប្រទេសវៀតណាម មានចំហាកដែលមានសក្តានុពលផ្សេងៗគ្នាបានបង្កើតឡើងដើម្បីការពារ និងធ្វើឱ្យមានដាំដុះកសិកម្មកាន់តែល្អប្រសើរ។ វិធីសាស្ត្រ និងឧបករណ៍ដែលបានប្រើប្រាស់ដំណើរការនេះ ហើយក៏អាចចែករំលែក ដល់ដៃគូនៅក្នុងតំបន់អាស៊ីអាគ្នេយ៍តាមរយៈបណ្តាញ REACT ក្នុងការសម្របសម្រួលពង្រីកកិច្ចសហប្រតិបត្តិការចំពោះចំហាកនៅក្នុងប្រទេសកម្ពុជា និងឡាវ។
- សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ឡាវ និងវៀតណាមពឹងផ្អែកខ្លាំងលើវិស័យកសិកម្ម ជាពិសេសការនាំចេញផលិតផល។ លើសពីនេះទៀត ការអនុវត្តកសិកម្មបានថយចុះនៅតែមានកសិករប្រមាណ ៥០%។ ការប្រែប្រួលអាកាសធាតុបានបង្ហាញថា ការគំរាមកំហែងចម្បងសម្រាប់វិស័យកសិកម្មដោយទទួលរងពីសេដ្ឋកិច្ចសង្គមខ្លាំងខ្លា ជាពិសេសចំពោះកសិករខ្នាតតូចដែលទទួលបានព័ត៌មានតិចតួចបំផុតចំពោះយុទ្ធសាស្ត្រឆ្លើយតប។ ចំពោះទស្សនៈរបស់ចូលរួមផ្តល់សម្ភាសបានបង្ហាញថា កិច្ចសហការគ្នាយ៉ាងស្វិតស្វាញរវាង គ្រឹះស្ថានឧត្តមសិក្សា និងភ្នាក់ងាររដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធនានាដែលនាំឱ្យមានការបង្កើតដំណោះស្រាយយ៉ាងប្រសិទ្ធភាពដែលត្រូវបានផ្ទេរដល់ក្រុមអ្នកទទួលរងគ្រោះ។
- លទ្ធផលទទួលបានពីកិច្ចសម្ភាស និងបញ្ជីសំណួរបានសង្កេតឃើញថាការស្រាវជ្រាវលើការវាយតម្លៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ យុទ្ធសាស្ត្របន្សាំ និងការកាត់បន្ថយកាន់តែស៊ីជម្រៅទាំងនៅកម្រិត គ្រឹះស្ថានឧត្តមសិក្សា និងគ្រប់ក្រសួងស្ថាប័នទាំងអស់។ ចំពោះការចែករំលែកទិន្នន័យអាចរកបាននៅ ប្រទេសវៀតណាម និងឡាវដែលមានការិយាល័យរដ្ឋាភិបាលទទួលខុសត្រូវក្នុងការប្រមូល និងស្តុកព័ត៌មាន

ទទួលបានពីគ្រឹះស្ថានឧត្តមសិក្សា និងបណ្តាការិយាល័យក្រសួងពាក់ព័ន្ធដែលបានស្រាវជ្រាវនៅតាមទីវាល។ ម៉្យាងវិញទៀត ប្រទេសកម្ពុជាខ្វះខាតស្ថាប័នសម្របសម្រួល។ ហេតុដូចនេះ នៅពេលណាមានស្ថាប័នសម្របសម្រួលទើបអាចបង្កើតឱ្យមានវេទិកាចែករំលែក និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ខ្វះបទបញ្ញាផ្ទៃក្នុងដែលធានាដល់តម្លាភាពស៊ីចង្វាក់គ្នានិងប្រភពព័ត៌មានដែលអាចរកបានទិន្នន័យដាក់បញ្ចូល។ ការទំនាក់ទំនងមានសារៈសំខាន់សម្រាប់ការផ្លាស់ប្តូរទិន្នន័យនៅតែមានចំពោះការទំនាក់ទំនងរវាងបុគ្គល និងតាមរយៈស្គាល់គ្នានៅក្នុងប្រទេសទាំងបី។ តាំងពីមានបណ្តាញចែករំលែកទិន្នន័យនៅតែមានតិចតួច និងពិបាកសម្របសម្រួលនៅថ្នាក់ជាតិដែលជាស្ថាប័នកណ្តាល អ្នកនិពន្ធ អាចស្នើសុំបង្កើតឱ្យមានដំណើរការតាមបែបវិមជ្ឈការ។

- ប្រព័ន្ធគ្រប់គ្រង ទិន្នន័យបញ្ចប់ត្រូវបានសំណូមពរឱ្យបង្កើតនៅតាមដៃគូគម្រោង REACT ឱ្យមានស្តង់ដារផ្តល់ដោយ អង្គភាពការប្រែប្រួលអាកាសធាតុ REACT Unit ។ ការអនុវត្តបែបនេះគួរត្រូវបានលើកទឹកចិត្តនៅតាមស្ថាប័នស្រាវជ្រាវផ្សេងៗទៀតនៅក្នុងប្រទេសនីមួយៗដើម្បីមានប្រភពឯកសារបើកទូលាយនិងបង្កើតបណ្តាញនិងការផ្លាស់ប្តូររវាងស្ថាប័ន និងស្ថាប័ន។
- យោងទៅលើព័ត៌មានទទួលបានតាមរយៈបញ្ជីសំណួរ និងក្រុមពិភាក្សាបានបង្ហាញថាប្រភពហិរញ្ញវត្ថុសំខាន់ការស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអកាសធាតុ គឺម្ចាស់ជំនួយអន្តរជាតិ ខណៈដែលវិស័យឯកជនមានគោលដៅបង្កើតផលប្រយោជន៍ និងចូលរួមប្រមូលតិចតួចនៅលើទីវាល។ ថវិការដ្ឋប្រើសម្រាប់ការស្រាវជ្រានៅមានកម្រិត និងការិយាធិបតេយ្យចំពោះការដាក់ស្នើសុំមូលនិធិស្រាវជ្រាវដែលបុគ្គល ឬក្រុមស្រាវជ្រាវ។ គ្រឹះស្ថានឧត្តមសិក្សាអាចបង្កើតឱ្យមានការស្រាវជ្រាវ និងវិស័យឯកជនដោយធ្វើការរួមគ្នាលើករណីសិក្សានេះ និងគម្រោងអនុវត្តន៍ជាក់ស្តែងចែករំលែកធនធានសម្រាប់ទំហំនៃការស្វែងរកដំណោះស្រាយឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។
- ទោះបីជាមានវគ្គមានមុខវិជ្ជាសិក្សា និងមេរៀននៅកម្រិតគ្រឹះស្ថានឧត្តមសិក្សាទាំងតំណាង "និស្សិត" និង "ស្ថាប័នសិក្សា" ចង្អុលបង្ហាញចំណេះដឹង និងស្វែងយល់ពីបញ្ហាពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។ សម្ភារសិក្សា និងកង្វះបទពិសោធន៍ក្នុងការអនុវត្តបានធ្វើឱ្យមានកិច្ចសហការខ្សោយរវាងវស័យឯកជន និងសាកលវិទ្យាល័យដែលឃើញថាជាមូលហេតុសំខាន់ការរៀបចំរបស់និស្សិតមិនគ្រប់គ្រាន់ដើម្បីឱ្យមាន

សកម្មភាពយ៉ាងសកម្មក្នុងការស្រាវជ្រាវ។ ឧបករណ៍ថ្មីៗសម្រាប់មន្ទីរពិសោធន៍ សម្ភារទំនើបទាន់សម័យ និងវិធីសាស្ត្រ និងមានករណីសិក្សាក្នុងការស្នើសុំពីភាគីនិស្សិតក្នុងការធ្វើឱ្យជំនាញរបស់ពួកគេកាន់តែប្រសើរ និងត្រៀមខ្លួនជាស្រេចសម្រាប់ទីផ្សារការងារ។

# ឧបសម្ព័ន្ធ

**តារាង 1៖ ស្ថាប័នពាក់ព័ន្ធចូលរួមក្នុងអង្គភាពស្រាវជ្រាវអន្តរគម្រោង ដៃគូអភិវឌ្ឍន៍ ដៃគូជំនួយ និងជំនួយទទួលបាន**

| ប្រទេស | ស្ថាប័ន | គម្រោង | ដៃគូរនិងចំនួននៃអ្នកជំនាញ | ថវិការសរុប |
|---|---|---|---|---|
| កម្ពុជា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងព្រំប្រទល់នៃធនធានទឹក<br>ការវាយតម្លៃពីភាពងាយរងគ្រោះ<br>ភាពធន់នឹងអាកាសធាតុនៅទីក្រុង<br>កត្តាបណ្តាលឲ្យមានការកាប់បំផ្លាញព្រៃឈើ | - សាកលវិទ្យាល័យវ៉ាស៊ីនតោនភាគខាងលិច UNESCO-IHE<br>- វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី AIT<br>- មជ្ឈមណ្ឌលបង្ការសម្រាប់គ្រោះមហន្តរាយអាស៊ី និង<br>- សាកលវិទ្យាល័យជាដៃគូក្រោមមូលនិធិ CIDA ទាក់ទងការធន់នឹងអាកាសធាតុទីក្រុងនៅតំបន់ដៃគូអាស៊ីភាគខាងត្បូង (UCRSEA) | - ផ្តល់ដោយ UNESCO-IHE ប្រមាណចំនួន ២៥,000 ដុល្លារ (២០១៤-២០១៦)<br>- គម្រោងមូលនិធិសម្រាប់ការបន្សាំរបស់ក្រសួង<br>- បរិស្ថានមានចំនួន ៣0,000 ដុល្លារ (២០១៥-២០១៨), ផ្តល់ជាអាហារូបករណ៍<br>- មូលនិធិ MacArthur គឺជាផ្នែកនៃការអភិរក្សសត្វល្អាបទឹក ប្រហែល ៥,000 ដុល្លារ (២០១៧-២០១៨) |
| | សាកលវិទ្យាល័យមានជ័យ | ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | សាកលវិទ្យាល័យបាត់ដំបង | មូលនិធិផ្តល់ចំនួន ៨,000 ដោយសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| | សាលាកសិកម្មជាតិកំពង់ចាម | ប្រភេទពូជដំណាំដែលធន់នឹងភាពរាំងស្ងួត និងការប្រើប្រាស់ទឹកស្រោចស្រពយ៉ាងសន្សំសំចៃ | អង្គការ និងក្រុមហ៊ុនមួយចំនួនមានបុគ្គលិក៥នាក់ចូលរួមក្នុងកម្មវិធីស្រាវជ្រាវ | មូលនិធិចំនួនតិចជាង ១0,000 ដុល្លារ ផ្តល់ដោយក្រុមហ៊ុន Sapmess (SKY.life.co, Ltd) និងហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល |

| | | | | |
|---|---|---|---|---|
| | សាកលវិទ្យាល័យបាត់ដំបង | ការថែរក្សាផលិតភាព និងប្រាក់ចំណូលទទួលបានពីអនុវិស័យផលផលនៅតាមដងទន្លេសាបដែលប្រឈមនឹងការប្រែប្រួលអាកាសធាតុ | មិនមាន | មូលនិធិចំនួន ១៩៤,000 អឺរ៉ូ ដោយភ្នាក់ងារជាតិសម្រាប់ការស្រាវជ្រាវរបស់បារាំង, ផទិកា BELMONT, មូលនិធិវិទ្យាសាស្ត្រជាតិ (USA),ក្រុមប្រឹក្សាសវិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្មកាណាដា |
| ឡាវ | មហាវិទ្យាល័យសេដ្ឋកិច្ច និងគ្រប់គ្រងពាណិជ្ជកម្ម នៃសាកលវិទ្យាល័យជាតិឡាវ | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបន្សាំរបស់កសិករឡាវ | EPSEA និង IDRC | ១០,000 ដុល្លារ |
| | មហាវិទ្យាល័យព្រៃឈើ នៃសាកលវិទ្យាល័យជាតិឡាវ | ការបន្សាំព្រៃឈើនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកទៅនឹងការប្រែប្រួលអាកាសធាតុ | មហាវិទ្យាល័យព្រៃឈើ, UBC, កាណាដា | APFNET |
| | | គម្រោងស្រាវជ្រាវស្តីពីផលប៉ះពាល់នៃ រ៉េដបូក (REDD+) លើអភិបាលកិច្ចធនធាន និងជីវភាពរស់នៅ | CIFOR, CDE | មិនដឹង |
| | | ការវាយតម្លៃគណនេយ្យកាបូន | IGES | ៥០,000 ដុល្លារ |
| | | ការចូលរួមក្នុងការគ្រប់គ្រងធនធានព្រៃឈើនៅតំបន់ការពារព្រៃឈើនៃប្រទេសឡាវ | សាស្ត្រាចារ្យរង Sithong Thomanivong | មិនដឹង |
| | | គម្រោង IREDD | រាជធានីកូប៉ិនហាក នៃប្រទេសដាណឺម៉ាក | មិនដឹង |
| | | ការកាត់បន្ថយភាពក្រីក្រ និងពង្រឹងបរិស្ថានស្អាតតាមរយៈការស្តារឡើងវិញនូវសេវាកម្មប្រព័ន្ធអេកូឡូស៊ី REDD និង REDD+ | ICRAF ពីប្រទេសហ្វាំងឡង់ | មិនដឹង |
| | | ភាពខុសគ្នានៃជីវម៉ាសនៅក្នុង | N/A | ២០០,000 ដុល្លារ |

| | | | | |
|---|---|---|---|---|
| | | NPA និងការការពារព្រៃឈើជាតិ | | |
| វៀតណាម | សាកលវិទ្យាល័យធនធានធម្មជាតិ និងបរិស្ថាន ហូជីមីញ | ការអនុវត្តលើការវិភាគបែងចែកទៅលើតំបន់ហូរចូលទឹកប្រៃៈ ការសិក្សានៅសហគមន៍ Tan Thanh , Ba Ria - ខេត្ត Vung Tau | សាកលវិទ្យាល័យ កាន់ ធឺ ; វិទ្យាស្ថានបរិស្ថាន និងធនធាន ហូជី មីញ អ្នកវិទ្យាសាស្ត្រ៣នាក់ | មិនដឹង |
| | វិទ្យាស្ថានវិទ្យាសាស្ត្រសង្គមតំបន់ភាគខាងត្បូង | គំរូប្រព័ន្ធផ្សព្វផ្សាយពីការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់សហគមន៍មេគង្គ(ករណីសិក្សានៅខេត្ត Tra Vinh និងខេត្ត Ca Mau | អ្នកវិទ្យាសាស្ត្រ៤នាក់ | ៤៣០ លាន វៀតណាមដុង ទទួលបានពីគ្រឹះស្ថានសិក្សាវិទ្យាសាស្ត្រសង្គមវៀតណាម |
| | វិទ្យាស្ថានសិក្សាការអភិវឌ្ឍហូជីមីញ | ការសិក្សាពីម៉ូដែលនៃការគ្រប់គ្រងទីក្រុងរបស់ទីក្រុងហូជី មិញ ក្នុងបរិបទការប្រែប្រួលអាកាសធាតុ | មិនមាន | ប្រភពថវិកាទទួលពានពីសាលាក្រុងហូជីមិញ |
| | សាកលវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រហូជីមិញ | បញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅតាមតំបន់ដីសណ្តមេគង្គ | មជ្ឈមណ្ឌលសម្រាប់ស្រាវជ្រាវតំបន់សមុទ្រនិងកោះ នៃមហាវិទ្យាល័យនរវិទ្យា មហាវិទ្យាល័យភូមសាស្ត្រ មហាវិទ្យាល័យប្រវត្តសាស្ត្រ សាកលវិទ្យាល័យវិទ្យាសាស្ត្រហូជីមីញ សាកលវិទ្យាល័យបច្ចេកវិទ្យាហូជី មីញ សាកលវិទ្យាល័យ An Giang និងមានការចូលរួមពីអ្នកស្រាវជ្រាវវិទ្យាសាស្ត្រជាង ៦០ នាក់ | 30 លានវៀតណាមដុងសម្រាប់សន្និបាត |
| | វិទ្យាស្ថានមេគង្គ DRAGON សាកលវិទ្យាល័យ កាន់ ធឺ | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើផលិតកម្មកសិកម្មនៅតំបន់ដីសណ្តមេគង្គ | អ្នកវិទ្យាសាស្ត្រ១០នាក់ | មូលនិធិប្រហែលជា ១០០,០០ ដុល្លារ មកពីអង្គការផ្សេងៗ |
| | មជ្ឈមណ្ឌលស្រាវជ្រាវសម្រាប់ការអភិវឌ្ឍជនបទ - | ការស្រាវជ្រាវពីគ្រោះទឹកជំនន់ ភាពរាំងស្ងួត និងការណែនាំពីផលប៉ះពាល់ទឹកប្រៃលើជីវភាពរស់នៅរបស់ប្រជាជន និងកសិករ | អាជ្ញាធរកម្រិតថ្នាក់ខេត្ត, អង្គការក្រៅរដ្ឋាភិបាល និងអ្នកវិទ្យាសាស្ត្រមកពីស្ថាប័នផ្សេងៗ | ចាប់ពី ១០,000 - ២០, 000 ដុល្លារ. |

| | | | | |
|---|---|---|---|---|
| | សាកលវិទ្យាល័យ An Giang | | | |
| | សាកលវិទ្យាល័យដាណាង | សហគមន៍បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | មូលនិធិ Rockefeller | មិនដឹង |
| | សាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហូជីមីញ | ការពង្រឹងសមត្ថភាពគ្រប់គ្រងធនធានព្រៃឈើ | JICA, ICRAF, មហាវិទ្យាល័យព្រៃឈើ - សាកលវិទ្យាល័យព្រៃឈើ ហូជី មីញ | មិនដឹង |
| | | ការវាយតម្លៃពីការបញ្ចូលគ្នានៃប្រព័ន្ធកសិរុក្ខកម្ម | | |
| | មហាវិទ្យាល័យភូមិសាស្ត្រនៃ HCM USSH | ជំងឺដែលបណ្តាលមកពីការឡើងកំដៅ និងទឹកជំនន់ | សហការជាមួយសាកលវិទ្យាល័យខាងក្នុង និងខាងក្រៅប្រទេស | មិនដឹង |
| | | បង្កើនការយល់ដឹងពីការប្រែប្រួលអាកាសធាតុនៅតាមសហគមន៍ | | |
| | | ការបន្សាំខ្លួនរបស់កសិករទៅនឹងការប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | | |
| | | ការស្រាវជ្រាវទឹក និងការប្រែប្រួលអាកាសធាតុ | | |
| | សាកលវិទ្យាល័យ Thai Nguyen | ការបន្សាំខ្លួនទៅនឹងអាកាសធាតុរបស់កសិករតំបន់ភ្នំភាគខាងជើង | ដោយអង្គការឃែរ៍អន្តរជាតិ (Care International) | មិនដឹង |
| | សាកលវិទ្យាល័យកសិកម្ម និងព្រៃឈើហ៊ូ | ការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីបង្រៀន និងស្រាវជ្រាវទាក់ទងនឹងកសិកម្ម ព្រៃឈើ និងជលផល | សាកលវិទ្យាល័យកសិកម្មទាំងអស់នៅវៀតណាម | ២,២៩៨,០០០ អឺរ៉ូ Nuffic, ប្រទេសហូឡង់ |
| | | ការផ្លាស់ប្តូរដីប្រើប្រាស់ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | សាកលវិទ្យាល័យ HUAF មាន៖ មហាវិទ្យាល័យសេដ្ឋកិច្ច គ្រឹះស្ថានសិក្សាពីធនធានទឹក សាកលវិទ្យាល័យបច្ចេកវិទ្យាដាណាង IMHENB នៅហាណូយ | ៥ លាន អឺរ៉ូ, ក្រសួងអប់រំនិងស្រាវជ្រាវសហព័ន្ធអាល្លឺម៉ង់ |

### តារាង 2៖ ការស្រាវជ្រាវតាមផ្នែក និងប្រធានបទដែលអ្នកស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

| ប្រទេស | ស្ថាប័ន | ការស្រាវជ្រាវតាមផ្នែក | ប្រធានបទនៃការស្រាវជ្រាវ |
|---|---|---|---|
| កម្ពុជា | DanChurchAid (DCA) | 1. បច្ចេកទេសកសិកម្មធន់នឹងភាពរាំងស្ងួត<br>2. ការគ្រប់គ្រងទឹកនិងអភិបាលកិច្ច<br>3. ប្រព័ន្ធត្រួតពិនិត្យតាមដានព័ត៌មាន និងភាពរាំងស្ងួត<br>4. វិធីសាស្ត្រក្នុងការវាយតម្លៃបច្ចេកទេសប្រព័ន្ធកសិឧតុនិយម<br>5. ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ | |
| | បុគ្គលិកក្រៅក្របខណ្ឌ | អភិបាលកិច្ចទឹក ការប្រែប្រួលអាកាសធាតុ DRR ការវាយតម្លៃពីផលប៉ះពាល់នៃបរិស្ថានទន្លេមេគង្គ និងយេនឌ័រ | |
| | នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការវាយតម្លៃភាពងាយរងគ្រោះថ្នាក់ សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ និងការវិភាគពីការកាត់បន្ថយ | |
| | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | បង្កើតជម្រើសបន្សាំនឹងអាកាសធាតុសម្រាប់សហគមន៍កសិកម្មនៅខេត្តស្វាយរៀង ប្រទេសកម្ពុជា | |
| | កម្មវិធីអភិវឌ្ឍសហប្រជាជាតិ | ការប្រែប្រួលអាកាសធាតុ និងវិស័យឯកជន ពាណិជ្ជកម្មពន្លឺព្រះអាទិត្យ | |
| | អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ | សារពើភណ្ឌព្រៃឈើថ្នាក់ជាតិ (វាយតម្លៃធនធានព្រៃឈើតាមរយៈការវាស់វែងទីវាល និងទិន្នន័យពីលំហអាកាស | |

| | | | |
|---|---|---|---|
| ឡាវ | NIER | សេដ្ឋកិច្ចបរិស្ថាន និងធនធាន; គោលនយោបាយសាធារណៈ | ការអភិវឌ្ឍជាតិប្រកបដោយចីរភាពនៃប្រទេសឡាវ ជាជំនួយរបស់រដ្ឋាភិបាលឡាវ |
| | NIER | ជំនាញសង្គមវិទ្យា និងបរិស្ថាន | - ការប្រែប្រួលអាកាសធាតុនិងការវាយតម្លៃផលប៉ះពាល់កង្វះខាតទឹកនៅឡាវ: ការសិក្សានៅស្រុក Champhone ខេត្ត Savannakhet, ឧបត្ថម្ភដោយ SIDA តាមរយៈSUMERNET;<br>- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើកសិករខ្នាតតូចនៅឡាវ: ការសិក្សានៅខេត្ត Oudomxay និង Vientiane (២០១៤) ឧបត្ថម្ភដោយគណៈកម្មាធិការទន្លេមេគង្គ<br>- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើអាងស្តុកធំ និងការវាយតម្លៃភាពងាយរងគ្រោះនៅតំបន់ដីសើមមេគង្គក្រោមសម្រាប់ផែនការបន្សាំ៖ ករណីសិក្សានៅតំបន់ដីសើម Xe Chanphone និង Siphandone (២០១១), គាំទ្រដោយដោយគណៈកម្មាធិការទន្លេមេគង្គ។ |
| | NIER | កសិកម្ម ធនធានធម្មជាតិ និងសេដ្ឋកិច្ចបរិស្ថាន | បង្កើនភាពធន់នៃវិស័យកសិកម្មទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (IRAS) ពីឆ្នាំ ២០១២ ដល់ ២០១៥, គាំទ្រដោយ UNDP និង GIF។ |
| | NIER | បញ្ហាទាក់ទងនឹងបរិស្ថាន; ការអភិវឌ្ឍបៃតង; ហិរញ្ញប្បទាន SMEs បៃតង; ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | ការសិក្សាពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកសិករខ្នាតតូចនៅឡាវ (មិនទាន់បានបោះពុម្ពនៅឡើយ) ប្រភពថវិការបស់គណៈកម្មាធិការទន្លេមេគង្គ និងលេខាធិការដ្ឋានមេគង្គជាតិឡាវ) |
| | ដេប៉ាតឺម៉ង់វិស្វកម្មបរិស្ថាន នៃមហាវិទ្យាល័យវិស្វកម្ម NUOL | វាយតម្លៃនៃការប៉ះពាល់បរិស្ថាន ការត្រួតពិនិត្យការការពារបរិស្ថាន ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ | - ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់អនុវត្តន៍ដោយមហាវិទ្យាល័យវិស្វកម្ម NUOL (សារណាបទបញ្ចប់របស់និស្សិត);<br>- ការវាយតម្លៃពីទឹកដែលអាចប្រើបាននិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលំហូរខ្សែទឹកនៅអាងទន្លេណាមសាន ប្រទេសឡាវ (ឯកសារសន្និសិទអន្តរជាតិ);<br>- ការសិក្សាពីភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុនៅស្រុក Xechamphone ខេត្ត Savannakhet (សារណាបទបញ្ចប់សិក្សា |

| | | | |
|---|---|---|---|
| | | | របស់និស្សិតក្រោយឧត្ដម) |
| | ផ្នែកស្រាវជ្រាវ នៃមហាវិទ្យាល័យវិទ្យាសាស្ត្របរិស្ថាន NUOL | ការអភិវឌ្ឍសេដ្ឋកិច្ច និងបរិស្ថាន ផលប៉ះពាល់នៃការវិនិយោគលើបរិស្ថាន និងការប្រែប្រួលអាកាសធាតុ | - មាតិកាវគ្គបណ្ដុះបណ្ដាលស្ដីពីការកាត់បន្ថយ និងការបន្សាំការប្រែប្រួលអាកាសធាតុ<br>- មាតិកាវគ្គបណ្ដុះបណ្ដាលស្ដីពីសេដ្ឋកិច្ចការប្រែប្រួលអាកាសធាតុ |
| | ផ្នែកស្រាវជ្រាវ នៃមហាវិទ្យាល័យវិទ្យាសាស្ត្របរិស្ថាន NUOL | ការប្រែប្រួលអាកាសធាតុ (ម៉ូដែលអាកាសធាតុ ការបន្សាំ និង ការកាត់បន្ថយ) | - ការទប់ស្កាត់វិបត្តិ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយពីគ្រោះទឹកជំនន់នៅទីប្រជុំជននៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ អត្ថបទស្រាវជ្រាវត្រូវបានបង្ហាញដោយអ្នកជំនាញអន្តរជាតិនៅក្នុងការតាំងពិពណ៌អន្តរជាតិពីសុវត្ថិភាពទឹកក្នុងទីក្រុងនៅតំបន់អាស៊ីអាគ្នេយ៍: ការគ្រប់គ្រងហានិភ័យព្រឹត្តការណ៍ធ្ងន់ធ្ងរដែលរៀបចំដោយវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ីនៅឆ្នាំ ២០១៥<br>- សកម្មភាព COP ២១ ពីប្រទេសឡាវ បោះពុម្ពនៅលើព្រឹត្តិបត្តិព័ត៌មាននៅលើបណ្ដាញស្រាវជ្រាវអន្តរជាតិសម្រាប់សង្គមដែលមានការបញ្ចេញកាបូនទាប (LCS-RNet) |
| | NUOL | សេដ្ឋកិច្ចបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ច | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកសិករនៅក្នុងឡាវ |
| | មហាវិទ្យាល័យសេដ្ឋកិច្ច និងគ្រប់គ្រងពាណិជ្ជកម្ម NUOL, សាស្ត្រាចារ្យង Thongphet Chanthanivong | ពន្ធលើបរិស្ថាន | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកសិករនៅក្នុងឡាវ |
| | មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ NUOL | គម្របព្រៃឈើ និងការប្រែប្រួលការប្រើប្រាស់ដី | |
| | មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើបណ្ឌិត Thounthone Vongvisouk នៅសាកលវិទ្យាល័យ NUOL | ការប្រើប្រាស់ដី អភិបាលកិច្ចធនធាន និងជីវភាពរស់នៅ | បរិបទនៃ REDD+ នៅឡាវ របៀបដែលឡាវផ្លាស់ប្តូរការគ្រប់គ្រង REDD+ និង រងចាំបន្ត REDD+ |
| | មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ Doungta | បច្ចេកទេសសមស្រប និងបច្ចេកវិទ្យាឈើដើម្បីធ្វើឲ្យ | គណនេយ្យកាបូនសហគមន៍មូលដ្ឋាន នៅស្រុក Sangthong ក្រុងវៀងចន្ទន៍ ប្រទេសឡាវ |

| | | | |
|---|---|---|---|
| | Bouaphavong NUOL | ប្រសើរឡើងការដាំម៉ៃសាក់នៅឡាវ | |
| | មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ Saykham Boutthavong NUOL | វិទ្យាសាស្ត្របរិស្ថានព្រៃឈើ | ត្រៀមចូលរួមនៅក្នុងកម្មវិធី REDD+ គណនេយ្យកាបូនសហគមន៍ ការតាមដានជីវម៉ាសព្រៃឈើ |
| | មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ, Viengsy Paothor NUOL | ការអភិវឌ្ឍអេកូទេសចរណ៍ | |
| | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម NUOL | ការវាយតម្លៃពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធាននៃការបន្សាំជាតិ | ភាពងាយរងគ្រោះ និងការបន្សាំនៃការធ្វើស្រែតាមបែបយថាផលដែលបណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលវិសមរូបអាកាសធាតុនៅខេត្ត Savannhakhet |
| | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម NUOL | សេដ្ឋកិច្ចសង្គម | គម្រោង NAFRI, IRAS |
| | លេខាធិការដ្ឋានគណៈកម្មាធិកាជាតិទន្លេមេគង្គនៃប្រទេសឡាវ | សារធាតុពុលសរីរាង្គ (PCB, dioxins/furans) គោលនយោបាយនៃការបន្សាំនឹងការប្រែប្រួលអាកាសធាតការគ្រប់គ្រងធនធានទឹក និងការប្រើប្រាស់ | របាយការណ៍វិភាគគោលនយោបាយនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានដាក់ឲ្យគណៈកម្មាធិការទន្លេមេគង្គសម្រាប់គម្រោងវិភាគគោលនយោបាយពីការប្រែប្រួលអាកាសធាតុនិងការបន្សាំនៅអាងទន្លេមេគង្គក្រោម និងយុទ្ធសាស្ត្រនៃការបន្សាំរបស់ទន្លេមេគង្គ និងផែនការសកម្មភាពដែលស្ថិតនៅក្នុងកម្មវិធីការប្រែប្រួលអាកាសធាតុ និងគោលគំនិតបន្សាំ។ |
| វៀតណាម | សាកលវិទ្យាល័យ កាន់ធឺ មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម | យេនឌ័រ ការធ្វើចំណាកស្រុក ការរៀនពីសង្គម | ចំណាកស្រុក ការប្រែប្រួលអាកាសធាតុ និងបរិស្ថានសម្រាប់ជាភស្តុតាងក្នុងបង្កើតជាគោលនយោបាយ |
| | សាកលវិទ្យាល័យ កាន់ធឺ | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យទេសចរណ៍ | ការវាយតម្លៃនៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យទេសចរណ៍នៅតំបន់ដីសណ្តទន្លេមេគង្គ បេក្ខជនបណ្ឌិត Huynh Van Da ក្នុងឆ្នាំ២០១៨។ |
| | ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ មហាវិទ្យាល័យសង្គមសាស្ត្រ នៃសាកលវិទ្យាល័យកាន់ | យេនឌ័រ បរិស្ថាន និងគ្រួសារ | ការវាយតម្លៃនៃភាពងាយរងគ្រោះយេនឌ័រនៅខេត្តកាម៉ូ ក្នុងបរិបទការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ ២០១៤ របស់អង្គការ GTZ |

| | | | |
|---|---|---|---|
| | ធី | | |
| | នាយកដ្ឋានការប្រែប្រួលអាកាសធាតុនៅសាលាក្រុងកាន់ធី | បរិស្ថាន និងការប្រែប្រួលអាកាសធាតុនៅតំបន់ដីសណ្តទន្លេមេគង្គ | ផែនការសកម្មភាព - ការបន្សាំនៃការប្រែប្រួលអាកាសធាតុនៅទីក្រុងកាន់ធី ក្នុងឆ្នាំ ២០១៦-២០៣០ ដែលសម្រេចបានឆ្នាំ ២០១៥ និងប្រើប្រាស់ប្រភពមូលនិធិ Rockefeller - ACCCRN |
| | នាយកដ្ឋានការប្រែប្រួលអាកាសធាតុនៅសាលាក្រុងកាន់ធី | ប្រព័ន្ធចាប់យកព័ត៌មានពីលំហអាកាស (Remote Sensing) និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) នៅក្នុងការគ្រប់គ្រងកសិកម្ម និងព្រៃឈើ | ផលប៉ះពាល់នៃការកាត់បន្ថយសារធាតុចិញ្ចឹម និងចំនួននៃដីល្បាប់ចំពោះកសិកម្ម និងជីវភាពរស់នៅក្នុងក្រុមស្រាវជ្រាវ An Giang: Pham Van Quang និងមហាវិទ្យាល័យអភិវឌ្ឍន៍ជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ |
| | មហាវិទ្យាល័យសេដ្ឋកិច្ច និងគ្រប់គ្រងពាណិជ្ជកម្ម នៃសាកលវិទ្យាល័យThai Nguyen | សេដ្ឋកិច្ចកសិកម្ម | ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងសម្រាប់តំបន់ភ្នំភាគខាងជើងនៅវៀតណាម |
| | មជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រងទឹកនិងការប្រែប្រួលអាកាសធាតុ | ការគ្រប់គ្រងប្រភពទឹក, ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | |
| | ដេប៉ាតឺម៉ង់កសិកម្ម និងធនធានធម្មជាតិនៃសាកលវិទ្យល័យ An Giang, | ជីវភាពរស់នៅ ការគ្រប់គ្រងធនធានធម្មជាតិ ចំណេះដឹងរបស់ជនជាតិដើមភាគតិច វិស័យទេសចរណ៍នៅតាមទីជនបទ ទឹកជំនន់ និងការប្រែប្រួលអាកាសធាតុ។ | បទពិសោធន៍របស់ប្រជាជនទៅលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ដីសណ្តតាមទន្លេមេគង្គ (ករណីសិក្សានៅខេត្ត An Giang) |
| | មជ្ឈមណ្ឌលស្រាវជ្រាវសម្រាប់ការអភិវឌ្ឍជនបទ នៃសាកលវិទ្យាល័យ An Giang, | អភិបាលកិច្ចទឹក អេកូឡូស៊ីកសិកម្ម ការប្រែប្រួលអាកាសធាតុ | ការបន្សាំទៅការប្រែប្រួលអាកាសធាតុតាមរយៈការអភិរក្ស និងការអភិវឌ្ឍប្រព័ន្ធកសិកម្មដំណាំស្រូវនៅក្នុងតំបន់តាមដីសណ្តមេគង្គ។ ថវិកាសរុបជាង ១០០,០០០ ដុល្លារអាមេរិកពី SEARCA SUMERNET នៃគោលនយោបាយសាធារណៈទន្លេមេគង្គក្រោម Mitsui។ |
| | មហាវិទ្យាល័យភូមិសាស្ត្រ នៃ HCM USSH | ព័ត៌មានបរិស្ថាន | ការស្រាវជ្រាវពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ប្រព័ន្ធព័ត៌មានពីលំហអាកាស និង ការគណនាតាមម៉ូដែល ការព្យាករ ការកើនឡើងសីតុណ្ហភាពលើផ្ទៃដីនៅទីក្រុងហូជី មីញ - ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទីក្រុងហូជីមិញ |

| | | | |
|---|---|---|---|
